# ឧត្តមគតិ

# លោក អៀវ កើស



មេធាវី ង៉ែត ហៀន

# ឧត្តមគតិ

# លោក អៀវ_កើស

អតីតប្រធានរដ្ឋសភានិតិកាលទី ១

ការផ្សាយរបស់អ្នករៀបរៀង

**ខែត ហឿន**

ព.ស. **២៥១៥** គ.ស.**១៩៧១**

រក្សាសិទ្ធិ



# ប៉ាច ឈឺន ចាងហ្វាងនយោបាយសារព័ត៌មាន នគរវត្ត

លោក **ប៉ាច ឈឺន** លោក **ស៊ឺម វ៉ុក ថាន់** និងលោក **ស៊ីម វ៉ា** រដ្ឋបុរស ៣ រូបនេះមានគុណចំពោះជាតិខ្មែរយ៉ាងលើសលប់ ព្រោះអប់រំជាតិតាមសំលេងសារពត៌មាននគរវត្ត ឱ្យកូនខ្មែរក្រោកឈរឡើងទាមទារឯករាជ្យពីអាណានិគមនិយមបារាំង តាំងពីឆ្នាំ ១៩៣៦ នោះម្ល៉េះ ។

ខេមរៈជនទាំងឡាយ ដែលចេះស្នេហាជាតិពិតជាភ្ញាក់រលឹក តាមមាគ៌ានយោបាយរបស់រដ្ឋបុរស ៣ រូបនេះគួសដៅបញ្ជាក់ឱ្យធ្វើតាមរហូតដល់បានឯករាជ្យបរិបូណ៌ ។

បើដូច្នេះចូរខេមរៈជនរួមជាតិ មិនត្រូវបំភ្លេចគុណរដ្ឋបុរស ៣ រូបនេះចោលឡើយ ព្រោះរដ្ឋបុរសនេះទទួលទណ្ឌកម្មពីអាណានិគមនិយមបារាំងគ្រប់បែបយ៉ាង ព្រោះតែរឿងទាមទារឯករាជ្យឱ្យជាតិ ។

មុននឹងលោក អៀង កើស បញ្ចាឱ្យខ្ញុំ ង៉ែត ហៀន ធ្វើញត្តិសូមដោះលែង

រដ្ឋបុរសទាំងឡាយ មានលោកប៉ាច ឈឿន ជាដើម លោកនិយាយថា ជាតិណាមិនស្គាល់គុណរដ្ឋបុរសជាតិខ្លួនទេ ជាតិនោះពិតជារកវឌ្ឍនភាពមិនឃើញឡើយ ។ ហើយលោកបញ្ជាក់ថែមទៀតថា ការស្គាល់គុណរដ្ឋបុរសរបស់ខ្លួននេះ ជាមធ្យោបាយយ៉ាងពិសេស នាំឱ្យជាតិទៅកាន់សុភមង្គល ព្រោះបំផុសមតិមហាជនទាំងជាតិ ឱ្យមានការចាប់អារម្មណ៍ស្រើបស្រាលទៅលើប្រយោជន៍សាធារណៈដែលជាមូលដ្ឋាននៃប្រយោជន៍ឯកជន ។ នៅអរិយៈប្រទេសទាំងឡាយមកពីជនជាតិគេស្គាល់តម្លៃមនុស្សដែលធ្វើប្រយោជន៍ឱ្យជាតិជាក់ច្បាស់ណាស់ បានជាជនជាតិគេជឿនលឿនទាន់សម័យនិយម ។ ខ្ញុំមានការបារម្ភតែមួយគត់គឺខ្លាចក្រែងជនជាតិយើង បានឯករាជ្យមកហើយឡើងកាន់ការជំនួស បារាំងមិនធ្វើប្រយោជន៍ជាតិ ឱ្យមានខ្លឹមសារបែរទៅធ្វើប្រយោជន៍ផ្ទាល់ខ្លួននឹងបក្ខខ្លួនទៅវិញ នាំឱ្យជាតិរឹតតែលិចលង់ថែមទៅទៀត ។ បើដូច្នេះពិតមែន សមដូចបុរាណភាសិតបានពោលទុកថា ធ្វើគុណមួយសំពៅ តែបណ្តោយឱ្យទោសមួយចូលទៅរលាយគុណបាត់ ។ ចេះកប់ពពកមកជ្រកអាចម៍ជន្លេន បុរាណភាសិតពីឃ្លានេះជាពាក្យតឿនក្រើនរំលឹកស្មារតីនៃអ្នកស្នេហាជាតិ កុំឱ្យបណ្តោយខ្លួនទៅអត្តាធិបតី ។ លោកអៀវ.កើស ពិតមែនតែស្លាប់ទៅហើយ ប៉ុន្តែសំដីរបស់លោកនៅរស់រវើកគួរតែខេមរៈជនប្រព្រឹត្តតាម ។ នៅទីបំផុតខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យទាំងបី នឹងឧត្តមគតិវីរបុរសអ្នកស្នេហាជាតិមកដឹកនាំពលរដ្ឋខ្មែរឱ្យមានឯកភាពបានជាមហាអំណាចដូចពីដើមវិញ ។

# ពាក្យឧទ្ទេសកថា

ខ្ញុំមានយោបល់ថា ឧត្តមគតិរបស់លោកអ្នកឧកញ៉ា **អៀង-គើស** ដែលជាកល្យាណមិត្តជាមួយនឹងខ្ញុំយ៉ាងជិតស្និទ្ធបានទទួលបាបគ្រោះជាមួយគ្នា ក្នុងការិយាល័យគណៈបក្ស **ប្រជាធិបតេយ្យ** ព្រោះតែធ្វើនយោបាយដើម្បីជាតិ ។

លោកអ្នកឧកញ៉ា **អៀង-គើស** ធ្វើមរណៈកាលទៅហើយ ចំណែកខ្ញុំវិញមានជីវិតរស់នៅដល់សព្វថ្ងៃនេះ មិនគួរឡើយខ្ញុំនឹងបំភ្លេច ឧត្តមគតិរវាងលោកនឹងខ្ញុំចោលទេ ។

គួរតែខ្ញុំស្រង់យក នូវចំណុចសំខាន់១ខ្លះ មកចងក្រងតាមវគ្គ ឱ្យអនុជនខាងក្រោយត្រិះរិះពិចារណាប្រយោជន៍យកមកធ្វើជាមូលដ្ឋាន ដើម្បីធ្វើជានយោបាយបោះជំហានតទៅមុខទៀត កុំឱ្យភ្លាត់ស្នៀត ចាញ់កលល្បិចមធ្យោបាយជនបរទេសបាន ។

ខ្ញុំសូមបញ្ជាក់ទៀតថា លោកអ្នកឧកញ៉ា **អៀង-គើស** និងខ្ញុំនេះ ពុំមែនទើបតែស្គាល់គ្នាក្នុងពេលដែលមកធ្វើអ្នកនយោបាយនោះទេ គឺស្គាល់គ្នាជាយូរឆ្នាំមកហើយ លោកអាចស្គាល់ជម្រៅនយោបាយរបស់ខ្ញុំបានសព្វគ្រប់ទាំងអស់ ចំណែកខ្ញុំវិញក៏អាចស្គាល់នយោបាយរបស់លោកសព្វគ្រប់ទាំងអស់ដែរ ។

ម្ល៉ោះហើយនៅក្នុងរដ្ឋសភាជាតិលើកទី១ លោកមានសេចក្ដីទុកចិត្ត មកលើរូបខ្ញុំជាពិសេស ជាងអ្នកដំណាងរាស្ត្រឯទៀតទាំងអស់ បើមានកិច្ចការអ្វី១លោកពុំដែលលាក់នឹងខ្ញុំឡើយ ហើយថែមទាំងបេសកកម្មលោកបានឱ្យខ្ញុំជួយ

មើលការខាងក្រៅ តាងនាមរបស់លោកទៀតផង ។

គួរឱ្យអស្ចារ្យណាស់ ពេលដែលខ្ញុំនិងលោក មិនទាន់បានជួបគ្នា បច្ចាមិត្ត វាពុំបានសម្លាប់លោក ឬសម្លាប់ខ្ញុំទេ ដល់ខ្ញុំនិងលោក បានសន្ទនាគ្នាតែពីរនាក់ នៅក្នុងការិយាល័យគណៈបក្ស **ប្រជាធិបតេយ្យ** ជាឱកាសល្អហុចឱ្យបច្ចាមិត្ត វាមកចោលគ្រាប់បែក ដើម្បីឱ្យស្លាប់ទាំងពីរនាក់តែម្តង ខ្ញុំដែលមានជីវិតរស់នៅនេះ ព្រោះតែសំដីលោកប្រាប់ខ្ញុំថា មាននរណាចោលអ្វី ខ្ញុំក៏ស្ទុះក្រោកឡើង បើកុំតែខ្ញុំស្ទុះក្រោកឡើង អំបែងគ្រាប់បែកមួយផ្នែកទៀត នឹងត្រូវចំពោះខ្ញុំដល់ស្លាប់តែម្តង ប៉ុន្តែខ្ញុំរស់រានមានជីវិតនេះ មកពីសំដីរបស់លោកនោះហើយ ។

ហេតុនេះហើយ ខ្ញុំត្រូវតែលើករឿងទាំងអស់នោះ មកចងក្រងទុក ឧទ្ទិសចំពោះវិញ្ញាណខ័ន្ធរបស់លោក ដែលជាកល្យាណមិត្តមួយក្នុងមួយជាតិនេះ ខ្ញុំរកមិនបានទាល់តែសោះ ។

ជាទីបំផុត ខ្ញុំសូមអភ័យទោស អំពីមិត្តអ្នកអាន ខ្ញុំបំរុងនឹងនិពន្ធរឿងនេះ ជាយូរណាស់មកហើយ ប៉ុន្តែបរិយាកាសមិនបើកឱ្យ បានជាខ្ញុំបៀមរឿងនោះទុករហូតមកដល់សព្វថ្ងៃនេះ ឥឡូវនេះ បរិយាកាសបានហុចឱ្យហើយត្រូវតែខ្ញុំនិពន្ធរឿងតាមដំណើរ រឿងនេះជារឿងពិត មានកន្លែងខ្លះនៅក្នុងសេចក្តីកត់ហេតុ មានកន្លែងខ្លះទៀត គ្មានក្នុងរាជកិច្ចទេ ព្រោះខ្ញុំនឹងលោកពិគ្រោះគ្នាតែពីរនាក់ ភាគច្រើននៅក្នុងការិយាល័យគណៈបក្សខ្លះ នឹងនៅក្នុងការិយាល័យប្រធានរដ្ឋសភាជាតិខ្លះពាក្យពេចន៍ពុំមែនដូចសំដីលោកសុទ្ធសាធទេ ប៉ុន្តែអត្ថន័យមិនឃ្លាតចាកប្រធានឡើយ ។

បើលោកអ្នកអាន ឃើញទាស់ឆ្គាំឆ្គងកន្លែងណាសូមមេត្តាអភ័យទោស ចំពោះរូបខ្ញុំផង ខ្ញុំដែលរចនារឿងនេះឡើង មានគំនិតតែមួយ គឺចង់រក្សានូវឧត្តមគតិ នឹងសេចក្តីស្នេហាជាតិរបស់លោក ទុកឱ្យអនុជនជំនាន់ក្រោយពិចារណា ត្រង់ណាខុសកុំដើរតាម ត្រង់ណាដែលត្រូវគួរតែយកទៅពិចារណា ជាឧត្តមគតិរបស់ខ្លួន តទៅទៀតតែប៉ុណ្ណោះ ។

សៀវភៅនេះដាក់ចំណងជើងថាឧត្តមគតិលោក **អៀច-ភើស** ។

អ្នកនិពន្ធ

មេធាវី **ខ៊ែត-ហៀន**



## អៀវ-កើស

លោក **អៀវ-កើស** អ្នកតំណាងរាស្ត្រ មណ្ឌលក្រុងភ្នំពេញផង អគ្គលេខាធិការគណៈបក្សប្រជាធិបតេយ្យផង ប្រធានរដ្ឋសភាជាតិផងអ្នកទាមទារឯករាជ្យតពីលោកប៉ាច.ឈឿន លោកសឺង.ង៉ុក.ថាន់ លោកស៊ឹម.វ៉ា លោកជុំ.មួង និង លោកង៉ោ.ហុង ។

## វគ្គទី ១

តាមឧត្តមគតិលោក **អៀវ-កើស** អតីតប្រធានរដ្ឋសភាជាតិឆ្នាំ ១៩៤៦ លោកមានប្រសាសន៍ថា មុននឹងចង់បានឯករាជ្យ ត្រូវយើងស្វែងរកលទ្ធិ **ប្រជាធិបតេយ្យ** មកជូនជាតិឱ្យបានជាមុនសិន ។ នាកាលជាតិយើងបានលទ្ធិប្រជាធិបតេយ្យ មកធ្វើជាមូលដ្ឋានហើយ. ជាតិយើងមានសិទ្ធិធ្វើនយោបាយដើម្បីទាមទារឯករាជ្យ ពីអាណានិគមនិយមបារាំងសែសបាន ។

បើកាលណាមានរដ្ឋសភាជាតិ ជាអ្នកដំណាងឆន្ទៈរបស់ប្រជាជនរួមជាតិ បើមតិភាគច្រើនវិនិច្ឆ័យទៅសេចក្តីទៅយ៉ាងណា អាណានិគមនិយមបារាំង ត្រូវតែយកមតិនោះទៅពិចារណា រកមធ្យោបាយដោះស្រាយឱ្យយើង ។

ខសំខាន់ត្រូវគណៈបក្សប្រជាធិបតេយ្យយើង រចនារដ្ឋធម្មនុញ្ញ ឱ្យមានអង្គការរដ្ឋឱ្យបានល្អ ឱ្យបានស្របតាមគំនិតប្រជាធិបតេយ្យពិតប្រាកដ ។ *រដ្ឋធម្មនុញ្ញនេះហើយជាមាគ៌ានយោបាយរបស់ជាតិ ខេមរៈជនត្រូវតែអនុវត្តន៍វិធានការ ឱយស្របតាមបន្ទាត់រដ្ឋធម្មនុញ្ញយើង* ។ កាលយើងធ្វើរដ្ឋធម្មនុញ្ញនេះមានឧបសគ្គ ពួកអាណានិគមនិយមបារាំង មកចាប់សមាជិកគណៈបក្សប្រជាធិបតេយ្យយើងមានលោកស៊ឹម.វ៉ា ជាដើម ដោយចោទថាពួកផ្កាយខ្មៅចំពោះមុខខ្ញុំ ក្នុងរដ្ឋសភាជាតិ ។

ការដែលអាណានិគមនិយមបារាំងធ្វើយ៉ាងនេះប្រយោជន៍ ដើម្បីសំឡុត

ស្មារតីរបស់សមាជិករដ្ឋសភាជាតិយើង ឱ្យងាករេគំនិតទៅតាមសេចក្ដីណែនាំរបស់គេតែប៉ុណ្ណោះ ។

នាកាលបើសមាជិករដ្ឋសភាយើង ងាករេទៅតាមសេចក្ដីណែនាំរបស់គេហើយ ពិតជាសមាជិកគណៈបក្សយើងគ្មានគ្រោះថ្នាក់អ្វី ក្នុងអនាគតកាលទេ ។ *ប៉ុន្តែឧត្តមគតិរបស់ជាតិ ដែលចង់បានឯករាជ្យនោះសន្មត់ថា រលត់រលាយត្រឹមប៉ុណ្ណោះដែរ យើងរាល់គ្នាចង់បានឯករាជ្យឱ្យជាតិពិតប្រាកដមែនត្រូវតែបានលះបង់នូវប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីបូជាជូនជាតិ ។*

តាមមតិខ្ញុំផ្ទាល់ខ្លួន នៅប្រទេសអឺរ៉ុប គេបានកាន់កាំភ្លើងទៅច្បាំងដើម្បីការពារប្រទេសគេកុំឱ្យបាត់បង់ឯករាជ្យ ចុះជាតិយើងមានទៅច្បាំងនិងអ្នកណា គ្រាន់តែសម្ដែងមតិបង្ហាញគេថាខេមរៈជាតិចង់បានឯករាជ្យប៉ុណ្ណោះ ម្ដេចជាតិយើងខ្លាចទៅវិញ ។ យើងម្នាក់ៗ ត្រូវសួរខ្លួនឯងមើលថា បើយើងខ្លាចហើយតើឱ្យនរណាមកបានជួសយើងទៅវិញ ។ *តាមមតិរបស់ខ្ញុំ គុកគេធ្វើសំរាប់ដាក់មនុស្សពិតមែនហើយ ប៉ុន្តែមនុស្សមានឧត្តមគតិភាគច្រើនដូចគ្នា គេមិនអាចរកគុកដាក់មនុស្សបានទេ ចំណុចត្រង់នេះដែលយើងត្រូវមានជ័យជំនះ* ។

ខ្ញុំសូមរំលឹកដល់អស់លោកឡើងវិញថា កាលបោះឆ្នោតជ្រើសរើសអ្នកដំណាងរាស្ត្រលើកទី ១ គណៈបក្សយើងបានឃោសនាថា យើងតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យពិតប្រាកដ *បើស្លាប់ម្នាក់ត្រូវមានដប់នាក់មកជំនួសអ្នកស្លាប់ បើស្លាប់ដប់នាក់ ត្រូវមានមួយរយនាក់ មកជំនួសមនុស្សដប់នាក់* សូមអស់លោកកុំភ្លេច បាវចនាគណបក្សយើង *វិន័យ ថ្លៃថ្នូរ ក្លាហាន* យើងត្រូវតែ *សាមគ្គី ពុះពារ*

តស៊ូទៅទៀត ។

## វគ្គទី ២

ដល់ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៤៧ លោក **អៀវ-កើស** បោះឆ្នោតជាប់ជាប្រធានរដ្ឋសភាពេញទី មានករណីកិច្ចត្រូវដឹកនាំសមាជិករដ្ឋសភាជាតិ ។

លោក **អៀវ-កើស** តែងតែឱ្យឱវាទសមាជិករដ្ឋសភាខាងគណៈបក្សប្រជាធិបតេយ្យថា អស់លោកបន្ទុករដ្ឋសភាលើកនេះ *ធ្ងន់ជាងបន្ទុករដ្ឋសភាបណ្ដោះអាសន្នទៅទៀតព្រោះរដ្ឋសភាយើង ត្រូវអនុវត្តន៍ច្បាប់រដ្ឋធម្មនុញ្ញហើយ* ។ ការអនុវត្តន៍ច្បាប់រដ្ឋធម្មនុញ្ញពុំមែនស្រួលទេ ព្រោះផ្ទះមួយម្ចាស់ពីរ បើយើងចង់រៀបផ្ទះយ៉ាងនេះ បារាំងថាឱ្យរៀបចំយ៉ាងនោះទៅវិញ បើយើងមិនស្ដាប់បារាំងប្រាកដជាមានឧបសគ្គ មកដល់គណៈបក្សយើងទៀតហើយ បើយើងស្ដាប់តាមបារាំង *រដ្ឋធម្មនុញ្ញជាមាគ៌ានយោបាយរបស់ជាតិយើង និងក្លាយទៅជារបស់ឥតមានតម្លៃ* ហើយថែមគណៈបក្សយើងភាគច្រើន ក្លាយទៅជាមនុស្សជាប់ចោទ ពីប្រជាពលរដ្ឋផងថែមទៀត ។

តាមឧត្ដមគតិរបស់ខ្ញុំថា គណៈបក្សយើងមិនត្រូវងាករេពីផ្លូវដែលគណៈបក្សយើង ត្រួសត្រាយរួចទៅហើយនោះទេ ទោះបីជាមានឧបសគ្គយ៉ាងណាក៏ដោយ ត្រូវតែយើងអនុវត្តន៍វិធានការ ទៅតាមទិសដៅរបស់គណៈកម្មការនាយក

របស់យើងតទៅទៀត ។ ខ្ញុំសូមរំលឹកថា មនុស្សអ្នកនយោបាយកសាងជាតិពិតប្រាកដ ត្រូវតែទទួលលទ្ធផល ៣ យ៉ាង :

*ទី១- ត្រូវស្លាប់ខ្លួន ព្រោះសេចក្ដីស្មោះត្រង់នឹងជាតិ ។*

*ទី២- ត្រូវជាប់គុក ព្រោះសេចក្ដីស្មោះត្រង់នឹងជាតិ ។*

*ទី៣-ត្រូវរត់ចោលស្រុក ចោលប្រទេស ព្រោះសេចក្ដីស្មោះត្រង់នឹងជាតិ ។*

នេះបើយើងធ្វើនយោបាយ ដើម្បីជាតិពិតប្រាកដ ។ ប៉ុន្តែបើយើងធ្វើនយោបាយ ដើម្បីខ្លួនវិញទោសទាំង ៣ យ៉ាងដូចខ្ញុំជំរាបរួចមកហើយនេះ ត្រូវតែឆ្លងផុតក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ។ តែលទ្ធិប្រជាធិបតេយ្យ និងឯករាជ្យនៃជាតិដែលជាទីដៅនៃគណៈបក្សយើងនោះ *និងក្លាយទៅជាមោឃៈទៅហើយ* ។ អនុជនជាន់ក្រោយដែលរៀនប្រវត្តិសាស្ត្រមិនដឹងជាពេបជ្រាយឱ្យយើងយ៉ាងណាទេហើយឯករាជ្យប្រទេសយើងដែលនៅក្រោមនឹមអាណានិគមនិយមបារាំង *ជិតមួយសតវត្សទៅហើយ ត្រូវមានអាយុរាប់រយសតវត្សទៅទៀត* ។ អស់លោកនៅចាំបានឬទេពួកសម្ពន្ធមិត្តបានសន្យាថា កាលណាសម្ពន្ធមិត្តឈ្នះសង្គ្រាម និងឱ្យ *ប្រទេសទន់ខ្សោយនឹងប្រទេសតូចតាចបានឯករាជ្យផងដែរ* ។ ពាក្យសន្យារបស់សម្ពន្ធមិត្តនោះប្រទេសអង់គ្លេស គេបានអនុវត្តន៍ហើយ *នៅប្រទេសហុល្លង់គឺនិងប្រទេសបារាំងសែស មិនព្រមអនុវត្តន៍តាមពាក្យសន្យាសោះ* ។ *ករណីយកិច្ចរបស់យើងត្រូវតែយកប្រទេសឥណ្ឌា និង ប្រទេសភូមាមកធ្វើជាមូលមូលដ្ឋាន បង្ខំឱ្យបារាំងអាណានិគមនិយមអនុវត្តន៍* តាមផងដែរ ។ ខ្ញុំមានជំនឿ

ជឿជាក់ច្បាស់ថាសព្វថ្ងៃនេះ ប្រទេសវៀតណាម, ប្រទេសលាវ និងប្រទេសអាល់ហ្សេរីជាដើម គេទាមទារឯករាជ្យគ្រប់គ្នាយ៉ាងនេះ អាទិតមនិយមបារាំងមិនអាចខាឃាំងមិនឱ្យឯករាជ្យដល់ ប្រទេសយើងបានទេ *បើយើងហើយទាមទារដោយស្មិតស្មាញពួតដ់តែបានដូចគេដូចឯងដែរ* ។ តាមខ្ញុំពិនិត្យមើលទៅប្រទេសដែលស្រេកឃ្លានឯករាជ្យ វិស័យដូចជាទឹកហូរចុះមក ច្រើនពីលើភ្នំពិតជាបាក់ធ្លាយទំនប់នោះមិនខានឡើយ ។ បើអស់លោកមានជំនឿដូចខ្ញុំដែរ ត្រូវតែយើងខំពុះពារមួយកំរិតថែមទៀត ក្នុងការពុះពារនេះ *បើមិនស្លាប់អស់លោកពិតជាស្លាប់ខ្ញុំ ខ្ញុំមិនចូលចិត្តស្លាប់ដេកលើពូកទេ ខ្ញុំចូលចិត្តស្លាប់ នៅចំពោះមុខបច្ចាមិត្ត ហើយខ្ញុំមិនចូលចិត្តយកដំបូកមកដេកធ្វើខ្នើយទេ ខ្ញុំចូលចិត្តស្លាប់នៅកណ្ដាលក្រុង ចំពោះមុខបច្ចាមិត្តរបស់ខ្ញុំតែម្ដង* ។

## វគ្គទី ៣

លោក អៀវ.កើស បានបរិយាយអំពីលទ្ធិប្រជាធិបតេយ្យឱ្យសមាជិកគណៈបក្សប្រជាធិបតេយ្យស្តាប់ក្នុងពេលប្រជុំសម្ងាត់ មុនចូលកាន់រដ្ឋសភា ដូចតទៅនេះ :

អស់លោកគ្រប់រូប ត្រូវជ្រាបថា លទ្ធិប្រជាធិបតេយ្យមានអត្ថន័យគម្ពីរភាពជ្រៅឆ្ងាយទូលាយណាស់ វិស័យដូចទឹកសមុទ្រ ម្ល៉ោះហើយខ្លួនខ្ញុំក្តី អស់លោកគ្រប់គ្នាក្តី មិនយល់នូវអត្ថន័យ លទ្ធិប្រជាធិបតេយ្យបានសព្វគ្រប់ទេ ។ ប៉ុន្តែខ្ញុំសូមសង្ខេបសេចក្តីជាមូលដ្ឋាននៃលទ្ធិនេះ នៅលើមតិភាគច្រើន មតិភាគច្រើនពុំមែនសុទ្ធតែត្រូវឥតខ្ចោះទេ ជួនកាលៈទេសៈខ្លះខុសទៅវិញក៏មានដែរ ។ ប៉ុន្តែគេសន្យាថា ទុកមតិភាគច្រើនជាមតិត្រឹមត្រូវនោះ *ព្រោះមតិភាគតិចគ្មានមូលដ្ឋាន និងទ្រទ្រង់រដ្ឋាភិបាលជាដំណាង* ប្រជាជាតិទេ បានជាគេសន្មត់ឱ្យមតិភាគតិចចាញ់ មតិភាគច្រើន ។ នេះហើយជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ។

លទ្ធិប្រជាធិបតេយ្យ ត្រូវអាស្រ័យទៅលើការពឹងផ្អែកប្រជែងប្រណាំងគ្នា ក្នុងការសម្តែងយោបល់នៃអ្នកដំណាងរាស្ត្រលើវេទិកា *អ្នកដំណាងរាស្ត្រណាមានមធ្យោបាយច្រើន ចេះនិយាយឱ្យអ្នកដំណាងរាស្ត្រឯទៀតចាប់ អារម្មណ៍មតិអ្នកដំណាងរាស្ត្រនោះ ពិតជាមានប្រសិទ្ធភាពក្នុងពេលវិនិច្ឆ័យ* ។ គូប្រជែងប្រណាំងមិនត្រូវខូចចិត្តទេ ត្រូវទទួលស្គាល់សមត្ថភាពរបស់ខ្លួនថាមកពីខ្លួនខ្វះ

មធ្យោបាយ មិនបានរិះគិតនូវសុខទុក្ខរបស់រាស្ត្របានសព្វគ្រប់ បានជាមតិរបស់ខ្លួនចាញ់គេ ។

បើដូច្នេះត្រូវរិះរកមធ្យោបាយសាជាថ្មីឡើងវិញ ដើម្បីជ័យជំនះក្នុងថ្ងៃក្រោយ ខែក្រោយ ឆ្នាំក្រោយទៅទៀត សូមកុំអស់សង្ឃឹមឱ្យសោះ ។ ខ្ញុំសូមបញ្ជាក់ថា ការប្រជែងប្រណាំងគ្នានេះ ពុំមែនជាការឥតប្រយោជន៍ទេមានប្រយោជន៍សំខាន់ណាស់ *ព្រោះក្នុងគោលគំនិត ដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់វឌ្ឍនភាពនិងសុភមង្គល* ។ អស់លោក តាមធម្មតា អ្នកប្រឆាំងចាញ់គេក្នុងផ្លូវគំនិតតែងមានចិត្តគុំគួនបៀមទុក មិនព្រមយកគំនិតមកប្រឆាំងទៀតសេចក្តីគុំគួន សន្សំបានច្រើនហើយ ថ្ងៃក្រោយមនុស្សនោះឯងពិតជាក្លាយខ្លួន*ទៅជាអ្នកកាន់អំណាចលទ្ធិផ្តាច់ការទៅវិញ* ។ ដល់ពេលខ្លួនប្រមូលយក អំណាចបានអួតអាងមួយថ្នាក់ទៀតថា *ខ្លួនកាន់លទ្ធិប្រជាធិបតេយ្យពិសេស* ដូចលោកហ៊ុត្លែរ៍ នាយករដ្ឋមន្ត្រីប្រទេសអាល្លឺម៉ាញ ហើយតាំងចោទប្រកាន់គេឯងថាគេធ្វើឱ្យខូចនយោបាយខ្លួន ឱ្យមនុស្សដុតរដ្ឋសភាចោល ហើយចោទអ្នកដំណាងរាស្ត្រថា ដុតរដ្ឋសភាទៅវិញ ។ យកអ្នកដំណាងរាស្ត្រដែលមានយោបល់ ផ្ទុយនឹងខ្លួនទៅសម្លាប់ចោលអស់ ដូចសុភាសិតបារាំងថា *មុនសម្លាប់ឆ្កែចោលត្រូវតែចោទថាឆ្កែនោះ វាឆ្កួតបើមិនដូច្នោះទេអ្នកផងគេចោទថា ម្ចាស់ឆ្កែឆ្កួតទៅវិញ* ។ នេះហើយដែលចាត់ទុកថា លទ្ធិផ្តាច់ការ *ជ្រៀតតាមលទ្ធិ ប្រជាធិបតេយ្យ* សូមអស់លោកប្រយ័ត្ន ។

# វគ្គទី ៤

លោក អៀវ.កើស តែងតែឱ្យឱវាទអ្នកដំណាងរាស្ត្រថា អស់លោកត្រូវតែមានសេចក្តីស្អាតស្អំជាមូលដ្ឋាន ព្រោះអំពើពុករលួយ *ដែលយើងបានប្រព្រឹត្តក្នុងទីសម្ងាត់នោះ មកបិទត្រចៀក. បិទភ្នែក. បិទមាត់យើង បោមឃាត់ចិត្តគំនិតយើង មិនឱ្យយើងហ៊ានរិះគន់អ្នកប្រព្រឹត្តអំពើពុករលួយ ។ បើអ្នកដំណាងរាស្ត្រធ្លាក់ខ្លួនដូច្នេះហើយ សិទ្ធិដែលរដ្ឋសភាត្រូវត្រួតពិនិត្យ គណៈរដ្ឋមន្ត្រីអនុវត្តន៍ច្បាប់ត្រូវចប់ត្រឹមនេះដែរ* ។ ខ្ញុំទទូចសូមចិត្តអស់លោក ថាសូមកុំប្រព្រឹត្តអំពើមិនគប្បីឱ្យសោះ សូមកុំយល់ដោយភាន់ច្រឡំថា គ្មាននរណាដឹងថាយើងប្រព្រឹត្តអាក្រក់ទេ ពិតជាមានអ្នកដឹងមិនខានឡើយ គ្រាន់តែយូរនិងឆាប់ប៉ុណ្ណោះ *អ្នកដឹងនោះគឺនរណា អ្នកដឹងនោះគឺអ្នកសមគំនិតជាមួយនឹងយើងនោះហើយ បើមិនដូច្នោះទេ ខ្លួនយើងនេះឯង និយាយប្រាប់ប្រពន្ធឬកូន ប្រពន្ធឬកូនអាចយករឿងនោះទៅផ្សាយ រឿងនោះអាចក្លាយពីក្អែក មួយទៅជាក្អែកដប់នាំឱ្យខូចកិត្តិយស កិត្តិនាមយើងក្នុងអនាគតកាលពុំខានឡើយ* ។ បូរាណថាផោមក្នុងទឹកម្តេចក៏ស្អុយបាន មកពីខ្ញុំមានជំនឿយ៉ាងនេះ ហើយបានក្នុងមួយជាតិខ្ញុំនេះ ខ្ញុំមិនត្រូវការប្រាក់ *ក្រៅពីកម្លាំងដែលខ្ញុំរកបាន តាមផ្លូវសុចរិត* ។ លោក អៀវ.កើស បន្តទៅទៀតថា ក្នុងរបបលទ្ធិប្រជាធិប តេយ្យ ច្បាប់ក្តី. បទបញ្ជាក្តី សារាចរក្តី ត្រូវឱ្យមានន័យ *ស្របតាមគំនិតរដ្ឋធម្មនុញ្ញ* ។ រដ្ឋសភាជាតិអ្នក

បញ្ចេញឱ្យប្រើ រដ្ឋមន្ត្រីជាអ្នកអនុវត្តន៍តាម បើឃើញពលរដ្ឋប្រព្រឹត្តខុសត្រូវតែធ្វើ ត្រូវតែធ្វើទោស តាមច្បាប់តាមបទបញ្ជាតាមសារាចរ បើរដ្ឋមន្ត្រីមិនធ្វើទោស ទេពិតជាសេចក្តីអនុគ្រោះនោះ *ក្លាយខ្លួនទៅជាទំនៀមទម្លាប់ សំរាប់ជាតិមក ប្រឆាំងនិងមាគ៌ានយោបាយរបស់ជាតិគឺច្បាប់ទៅវិញ បើសមាជិករដ្ឋសភា បណ្តោយទៅទៀតច្បាប់ក្តីទេ* បញ្ញត្តិ, សារាចរក្តី អស់មាន ន័យហើយ លទ្ធិប្រជាធិបតេយ្យ *ត្រូវចប់តែប៉ុណ្ណោះឯង* ។

លោកអៀវ.កើស បានឱ្យឱវាទសមាជិករដ្ឋសភាថា ការធ្វើច្បាប់ត្រូវឱ្យ បានស្របតាមពលរដ្ឋស្រែកឃ្លាន បើខុសពីពលរដ្ឋស្រែកឃ្លាន មិនសូវមាន ប្រយោជន៍ទៅពលរដ្ឋទេ ឧទាហរណ៍ កាលមុនប្រជាធិបតេយ្យកាន់អំណាចវិទ្យុ *មានចំពោះតែជនជាតិបារាំង គ្មានសាយភាយដល់ទៅខេត្តស្រុក ឃុំផងទេ លោកអៀវ.កើសហៅលោកថុន.អ៊ុក* រដ្ឋមន្ត្រីក្រសួងឃោសនាការមកសួរថា លោកមាន មធ្យោបាយយ៉ាងណាខ្លះ អាចឱ្យវិទ្យុផ្សាយដល់ខេត្តស្រុកឃុំផងបានឬទេ លោក ថុន.អ៊ុក ឆ្លើយថាបាន លោកបញ្ជាថាបើដូច្នេះ ខ្ញុំពឹងផ្អែកលើលោកហើយ ។តាំងពី នោះមកវិទ្យុសាយភាយ រហូតដល់ចុងកាត់មាត់ញូកពេញរដ្ឋាណាចក្រ ស្របតាម សេចក្តីស្រែកឃ្លាន របស់ប្រជាពលរដ្ឋពិតមែន ។ ខ្ញុំសូមបញ្ជាក់ថា មធ្យោបាយ របៀបនេះ មានច្រើនណាស់កាលគណៈបក្សប្រជាធិបតេយ្យកាន់អំណាចជំនាន់ លោកអៀវ.កើស ។

# វគ្គទី ៥

*កាលលោកអៀវ.កើស ធ្វើជាប្រធានរដ្ឋសភានោះ ពេលចូលជំនុំតែងតែមានភ្នាក់ងារសម្ងាត់បារាំង មកស្តាប់យកពត៌មាន ទៅឱ្យអ្នករដ្ឋការបារាំងជារៀងរាល់ថ្ងៃ* ។ អ្នកដំណាងរាស្ត្រណាមានឧត្តមគតិស្នេហាជាតិយ៉ាងណា អ្នករដ្ឋការបារាំង *យល់នូវជម្រៅស្នេហាជាតិនោះទាំងអស់មានន័យ ថាសេចក្តីស្នេហាជាតិរបស់អ្នកដំណាងរាស្ត្រ នៅក្នុងកណ្តាប់ដៃអ្នករដ្ឋការ* បារាំងទាំងអស់ ។

ង៉ែត.ហៀន អ្នកដំណាងរាស្ត្រមណ្ឌលកណ្តោលជ្រុំ ទីរួមខេត្តកំពង់ចាម សូមស្នើចំពោះលោកប្រធានរដ្ឋសភាអៀវ.កើស ថា ដល់ពេលរដ្ឋសភាជាតិយើងស្នើសុំឯករាជ្យពីប្រទេសបារាំងហើយ ព្រោះព្រឹត្តិការណ៍សកលលោកដើរជឿនលឿនទៅមុខណាស់ហើយ ។ បើយើងទុកស្ថានការណ៍របៀបនេះតទៅទៀត យើងធ្វើការជូនជាតិមិនសូវបានប្រសិទ្ធិភាពទេ ហើយរាស្ត្រអាចរិះគន់យើងបាន ព្រោះពេលឃោសនា យើងបានសន្យានឹងរាស្ត្រថា កម្មវិធីយើងយក *ឯករាជ្យឱ្យបានជូនរាស្ត្រមុនអ្វីឯទៀតទាំងអស់* ។ លោកអៀវ.កើស បានឆ្លើយមកខ្ញុំវិញថា តាមយោបល់ខ្ញុំ បាក់ដូចជាមិនទាន់ដល់ពេលទេ ផ្លែឈើបើមិនទាន់ចាស់ទេ យើងបេះបន្ទំមុនកំណត់ពេល មានឱជារសមិនឆ្ងាញ់ទេ គួរទុកដល់ពេលវេលាសិនទៅ ។ បើតាមមតិខ្ញុំ ពេលនេះត្រូវទាមទារឱ្យបារាំង ដោះលែងមនុស្សនយោបាយជាតិយើងជាមុនសិនទៅល្អជាង ។ បើលោកមិនយល់ទាស់ទេ សូមលោកធ្វើញត្តិមួយ



ប៉ាច-ឈឺន រដ្ឋមន្ត្រីសេដ្ឋកិច្ច

សុំទៅរដ្ឋសភាជាតិឱ្យបញ្ចេញមតិ សុំ *ដោះលែងលោកប៉ាច.ឈឺន លោក ស៊ឹង.ង៉ុក ថាញ់ នឹងលោកប៊ូ.ហ៊ាង* វិញល្អជាង ព្រោះពេលនេះព្រះករុណាជិតយាងទៅប្រទេសបារាំងហើយ ខ្ញុំនិងយកញត្តិនេះទៅថ្វាយព្រះករុណា សូមជូនទៅលោកវ៉ាំងសង់អូរីយ៉ូល ប្រធានាធិបតីប្រទេសបារាំង ។ ខ្ញុំមានសេចក្ដីសង្ឃឹមជាច្រើនថា មុខជាបារាំងអនុញ្ញាតឱ្យពុំខានឡើយ កាលណាឥស្សរៈជនទាំងនោះ បានវិលត្រឡប់មកប្រទេសវិញ ចាំយើងរួបរួមកម្លាំងគ្នាទាមទារឯករាជ្យជាថ្ងៃក្រោយ ។ ក្នុងថ្ងៃនោះ ខ្ញុំបានធ្វើសេចក្ដីព្រាងញត្តិមួយ សូមឱ្យលោកជួយសម្រួលសេចក្ដី លុះដល់លោកសម្រួលសេចក្ដីហើយ បានប្រគល់សេចក្ដីញត្តិនោះមកខ្ញុំវិញ ខ្ញុំយកមកសរសេរជាត្រឹមត្រូវ ហើយខ្ញុំក៏យកទៅជូនលោក សុំឱ្យដាក់ទៅរដ្ឋសភា ដើម្បីពិចារណាបញ្ចេញមតិ លោកបានទទួលញត្តិនោះ យកទៅពិចារណាមើលហើយ ពិនិត្យមើលឃើញមានហត្ថលេខា ដែលមានចុះក្នុងញត្តិនោះតែខ្ញុំម្នាក់ឯង ។ លោកអៀវ.កើស បានប្រាប់ខ្ញុំថា គួរស្នើដល់សមាជិករដ្ឋសភាឯងទៀត សុំឱ្យចុះហត្ថលេខាជាមួយបានច្រើនគ្នាល្អជាង ខ្ញុំបានយកញត្តិនោះ ដើរសុំសមាជិករដ្ឋសភាឯទៀត ឱ្យចុះហត្ថលេខាបាន៨នាក់ថែមទៀត យកទៅជូនលោកសារជាថ្មី ទើបលោកចាត់ការឱ្យពិភាក្សារួចហើយរដ្ឋសភា បញ្ចេញមតិជាឯកឆន្ទ. សូមឱ្យរដ្ឋាភិបាលបារាំងដោះលែងអ្នកស្នេហាជាតិ មានលោក ប៉ាច.ឈឺនជាដើម ហើយយកញត្តិនោះ ទៅថ្វាយព្រះករុណា ។ លុះដល់ព្រះអង្គយាងទៅប្រទេសបារាំង ព្រះអង្គយកញត្តិនោះ ទៅជូនលោកវ៉ាំងសង់អូរីយ៉ូល ដល់ព្រះមហាក្សត្រយាត្រឡប់ប្រទេសកម្ពុជាវិញ បានប្រាប់លោកអៀវ.កើសថារដ្ឋាភិបាលបារាំង យល់សេចក្ដី

ស្នើនោះហើយ មនុស្សអ្នកទោសនយោបាយ មិនទាន់ឃើញវិលត្រឡប់មកប្រទេសវិញផង ។ ស្រាប់តែលោកអៀវ.កើស ហៅខ្ញុំង៉ែត ហៀន ឱ្យចូលទៅក្នុងការិយាល័យរបស់លោក ហើយលោកប្រាប់ខ្ញុំថា សេចក្ដីស្នើសុំឯករាជ្យរបស់លោកនោះ ខ្ញុំយកបញ្ហានេះទៅឱ្យគណកម្មការនាយកពិចារណា គេយល់ស្របតាមសេចក្ដីស្នើរបស់លោកនេះហើយ បើដូច្នេះ ចាំឱ្យគណរដ្ឋមន្ត្រី ស្នើទៅអ្នករដ្ឋការបារាំង ។ បើអ្នករដ្ឋការបារាំងយល់ស្របដែរ ចាំយកបញ្ហានោះមកដោះស្រាយ ។ រំលងមកដោយស្មានប្រហែលបួនដប់ថ្ងៃ មានមិត្តខ្ញុំម្នាក់ឈ្មោះចឺថោងវ៉ាន់ ធ្វើការនៅជប់ បានមកជួបនឹងខ្ញុំដល់រដ្ឋសភាជាតិ ហើយប្រាប់ខ្ញុំថា លក្ខន្តិកឯករាជ្យបារាំងធ្វើរួចស្រេចទៅហើយ ខ្ញុំបានឃើញសេចក្ដីព្រាងលក្ខន្តិកនោះផង ។ នៅក្នុងការិយាល័យលោកចាងហ្វាងចំការកៅស៊ូជុប ។ ខ្ញុំបាននាំដំណឹងនេះទៅជំរាបលោកអៀវ.កើស តាមដំណើរព្រឹត្តិការលោកមានប្រសាសន៍ថា ប្រហែលជាគេប្ដូរយោបល់គ្នា រវាងជាតិគេនិងជាតិគេទេ ។ ខ្ញុំសូមបញ្ជាក់ជូនលោកថា បើតាមសំដីចឺ ថោង.វ៉ាន់ លក្ខន្តិកឯករាជ្យនោះគ្មានតម្លៃដល់ជាតិយើងទាល់តែសោះឯករាជ្យមានតែឈ្មោះ ។

## វគ្គទី ៦

បន្ទាប់ពីនោះមកស្រាប់តែមាន គណកម្មការចម្រុះមួយមានសមាជិករដ្ឋមន្ត្រីខ្លះ, សមាជិករដ្ឋសភាខ្លះ, ចាត់អ្នករដ្ឋការបារាំងខ្លះ មកចចារលក្ខន្តិកឯករាជ្យនៅបន្ទប់មួយដោយឡែកក្នុងរដ្ឋសភា ។ ខ្ញុំបញ្ជាក់ថា ខាងរដ្ឋសភា មានសមាជិករដ្ឋសភា តែប្រធានគណកម្មការទេ ដែលត្រូវចូលរួមប្រជុំ សមាជិកឯទៀតគ្មានសិទ្ធិចូលរួមប្រជុំផងទេមានភ័ព្វសំណាងតែខ្ញុំម្នាក់ឯង ព្រោះខ្ញុំង៉ែត.ហៀន ពុំមែនប្រធានគណកម្មការទេ ប៉ុន្តែខ្ញុំជាអ្នកផ្តើមគំនិតស្នើបញ្ហាឯករាជ្យនោះ លោក អៀវ.កើស ចាត់ខ្ញុំជាម្ចាស់បញ្ហា ត្រូវតែមានសិទ្ធិចូលប្រជុំផងដែរ ។ ហើយលោក អៀវ.កើស សូមឱ្យខ្ញុំទៅរាយការណ៍ជំរាបលោករាល់ថ្ងៃប្រជុំដើម្បីឱ្យលោកបានជ្រាបផង ។ ចាប់តាំងពីថ្ងៃនោះមក មានការចំឡែកមួយគួរឱ្យឆ្ងល់ណាស់ ភ្នាក់ងារសម្ងាត់បារាំង តាមលោកអៀវ.កើស និងខ្ញុំជាប់ជានិច្ច អ្នកដំណាងរាស្ត្រឯទៀតគ្មានឃើញ ធ្វើដូច្នេះផងទេ ។ លោក អៀវ.កើស សួរខ្ញុំថា លោកខ្លាចឬទេ ខ្ញុំឆ្លើយជំរាបទៅលោកវិញថា *ខ្ញុំគ្មានគក់ស្លុតបន្តិចសោះទេ* ខ្ញុំដឹងខ្លួនមុនរួចទៅហើយ ថានរណាហ៊ានស្នើសុំឯករាជ្យនោះអ្នកនោះហើយទទួលបាបគ្រោះមុនគេដូចលោក *ស៊ឹម.វ៉ា ស្នើសុំលទ្ធិប្រជាធិបតេយ្យដូច្នេះដែរ* ។

លោក អៀវ.កើស ឆ្លើយមកខ្ញុំវិញថា ខ្ញុំសូមសរសេរឧត្តមគតិលោក

ហើយ ហើយនិយាយតទៅទៀតថា *អ្នកណាដឹងច្រើន វិស័យដូចកាំបិតមុត មែន ប៉ុន្តែបើនៅក្នុងស្រោមជាការឥតប្រយោជន៍ទេ ឯសំខាន់ត្រង់ហ៊ាន យកកាំបិតនោះមកប្រើការ នេះយ៉ាងណា វិជ្ជាយ៉ាងនោះដែរ* ។

លោកអៀវ.កើស និយាយនេះ លើកទឹកចិត្តខ្ញុំបានមួយកំរិតយ៉ាងខ្ពស់ ថែមទៀត *នាំឱ្យខ្ញុំមានសេចក្តីក្លាហានទ្វេមួយជាពីរ* ដល់ថ្ងៃក្រោយខ្ញុំឃើញភ្នាក់ងារសម្ងាត់បារាំងទៅយាមផ្ទះលោក អៀវ.កើស ខ្ញុំទៅទះស្មា ប្រាប់ថាសុំលោកទៅកត់លេខរថយន្តខ្ញុំ ខ្ញុំនេះហើយ ង៉ែត.ហៀន មកផ្ទះលោកអៀវ.កើស ដើម្បីចចារពីរឿងនយោបាយ *សូមលោកឯងទៅជំរាបចៅហ្វាយលោកឯងទៅ* ភ្នាក់ងារសម្ងាត់បារាំងលើកដៃសំពះខ្ញុំសូមទោសថា ខ្ញុំធ្វើតែតាមបង្គាប់ពីលើទេ ។ ពិតជាសំដីនេះដឹងដល់លោកគុម្មសៀពុំខានឡើយព្រោះខ្ញុំចង់ឱ្យឮដល់ថា ខ្មែរមិនខ្លាចបារាំងទេត្រូវឈប់ប្រើបែបសំឡុតកំញើញទៅ ។

# វគ្គទី ៧

លុះគណកម្មការចម្រុះពិនិត្យ សេចក្តីព្រាងលក្ខន្តិកឯករាជ្យរួចហើយ ស្រាប់តែមានសំបុត្រពីលោកអ្នកុម្មសៀជីវ៉ៃរ៉ម៉ុង អញ្ជើញលោកអៀវ.កើស និងអ្នកដំណាងរាស្ត្រ ៤នាក់ទៀត ឱ្យទៅជួបដើម្បីប្តូរយោបល់គ្នា ពីលក្ខន្តិកឯករាជ្យ ។ ក្នុងពេលជាបន្ទាប់មកទៀត លោកអៀវ.កើសអញ្ជើញជាអ្នកតំណាងរាស្ត្រ៤នាក់ ចចារគ្នាគ្មានចុះ *សម្រុងទាល់តែសោះ* ។ លោកអ្នកុម្មសៀសួរថា លក្ខន្តិកឯករាជ្យនោះ អ្នកឯងពេញចិត្តឬទេ លោកអៀវ.កើសឆ្លើយថា ចំពោះរូបខ្ញុំគ្មានពេញចិត្តទេ ដោយផែនដី*កូសាំងស៊ីន គ្មានឃើញក្នុងលក្ខន្តិកឯករាជ្យនោះផងទេ* ។ ដោយលក្ខន្តិកអ្នកុំនោះឯងធ្វើរួចស្រេចទៅហើយ បានយកមកឱ្យរដ្ឋាភិបាលខ្ញុំយល់ព្រមជាក្រោយ និងហៅថា *លិខិតសញ្ញារវាងគូភាគីដូចម្តេចកើត* តាមផ្លូវច្បាប់ លិខិតសញ្ញានីមួយៗ ត្រូវគូភាគី បញ្ចេញមតិទាំងអស់គ្នាទើបមានសេចក្តីយុត្តិធម៌ ។ ចំពោះរឿងនេះរដ្ឋាភិបាលរបស់ខ្ញុំគ្មានបានបញ្ចេញមតិជាមួយ នឹងរដ្ឋការបារាំងផងទេ រដ្ឋការបារាំងធ្វើសេចក្តីព្រាង រួចស្រេចទៅហើយ ទើបយកទៅឱ្យរដ្ឋាភិបាលខ្មែរពិនិត្យកែសម្រួល រដ្ឋាភិបាលមិនហ៊ានកែសម្រួល បានតាំងគណកម្មការចម្រុះ មានសមាជិករដ្ឋសភាឱ្យចូលរួមផង *ឃើញថាមិនបានស្របតាមគំនិតរដ្ឋធម្មនុញ្ញទេ* ។ តាមគំនិតរដ្ឋធម្មនុញ្ញ សមាជិករដ្ឋសភាគ្មាន

ការត្រូវចូលទៅហោយឡំ និងអ្នកកាន់អំណាច និតិប្រតិបត្តិទេ ត្រូវទុកអំណាចនោះឱ្យទៅខាងនិតិប្រតិបត្តិបញ្ចេញមតិ បានដោយសេរី ។ សមាជិករដ្ឋសភាមានសិទ្ធិគ្រាន់តែត្រួតពិនិត្យ *ក្នុងពេលបញ្ចេញសច្ចាប័ណ្ណតែប៉ុណ្ណោះ* បើប្រសិនអ្នកឯងយកលក្ខន្តិកៈឯករាជ្យនោះ ទៅសុំសច្ចាប័ណ្ណពីរដ្ឋសភា ចំពោះខ្លួនខ្ញុំម្នាក់ ក្នុងឋានៈជាអ្នកដំណាងរាស្ត្រ *ក្នុងមណ្ឌលក្រុងភ្នំពេញ ខ្ញុំសូមឱ្យសមាជិករដ្ឋ*សភាបដិសេធចោល ។ លោកជីវ៉ែម៉ុង ឆ្លើយមកលោកអៀវ.កើសវិញថា អ្នកឯងទាំង៥នាក់ ជាកូនសិស្សសាលាបារាំង ជាពួកអ្នកចេះដឹង យល់ដូច្នេះហើយ ប៉ុន្តែតាម*សេចក្តីអង្កេតរបស់ខ្ញុំ* ដែលបានទទួលពីអ្នករដ្ឋការ មានសមត្ថកិច្ចមកឃើញថាពីគ្រប់មជ្ឈដ្ឋាន មានអ្នកដំណាងរាស្ត្រជាដើម ក្នុងរដ្ឋសភាជាតិ ពេញចិត្តនិងលក្ខន្តិកៈឯករាជ្យនេះណាស់ ។

បើដូច្នេះ មិនអីទេ ចាំខ្ញុំស៊ើបអង្កេត រកសេចក្តីពិតតទៅទៀត គង់តែបានដឹងថា សមាជិករដ្ឋសភាភាគច្រើន *យល់តាមគំនិតអ្នកឯង ឬយល់តាមលក្ខន្តិក លក្ខន្តិកៈឯករាជ្យ ទៅអនាគតកាលយ៉ាងខ្លីនេះពុំខានឡើយ ចប់ការពិភាក្សា* រវាងលោក អូកុម្មសៀ និងលោកប្រធានរដ្ឋសភា លោកអៀវ.កើសវិលត្រឡប់ទៅកាន់រដ្ឋសភាជាតិវិញ ។

លោកអៀវ.កើសបានហៅខ្ញុំ ទៅជួបនិងលោកនៅការិយាល័យរបស់លោក តែពីរនាក់ដើម្បីពិគ្រោះគ្នាព្រោះខ្ញុំនេះជាម្ចាស់បញ្ហាឯករាជ្យ ដើម្បីដឹងការសម្ងាត់ ដូចជំរាបខាងលើ រួចលោកអៀវ.កើសប្រាប់ខ្ញុំថា លោកមានមធ្យោបាយយ៉ាងណាដែរ ក្នុងរឿងនេះ ខ្ញុំជំរាបទៅលោកវិញថាតាមសេចក្តីអង្កេតរបស់ខ្ញុំ

សមាជិករដ្ឋសភា ស្ទើរតែទាំងអស់ មិនយល់ស្របតាមលក្ខន្តិកនោះទេ លោកអៀវ កើស សួរបញ្ជាក់មកខ្ញុំវិញថា បើដូច្នេះ ម្ដេចក៏ភ្ជាក់ងារសម្ងាត់បារាំងថា សមាជិករដ្ឋសភាភាគច្រើន សប្បាយចិត្តនឹងលក្ខន្តិកឯករាជ្យនោះទៅវិញ ក្រែងការស៊ើបអង្កេតរបស់លោក មិនជិតដល់ ដូចគេទេដឹង ខ្ញុំឆ្លើយទៅវិញថា សូមលោកប្រធានចាត់ការ ឱ្យស៊ើបអង្កេតទៀតទៅ ថ្ងៃក្រោយមក លោក អៀវ កើសប្រាប់ខ្ញុំថា កុំថាឡើយតែបក្សប្រជាធិបតេយ្យ សូម្បីតែបក្សសេរីភាព ក្នុងរដ្ឋការមិនពេញចិត្ត នឹងលក្ខន្តិកឯករាជ្យនោះទាល់តែសោះ ខ្ញុំដឹងដំណើរនេះ ខ្ញុំមានសេចក្ដីពេញចិត្តយ៉ាងខ្លាំង ដើម្បីកុំឱ្យគេថាខ្ញុំនេះនិយាយកុហកគេ នាំអោយខូចកិត្តិយសរបស់ខ្ញុំ ។

## វគ្គទី ៨

រំលងពេលដោយស្មានប្រហែលជាមួយខែ មានសំបុត្រលោកកុម្មស្សៀជីវ៉ៃម៉ុង អញ្ជើញសមាជិករដ្ឋសភា ៨ រូបឱ្យទៅពិសារភោជនាហារ ពេលថ្ងៃរសៀលនៅផ្ទះលោកកុម្មស្សៀ ដើម្បីប្ដូរយោបល់គ្នា ពីរឿងលក្ខន្តិក ឯករាជ្យ ។

លោកអៀវ កើស ហៅខ្ញុំទៅជួបម្ដងទៀតប្រាប់ខ្ញុំថា ម្ដងនេះលោកអូកុម្មស្សៀ ហៅអ្នកដំណាងរាស្ត្រ យកចំពោះតែអ្នកដំណាងរាស្ត្រណាមិនចេះអក្សរបារាំង ចំនួន ៨ រូប ដើម្បីប្ដូរយោបល់គ្នា ពីរឿងលក្ខន្តិកឯករាជ្យ បើដូច្នេះគួរពាត់គ្នាយើង ឱ្យនរណាទៅខ្លះ ក្នុងពេលនោះ *ខ្ញុំម៉ែត.ហៀន សូមស្ម័គ្រ*

*ចិត្តមួយ* លោកអៀវ កើសបានឆ្លើយមកខ្ញុំវិញថា បើលោក ស្ម័គ្រចិត្ត ខ្ញុំមានសេចក្ដីត្រេកអរណាស់ព្រោះលោកជាម្ចាស់បញ្ហាឯករាជ្យផង ហើយយល់អត្ថន័យលក្ខន្តិកឯករាជ្យសព្វគ្រប់ផង ។ ខ្ញុំឆ្លើយតបទៅលោកវិញថាត្រូវមានអ្នកចេះភាសាបារាំង យ៉ាងតិចពីរនាក់ដើម្បីកុំឱ្យធីបកនោះ បកស្រាយបង្កាច់យើងបាន ។ លោកអៀវ កើសថា គួរយកអ្នកណាទៅ បកប្រែខ្ញុំថា ត្រូវយកលោកអ៊ុត.ស៊ាប១ លោកគង់.ចូ១ ព្រោះមនុស្សពីរនាក់នេះ *មានសេចក្ដីក្លាហាយ គួរឱ្យកក់ក្ដៅណាស់ ។ លោកអៀវ.កើស* បន្តទៅទៀតថា អ្នកទៅនោះត្រូវឱ្យមានសមាជិក*ប្រជាធិបតេយ្យខ្លះ សមាជិកសេរីភាពខ្លះ សមាជិកឯកធន្ទខ្លះ* ។

លុះស្របមតិគ្នាហើយ ទើបចេញទៅប្រជុំរដ្ឋសភាពេញអង្គ ហើយសូត្រសំបុត្រលោកអូកុម្មសៀជាភាសាបារាំងឱ្យស្ដាប់ ហើយបកប្រែភាសាខ្មែរទៀត ឱ្យសមាជិករដ្ឋសភាពិចារណា ហើយសួរបញ្ជាក់ថា លោកណាមានយោបល់ថ្លែង សូមអញ្ជើញឡើងលើវេទិការ ថ្លែងជូនសមាជិករដ្ឋសភាដើម្បីពិចារណា ។ ក្នុងពេលនោះលោកបាក់.ម៉ុងសេងអ្នកដំណាងរាស្ត្រ មណ្ឌលព្រែកពោធិក្នុងទីរួមខេត្តកំពង់ចាម បានថ្លែងថា តាមសាររបស់លោកអូកុម្មសៀ អញ្ជើញសមាជិក ទៅប្ដូរយោបល់គ្នា ពីរឿងលក្ខន្តិកឯករាជ្យនោះ យើងមិនត្រូវចូលទៅលាយឡំជាមួយផងទេ ព្រោះអ្នកដំណាងរាស្ត្រ ៨ នាក់ ពុំមែនដំណាងរដ្ឋសភាជាតិបានទេ បើទៅគ្រាន់តែជាអ្នកដំណាងឆន្ទៈរបស់ខ្លួនឯងតែប៉ុណ្ណោះ *គួរតែបដិសេធសាររបស់លោក អ្នកកុម្មសៀចោល ទុកជាអាសាឥតការ ហើយជូនដំណឹងទៅ លោកអូកុម្មសៀថា មតិភាគច្រើន មិនព្រមឱ្យអ្នកដំណាងរាស្ត្រកាន់អំណាចនីតិបញ្ញត្តិ ទៅ*

*លោយឡំនិងអ្នកកាន់អំណាចនិតិប្រតិបត្តិបានទេ ។*

ក្នុងពេលនោះខ្ញុំ រ៉ែត.ហៀន អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាលជ្រុំទីរួមខែត្រកំពង់ចាមឡើងទៅលើវេទិការថ្លែងថា តាមសេចក្តីក្នុងសាររបស់លោកអ្នកុម្មសៀ មានអត្ថន័យពីរយ៉ាង ។

១- សូមអញ្ជើញសមាជិករដ្ឋសភា៨នាក់ ទៅពិសារភោជនាហារ គឺទំ និងភេសជ្ជៈ នៅពេលថ្ងៃរសៀល បើសមាជិកសភាមិនទៅតាមសេចក្តីអញ្ជើញនោះ *ហាក់យើងគ្មានយល់ច្បាប់សុជីវធម៌ ។*

២- សូមប្តូរយោបល់ចំពោះលក្ខន្តិកឯករាជ្យ លោកអ្នកុម្មសៀអាចយល់បានថា សមាជិករដ្ឋសភា៨រូប ពុំមែនជាដំណាងរដ្ឋសភាបានទេ ប៉ុន្តែលោកចង់ដឹងមតិអ្នកដំណាងរាស្ត្រ ដែលមិនចេះភាសាបារាំងនោះ មានយោបល់កំពស់នយោបាយប៉ុណ្ណាដែរ តើស្របនិងអ្នកចេះភាសាបារាំងដែរឬទេ ព្រោះថ្ងៃលោកអ្នកុម្មសៀ បានស្ទង់មតិលោកប្រធានរដ្ឋសភា និងអ្នកដំណាងរាស្ត្រ ៤នាក់ទៀតរួចទៅហើយ ។ តាមយោបល់ខ្ញុំថា ត្រូវតែអ្នកតំណាងរាស្ត្រទាំង ៨នាក់ *ទៅតាមសេចក្តីអញ្ជើញរបស់លោកអ្នកុម្មសៀ* ហើយអ្នកតំណាងរាស្ត្រនីមួយៗត្រូវតែហ៊ានបញ្ចេញមតិ ឱ្យ*អ្នកតំណាងរដ្ឋាភិបាលបារាំងយល់ឆន្ទៈរបស់ខ្លួន ជាអ្នកតំណាងរាស្ត្រ* ខ្ញុំសូមដកលស់សាររបស់លោក អ្នកុម្មសៀ ទុកជាបានការ ។ លុះប្តូរយោបល់គ្នាអស់ពេលយ៉ាងយូរ មតិរបស់សមាជិកបែកជាពីរ ដូចខាងលើដែលទើបលោកប្រធាន ដាក់ឱ្យសមាជិករដ្ឋសភាវិនិច្ឆ័យ យកតាមសម្លេងភាគច្រើន ។ សមាជិករដ្ឋសភា បានអនុមត្តិថា *ត្រូវតែទៅតាមសេចក្តីអញ្ជើញរបស់លោក*

*អ្នកុម្មសៀ* ។ លោកប្រធានមានប្រសាសន៍បន្តទៅទៀតថា បើដូច្នេះលោកណា ដែលមិនភាសាបារាំង លោកស្ម័គ្រចិត្តទៅ សូមលើកដៃឡើង ក្នុងពេលនោះ មានអ្នកស្ម័គ្រចិត្តតែម្នាក់គត់ *គឺខ្ញុំ ម៉ែត.បៀន* លោកអៀវ.កើស ឱ្យចុះឈ្មោះក្នុងក្ការ បៀន ក្រៅពីនោះមករកអ្នកស្ម័គ្រទៀត គ្មានបានទាល់តែសោះ ។ លោកប្រធានរដ្ឋសភា ប្រកាសតទៅទៀតថា នៅខ្វះតែ៥នាក់ទៀត សូមបញ្ជាក់ថា អ្នកតំណាងពស្ត្រពីរនាក់ទៀតនោះ គួរយកលោក *គង់.ធូ១ និងលោក អ៊ុក.ស៊ាប១* ឱ្យទៅជួយស្តាប់ផងដែរ ខ្លាចគេបកប្រែខុស នាំឱ្យវិប្បឡាស់សេចក្តី បើដូច្នេះបានអ្នកតំណាងរាស្ត្រ ៣នាក់រួចហើយ ត្រូវបោះឆ្នោតទៅវិញទៅមក ចំពោះតែអ្នកតំណាងរាស្ត្រណា ដែលមិនចេះភាសាបារាំង បើបោះឆ្នោតឆ្លើយទៅតំណាងរាស្ត្រណាភាគច្រើនតាមលទ្ធិប្រជាធិបតេយ្យ *ត្រូវតែអ្នកតំណាងរាស្ត្រនោះ បំរើឧត្តមគតិលទ្ធិប្រជាធិបតេយ្យ* លុះបោះឆ្នោតទៅបានលើអ្នកតំណាងរាស្ត្រ៥នាក់ ខ្ញុំសូមអភ័យទោស ព្រោះចាំឈ្មោះមិនអស់ ប៉ុន្តែបើចង់ដឹងការពិត សូមមើលសេចក្តីកត់ហេតុរដ្ឋសភា និងឃើញឈ្មោះ អ្នកតំណាងរាស្ត្រទាំងនោះហើយ ។

# វគ្គទី ៩

លុះដល់អ្នកតំណាងរាស្ត្រទាំង ៨នាក់ ទៅដល់ផ្ទះលោកអ្នកឧកញ៉ាសៀ លោកអ៊ុត.ស៊ាប និងលោកគង់ចូ រាយការណ៍ប្រាប់លោកជីវ៉េម៉ុង តាមដំណើរការ ដូចជំរាបពីដើមរួចមកហើយ ។ លោកអ្នកឧកញ៉ាសៀ សម្តែងសេចក្តីរាប់អានយ៉ាងរាក់ទាក់ណាស់ អញ្ជើញភ្ញៀវ ឱ្យពិសារទំ និងស្រាសម្ប៉ាញជាមួយលោកបណ្ដើរ សួរសាវតាជាតិនិងវិជ្ជាជីវៈ ពីអតីតកាល មុនមកធ្វើតំណាងរាស្ត្របណ្ដើរ លុះបានយល់សព្វគ្រប់ហើយ ។ ទើបសួរយោបល់ម្នាក់ម្តងថា បានមើលសេចក្តីព្រាងច្បាប់លក្ខន្តិកឯករាជ្យ ដែលរដ្ឋាភិបាលបោះជូន សមាជិករដ្ឋសភា ពិនិត្យហើយឬនៅ អ្នកតំណាងរាស្ត្រទាំងអស់ឆ្លើយថា បានមើលរួចហើយ យល់សេចក្តីសព្វគ្រប់អស់ហើយ ។ ខ្ញុំសូមបញ្ជាក់ថា: ពេលនោះនាទីអ្នកបកប្រែភាសា *ត្រូវធ្លាក់ទៅលើលោកអ៊ុត.ស៊ាប និងលោកគង់ ចូទាំងស្រុង* ព្រោះចឹបកខាងបារាំង មកប្រែមិនរួចព្រោះពាក្យជ្រៅពេក ទើបប្រគល់អំណាចមកលោកទាំងពីរនេះទៅវិញ ។ ចាប់មុនដំបូង លោកអ្នកឧកញ៉ាសៀចចារនឹងលោកសម ញ៉ានមុនគេ សួរលោកសម ញ៉ានថាសេចក្តីព្រាងលក្ខន្តិកឯករាជ្យនេះ អ្នកឯងមិនពេញចិត្តត្រង់ណាខ្លះ លោកសម ញ៉ានឆ្លើយថា: មិនឃើញមានផែនទី *ដែនដីកូសាំងស៊ីន ចូលក្នុងលក្ខន្តិកឯករាជ្យនោះផង* គួរតែបញ្ចូលដែនដីកូសាំងស៊ីន មកក្នុងលក្ខន្តិកឯករាជ្យនេះផង ព្រោះដីនោះ ជាដីរបស់ខ្មែរ ខ្មែរបាត់ដើររបស់ខ្លួនមួយភាគទៅហើយ ។ លោកអ្នកឧកញ៉ាសៀ

ឆ្លើយថា រឿងនេះ ទុកទៅពេលក្រោយ រដ្ឋាភិបាល មិនភ្លេចទេ បាន*សន្យានឹងខ្មែរ ដោយលាយលក្ខណ៍អក្សរថា ឱ្យខ្មែរមាន*ប្រៀបជាងខាងយួន ព្រោះរដ្ឋាភិបាលខ្មែរ គ្មានវាយបារាំងដូចយួនទេ ។

បន្ទាប់នោះមកទៀត ត្រូវវេនខ្ញុំម៉ែត.ហៀន អ្នកតំណាងរាស្ត្រមណ្ឌល កណ្ដាលជ្រុំ ទីរួមខេត្រកំពង់ចាម ត្រូវចចារជាមួយលោក អូកុម្មសៀ លោក អូកុម្មសៀសួរថា ចុះលោកឯណោះយល់ឃើញយ៉ាងម្ដេចដែរ ចំពោះលក្ខន្តិកឯក រាជ្យ ប្រទេសកម្ពុជា សូមនិយាយទៅមើល ខ្ញុំម៉ែត ហៀន ឆ្លើយថា តាមការ ពិនិត្យរបស់ខ្ញុំ លក្ខន្តិកឯករាជ្យប្រទេសកម្ពុជា *មាត្រា ១ ប្រទេសបារាំងទទួល ស្គាល់ឯករាជ្យប្រទេសកម្ពុជាឃើញថា ជាការប្រសើរណាស់ហើយ ប៉ុន្តែមាត្រាជាំ លំដាប់លំដោយមកទៀត ទាញយកអំណាចពីមាត្រាទី ១ អស់មួងបន្តិចៗ រហូត ដល់មាត្រាទី ១ ឥតមានតម្លៃអ្វីទាល់តែសោះ* បាត់ពាក្យថាឯករាជ្យទៅហើយ ។ ព្រោះពាក្យថាឯករាជ្យមានន័យថា រដ្ឋការតែមួយ ឯលក្ខន្តិកនេះបញ្ជាក់បង្ហាញឱ្យ ឃើញថា *មានរដ្ឋការដល់ទៅពីរគឺអ្នករដ្ឋការខ្មែរផង អ្នករដ្ឋការបារាំងផង មិនបាន ស្របតាមពាក្យថាឯករាជ្យ* ។ លុះលោកអ៊ុត-ស៊ាប បកប្រែស្រាប់តែឃើញអូកុម្ម សៀ *ផ្លាស់ទឹកមុខស ទៅជាក្រហមទៅវិញ* ហើយទឹកមុខបង្ហាញឱ្យឃើញថា មាន ការអាក់អន់ចិត្ត ចំពោះមកលើរូបខ្ញុំយ៉ាងខ្លាំង ។ លោកអូកុម្មសៀ ឆ្លើយតបមកខ្ញុំ វិញថា ខ្ញុំសូមប្រាប់អ្នកឯង ដោយស្មោះត្រង់ទៅ *ចុះបារាំងបានធានារ៉ាប់រងចំពោះ អនិកជនជាតិចិន កាលដែលចិនមកដកអាវុធពីជនជាតិជប៉ុន កាលចាញ់សង្គ្រាម លោកលើកទី ២* បានជាអ្នករដ្ឋការបារាំង ទុកអំណាចខ្លះ ដើម្បីរក្សាអនិកជនជាតិ

ចិន *កុំឱ្យខុសពីសិទ្ធិសញ្ញា រវាងជនជាតិចិន* និងបារាំង តើអ្នកឯងយល់ដូចម្ដេចទៅវិញ ។

ខ្ញុំឆ្លើយតបទៅវិញថា កាលណោះប្រទេសខ្មែរ នៅក្រោមអំណាចប្រទេសបារាំង បារាំងចាត់ការដូចម្ដេចចេះតែបានប៉ុន្តែឥឡូវនេះ បារាំងបានឱ្យឯករាជ្យមកប្រទេសខ្មែរហើយ *កិច្ចសន្យាឯករាជ្យលើកក្រោយនេះ អាចបដិសេធកិច្ចសន្យាលើកមុន ដោយស្វ័យប្រវត្តិបាន* ។ ស្រាប់តែលោកអូកុម្មសៀ សួមបញ្ជាក់ខ្ញុំម្ដងទៀតថា បើឪពុកអ្នកឯងជំពាក់បំណុលគេ ដល់ឪពុកអ្នកឯងស្លាប់ទៅអ្នកឯង *តេចមិនសងបំណុលគេឬដូចម្ដេច* ខ្ញុំឆ្លើយតបទៅវិញថា តាមច្បាប់កូនអ្នកស៊ីមតិកឪពុក *ត្រូវតែសងបំណុលគេហើយ* លោកអូកុម្មសៀបញ្ជាក់ រឿងនេះក៏ដូច្នោះដែរ ។ ខ្ញុំឆ្លើយតបទៅវិញថា គ្មានច្បាប់បញ្ជាក់ថា ប្រទេសខ្មែរជាកូន*ប្រទេសបារាំងទេ លោកយករឿងអ្នកស៊ីមតិកនោះ មកប្រដូចមិនសមទេ* ។ ស្រាប់តែលោកអូកុម្មសៀជីរ៉ែម៉ុង ច្រឡោតខឹងបញ្ចេញកាយវិការ មិនគប្បីកំញើញខ្ញុំតែម្ដង ហើយជេរលខ្ញុំថា អ្នកឯងនៅក្មេងណាស់ ។ រួចលោកសួរមកខ្ញុំម្ដងទៀតថា អ្នកឯងចង់បានឯករាជ្យ ដូចម្ដេចទៅវិញ ក្នុងពេលនោះ ខ្ញុំមិនឆ្លើយតប នៅស្ងៀមតែម្ដង លោកអូកុម្មសៀសួរហើយសួរទៀត ខ្ញុំឆ្លើយថា ខ្ញុំគ្មានសេរីភាព និងឆ្លើយតប ចំពោះសំនួរលោកបានទេ ។ ព្រោះលោកយកអំណាចមកប្រើទៅហើយ សូមបញ្ជាក់ត្រឹមណឹងចុះ ស្រាប់តែលោកអូកុម្មសៀ យកបារីមកឱ្យខ្ញុំជក់ ហើយគូសឈើគូសអុជឱ្យទៀត ម្ដងនេះឃើញស្រាយទឹកមុខ ពី*ក្របាមផ្លាស់ទៅជាសវិញ ហើយសើចញញឹមស្ងួត តាំងមាន*ប្រសាសន៍ថា ការជជែកគ្នា តែងតែ

ដូច្នេះហើយ សូមលោកកុំប្រកាន់ ធ្មេញក្នុងមាត់នៅតែដណ្ដំគ្នាដែរ សូមលោកឆ្លើយនឹងសំនួរខ្ញុំទៅ ។ ខ្ញុំឆ្លើយថា ក្នុងឋានៈខ្ញុំជាអ្នកតំណាងរាស្ត្រម្នាក់ ចង់បានឯករាជ្យ ឱ្យដូចប្រទេសឥណ្ឌា ឬប្រទេសភូមា ព្រោះឯករាជ្យប្រទេសទាំងពីរនោះមានឯកភាពយ៉ាងបរិបូរណ៍ ។ លោកអូកុម្មសៀថា *ប្រទេសអ្នកឯងមានពលរដ្ឋតែ៤លាន៥សែននាក់ ចង់បានឯករាជ្យ ដូចប្រទេសឥណ្ឌា មានពលរដ្ឋ៤០០លាននាក់ ប្រទេសភូមា*មានពលរដ្ឋ ៧០លាននាក់ ធ្វើដូចម្ដេចនឹងរកើត ។ ខ្ញុំឆ្លើយទៅថា *ប្រទេសស៊ិសមានពលរដ្ឋតិចជាងប្រទេសកម្ពុជាទៅទៀត ម្ដេចក៏គេរក្សាឯករាជ្យទៅកើត លោក*អូកុម្មសៀ ឆ្លើយថា ពលរដ្ឋប្រទេសអ្នកឯង យកទៅប្រដូចនិងប្រទេសស៊ិសម្ដេចកើត ។ ខ្ញុំឆ្លើយថា ប្រទេសខ្ញុំក្រោមអាណាព្យាបាលបារាំងជិតមួយសតវត្សហើយ *ត្រង់វិជ្ជាជីវៈពលរដ្ឋមិនស្មើប្រទេសស៊ិសនោះ ជាករណីយកិច្ចរបស់ប្រទេសបារាំង ជាអាណាព្យាបាល ។ តពីខ្ញុំទៅ*ទៀត អ្នកតំណាងរាស្ត្រទាំង ៥នាក់ ឆ្លើយរិតតែធ្ងន់ជាងខ្ញុំណាស់ទៅទៀត គ្រប់រូបទាំងអស់ ប៉ុន្តែពាក្យខ្លីៗទេ ទើបលោកអូកុម្មសៀបញ្ចប់ការពិភាក្សា ហើយបញ្ចប់សេចក្ដីថា ចាំខ្ញុំធ្វើពតិមានទៅជូន ឱ្យរដ្ឋាភិបាលបារាំងជ្រាប តាមដំណើរដែលយើងបាននិយាយគ្នារួចមកហើយ ដល់ម៉ោង ៥ ល្ងាច ទើបនាំគ្នាត្រឡប់មកកាន់រដ្ឋសភាវិញ ។ បានចូលទៅជូនពតិមានលោកអៀវ.កើស តាមដំណើរដូចបានជំរាបមកពីខាងដើម លោកអៀវ.កើសសូមសរសើរសមាជិករដ្ឋសភាទាំង ៨ នាក់ ។ រួចលោកសម្ដែងមតិផ្ទាល់ខ្លួនលោកថា លក្ខន្តិកឯករាជ្យនោះ បារាំងមិនហ៊ានយកមកឱ្យរដ្ឋសភាយើងបញ្ចេញមតិជាសច្ចាប័ណ្ណទេ ។ មុខជាគេប្រើមធ្យោបាយផ្សេងទៅវិញហើយ

ប៉ុន្តែដរាបណា តែខ្លះសូមសច្ចាប័ណ្ណពីរដ្ឋសភាជាតិ សន្និសញ្ញាក្តី អនុសញ្ញាក្តីគ្មានតម្លៃអ្វីទាល់តែសោះ តាមច្បាប់រដ្ឋធម្មនុញ្ញយើង ។

## វគ្គទី ១០

បន្ទាប់ពីនោះមកទៀត មានពាក្យចចាមអារាម លេចឮដល់រដ្ឋសភាថា បើរដ្ឋសភាមិនយល់ស្របតាមលក្ខន្តិកឯករាជ្យ ២៤៦នោះទេ ពិតជារដ្ឋការបារាំងចាប់ខ្លួនដំណាងរាស្ត្រទាំងអស់យកទៅកោះត្រឡាចហើយ ។ ពាក្យដូចខាងលើនេះ មានឥទ្ធិពលម្តងបន្តិច១ កាន់តែខ្លាំងឡើង១ នាំឱ្យអ្នកដំណាងរាស្ត្រដែលមានស្មារតីទន់ខ្សោយ មានសេចក្តីព្រួយចិត្តកាន់តែច្រើនឡើងដែរ ។ ប៉ុន្តែមានភាគតិចទេព្រោះលោកអៀវ.កើស អប់រំស្មារតី អ្នកដំណាងរាស្ត្ររៀងរាល់ថ្ងៃជានិច្ច ។ ពាក្យលោកអប់រំនោះតាមខ្ញុំចាំបានថា អស់លោកត្រូវប្រុងប្រយ័ត្នស្មារតីឱ្យនឹងនរកុំងាករេ ទៅតាមពាក្យឃោសនាអកុសល ។ តែអស់លោកងាករេ ប្រយោជន៍ជាតិនិងវិនាសអន្តរាយ ដោយស្នាដៃអស់លោកហើយ ឈ្មោះអស់លោកត្រូវមានចារទុកក្នុង*ប្រវត្តិសាស្ត្រ អ្នករៀនប្រវត្តិសាស្ត្រជាន់ក្រោយជេរត្មះតិះដៀលយើង*គ្មានពេលនឹងចប់ទេ ។ តាមធម្មតា តែយើងមានសេចក្តីស្មោះត្រង់ រកប្រយោជន៍ឱ្យជាតិពិតប្រាកដត្រូវតែជួបនឹងឧបសគ្គហើយ ។ ហើយលោកយករឿងមហិតព្ទះ

គន្ធី មកធ្វើឧទាហរណ៍ រួចប្រាប់ថាប្រទេសឥណ្ឌា បានឯករាជ្យបរិបូរណ៍ ព្រោះជនជាតិឥណ្ឌា ចេះរួបរួមគ្នាតវ៉ា ជាមួយនឹងលោកមហិតត្មះគន្ធីនេះឯង ខ្ញុំសង្ឃឹមថា ពេលនេះ *ជនជាតិយើងមិនចាញ់ជនជាតិឥណ្ឌាប៉ុន្មានទេ* ។ ខ្ញុំជឿយ៉ាងជាក់ច្បាស់ថា ប្រទេសធំៗ មានសហរដ្ឋអាមេរិក និងសហភាពសូវៀត ដែលជាប្រទេសមិនធ្លាប់ជិះជាន់គេ មុខជាមិនបណ្ដោលឱ្យប្រទេសឯទៀត ជិះជាន់គេក្នុងអនាគតបានឡើយ ។ បើបណ្ដាសេចក្ដីប្រកាសរបស់សម្ពន្ធមិត្រ ក្នុងពេលសង្គ្រាមលោកលើកទី ២ *នឹងក្លាយទៅជាពាក្យឥតមានន័យទៅហើយ* ។ ការអប់រំរបស់លោកនេះ អ្នកដំណាងរាស្ត្រមានសេចក្ដីក្លាហានមួយកំរិតយ៉ាងខ្ពស់ថែមទៀតលែងស្ដាប់ពាក្យឃោសនាអកុសលតទៅទៀតហើយ ។

គួរឱ្យអស្ចារ្យណាស់ ស្រាប់តែមានថ្ងៃមួយ អ្នកដំណាងរាស្ត្រម្នាក់ មកប្រាប់លោកជាផ្លូវការថា ថ្ងៃនេះអ្នករដ្ឋការបារាំង នឹងមកចាប់អ្នកដំណាងរាស្ត្រហើយ លោកអៀវ.កើស មិនជឿទាល់តែសោះ ដល់ម៉ោង៨ព្រឹកស្រាប់តែឃើញទាហានបារាំង បើករថយន្តដឹកទាហាន មានទាំងរទេះតង់ផង មកព័ទ្ធរដ្ឋសភាផ្ទង់កាំភ្លើងសំដៅមកលើរដ្ឋសភា ពីគ្រប់ទិសទាំងអស់ ។ ព្រឹត្តការណ៍នោះបានបង្ខំចិត្ត ឱ្យលោកអៀវ.កើស ជឿទៅវិញ លោកលើកយកបញ្ហានេះ មកដោះស្រាយភ្លាមៗ ជាបន្ទាន់ដូចមានតទៅនេះ :

ក្នុងពេលនេះ *លោកហៅប្រធានគណកម្មការជំនុំសម្ងាត់ ប្រើវិធីយាបថលេចដែកក្ដៅ* គ្មានពេលអង្គុយទេ ព្រោះមានឧបសគ្គកើតឡើងជាបន្ទាន់ ខ្ញុំពុំមែនជាប្រធានគណកម្មការ ឥតមានភ័ព្វសំណាង ចូលទៅរួមប្រជុំផងទេ ទៅនិយាយ

អប់រំអ្នកដំណាងរាស្ត្រខ្លះ ដែលស្លុតស្លន់ នឹងព្រឹត្តិការណ៍ថ្មី ដែលទើបនិងកើតឡើង ។

ខ្ញុំបំភ្លឺថា សូមអស់លោកទាំងអស់ កុំរត់ចេញទៅឱ្យសោះ ត្រូវនៅឱ្យនឹងមួយកន្លែង ចាំស្តាប់សេចក្តីសម្រេចពីអង្គប្រជុំ ក្នុងពេលនោះអ្នកដំណាងរាស្ត្រខ្លះចេញចូលបង្កន់ញឹកញយពេក ខ្ញុំសូមបញ្ជាក់ថា សូមអស់លោកកុំភ័យឱ្យហួសហេតុ ផ្លែព្រុសមិនដែលខាំទេ បើចង់ខាំមិនដែលព្រុសទេ ។ លុះប្រជុំគណកម្មាធិការចប់ សួរប្រធានគណកម្មការ គ្មាននរណាប្រាប់ដូចម្តេចសោះ ។

សមាជិករដ្ឋសភា តក់ស្លុតមួយកំរិតទៀត ស្រាប់តែលោកអៀវ.កើសឱ្យលេខដ្ឋារី មកហៅខ្ញុំតែម្នាក់ឯង ចូលកាន់ការិយាល័យរបស់លោក ខ្ញុំទៅដល់សួរលោកថា អង្គប្រជុំសម្រេចយ៉ាងណាទៅហើយ លោកមិនព្រមឆ្លើយមកខ្ញុំវិញទេ បែរមកសួរខ្ញុំវិញថា លោកជាម្ចាស់បញ្ហា មានមធ្យោបាយយ៉ាងណាដែរក្នុងរឿងនេះ ក្នុងពេលនោះខ្ញុំឆ្លើយភ្លាមជាបន្ទាន់ថា តាមយោបល់របស់ខ្ញុំ ត្រូវលោកប្រធាន *អញ្ជើញទៅសួរ លោកអ្នកឧកញ៉ាសៀវផាល់ថាលោកឱ្យទាហានរបស់លោកមកចាប់អ្នកដំណាងរាស្ត្រឬ ? ក្នុងពេលនោះ*ប្រធានទៅសួរត្រូវកំណត់លក្ខណ្ឌ បើហួសពីម៉ោង ១២ ត្រូវសន្និដ្ឋានថា អ្នករដ្ឋការបារាំងចាប់លោកប្រធាន ដូចលោកស៊ឹង.ង៉ុកថាន់ទៀតហើយ អ្នកតំណាងរាស្ត្រទាំងអស់ ត្រូវទៅទាំងអស់គ្នា ឱ្យអ្នករដ្ឋការបារាំងចាប់តែម្តង បើលោកអ្នកឧកញ៉ាសៀវឆ្លើយថា ឥតមានឱ្យចាប់ទេ ត្រូវលោកប្រធានវិញត្រឡប់មកវិញ ឱ្យបានទាន់ម៉ោង ១១ កុំខានឱ្យសោះ ។ លោកអៀវ.កើស យល់ស្របតាមមតិរបស់ខ្ញុំ បានអញ្ជើញទៅផ្ទះលោកអ្នកឧកញ៉ាសៀវជីរ៉ែ

ម៉ោង ភ្លាមមួយរំពេច ។ ក្នុងពេលនោះខ្ញុំសុំទៅជាមួយលោកផង លោកមិនយល់ព្រមឱ្យទៅទេ ដោយឱ្យខ្ញុំនៅរៀបរក្សាសេចក្តីក្លាហាន របស់សមាជិករដ្ឋសភាតទៅទៀត សេចក្តីក្លាហានរបស់សមាជិករដ្ឋសភា មិនបាច់ខ្ញុំរក្សាទៀតទេ ថែមទាំងក្លាហានយ៉ាងខ្ពស់មួយកំរិតថែមទៅទៀត ហើយអ្នកខ្លះ ជជែកគ្នាថា បើលោកប្រធានត្រូវរដ្ឋការបារាំងចាប់ លើកទី១ ត្រូវទៅពាក់ កណ្តាលលើកទី ២ ត្រូវទៅពាក់កណ្តាលទៀតហើយអ្នកខ្លះដណ្តើមតែទៅមុន ទៅលើកទី ១ អ្នកដំណាងរាស្ត្រខ្លះថាត្រូវទៅទាំងអស់តែម្តង បើអ្នករដ្ឋការបារាំងហ៊ានចាប់ពិតជាប្រទេសយើងនឹងបានឯករាជ្យយ៉ាងឆាប់ ១ ព្រោះរាស្ត្រមុខជាបះបោរពេញផ្ទៃប្រទេសហើយគ្មានខុសពីរឿងហូ-ឡុងចាប់គណរដ្ឋមន្ត្រី ប្រទេសឥណ្ឌូណេស៊ីយកទៅព្រោះចោលក្នុងកោះមួយនោះទេ ។ ការដែលអ្នកដំណាងរាស្ត្រ ជជែកគ្នានេះនៅចំពោះមុខភ្នាក់ងារសម្ងាត់បារាំងតែម្តងភ្នាក់ងារសម្ងាត់បារាំង ផ្លាស់ប្តូរវេនគ្នារត់យកពតិមាន ទៅប្រាប់ចៅហ្វាយរបស់ខ្លួន មានភ្នាក់ងារសម្ងាត់លោកអៀវ.កើស រត់មកប្រាប់ខ្ញុំថា គ្មានឃើញព្រឹត្តិកម្មអ្វីចំឡែកទេ នៅផ្ទះលោកអូកុម្មសៀនោះ ។ ខ្ញុំបណ្តេញភ្នាក់ងារឱ្យត្រឡប់ទៅវិញហើយប្រាប់ថាត្រូវចាំមើលឱ្យរួចសិន ក្រែងមានឧបសគ្គអ្វីកើតឡើង កាលបើឃើញលោកប្រធានឡើងរថយន្តត្រឡប់មកវិញ ទើបឧបសគ្គនោះផុតរលត់ ។ បានមួយសន្ទុះក្រោយមកភ្នាក់ងារសម្ងាត់ លោកអៀវ.កើស មកប្រាប់ខ្ញុំទៀតថា លោកប្រធានចុះដល់ថ្នាក់ក្រោយហើយ ខ្ញុំប្រាប់អស់លោកដំណាងរាស្ត្រថា. យើងទៅតាមលោកប្រធានទេ បើតាមខ្ញុំស្មានមួយសន្ទុះក្រោយមកម៉ោង ១១និង ៣០នាទី លោច

រថយន្តលោកប្រធាន មកដល់មុខរាំងអស់លោកអ្នកអ្នកដំណាងរាស្ត្រទះដៃស្រែកថា ជយោរដ្ឋសភា ។ រវល់តែអរនិងជ័យជំនះ ដោយសន្តិវិធី ងាកទៅរកអ្នកប្រាប់នោះរត់ទៅបាត់ហើយ លោកអ៊ុត.ស៊ាបថា តាមរកឱ្យឃើញយកមកវាយ ដូចពាក្យសន្យារបស់ខ្លួន ។ អ្នកដំណាងរាស្ត្រភាគច្រើនថា គេអ្នកប្រាប់នោះថា ពិតណាស់ព្រោះកងទ័ពបារាំង មកព័ទ្ធរដ្ឋសភាពិតមែន អ្នកមកប្រាប់នោះត្រឡប់ជាមានគុណទៅវិញ ប៉ុន្តែរឿងនោះមកពីយើង ដោះស្រាយទាន់ពេលវេលាមិនត្រូវខឹងនឹងអ្នកមកប្រាប់ទេ បើកុំអីកងទ័ពបារាំងចាប់បាត់ទៅហើយមិនត្រូវខឹងនឹងអ្នកប្រាប់ទេ ។ មធ្យោបាយបារាំងយ៉ាងនេះ ឱ្យយើងងាករេទៅតាមបំណងរបស់គេតែប៉ុណ្ណោះ ។

លុះលោកប្រធានត្រឡប់ដល់រដ្ឋសភាវិញ និយាយប្រាប់អ្នកដំណាងរាស្ត្រថា ខ្ញុំសួរលោកអូកុម្មសៀថា: *អ្នកឯងចង់ចាប់ពួកអ្នកនយោបាយពិតមែនឬទេ លោកអូកុម្មសៀឆ្លើយថាទេ លោកប្រធានសួរថា: បើអ្នកឯងមិនបញ្ជាឱ្យចាប់ទេ ហេតុម្តេចកងទ័ពអ្នកឯង ទៅព័ទ្ធរដ្ឋសភាខ្ញុំ មានទាំងរទេះគង់ទ័ផង ។ លោកអូកុម្មសៀឆ្លើយថា ដោយបានពត៌មានជាសម្ងាត់ថា ពួកឥស្សរៈបំរុងនឹងចូលមកវាយរដ្ឋសភា បានជាខាងកងទ័ព ធ្វើការសាកល្បងមើល* ។ លោកអៀវ.កើសសួរថា :

បើដូច្នោះមែន *ហេតុម្តេចក៏អ្នកឯងមិនប្រាប់ ឱ្យខ្ញុំដឹងជាមុនផង* លោកអូកុម្មសៀឆ្លើយថា *ឥឡូវនេះខ្ញុំបញ្ជាឱ្យដកទ័ពថយវិញហើយ* ។ លោកអៀវ.កើសបញ្ជាក់តទៅថា ម្តេចទៅអ្នកដំណាងរាស្ត្រ ៨នាក់ ដែលមកជូនយោបល់ខាង

ក្រោមនោះ មនុស្សអស់នេះ គេសម្តែងឆន្ទៈ ដោយសុទ្ធចិត្តរបស់គេតែម្តង ។ ខ្ញុំរិះរកមធ្យោបាយ ហៅពួកឥស្សរៈដែលប្រឆាំងនឹងរដ្ឋាភិបាលបារាំងឱ្យចូលមកវិញ ចំនួន ១០នាក់ អ្នករត់ទៅធ្វើឥស្សរៈ ប្រឆាំងនឹងបារាំង១០០នាក់ទៅវិញខ្ញុំរកមធ្យោបាយឱ្យចូលអ្នកឯងរកមធ្យោបាយឱ្យចេញ ។ *ចំណុចត្រង់នេះ បង្ហាញឱ្យឃើញថា* ជាតិខ្មែរចង់បានឯករាជ្យ ឱ្យប្រទេសជាតិ មិនស្តាយអាយុជីវិតទេ គួរតែលោកជាអ្នកដឹកនាំរដ្ឋាភិបាលបារាំង ធ្វើសេចក្តីរាយការណ៍ឱ្យរដ្ឋាភិបាលបារាំងជ្រាបផងទៅ ។

លោកអៀវ.កើស កំពុងតែដំណាលប្រាប់សមាជិករដ្ឋសភា កងទ័ពបារាំងបានដកថយអស់ពីផ្ទាល់ ជុំវិញរដ្ឋសភា ។ ស្រាប់តែរំលងពីរ បីថ្ងៃមក មានកម្មករម្នាក់មកចងក នៅលើដើមម៉ាក់ឃ្លឿ ខាងក្រោយការិយាល័យប្រធានរដ្ឋសភា ។ ក្នុងពេលនោះខ្ញុំង៉ែត ហៀន យល់សប្តិឃើញថា ខ្យល់ព្យុះមកពីទិសខាងជើងខ្លាំងណាស់ បក់រំលំរដ្ឋសភាដួល បាក់បែកមុខព្រហ្មទាំងបួន ជាកំពូលរដ្ឋសភាខ្ទេចលែងប្រើការកើតតែម្តង ។

ខ្ញុំយករឿងនេះជូនលោក នូ កន ចាស់ទុំអោយកាត់សប្តិខ្ញុំនោះអោយ ។ លោកនូ កន កាត់សប្តិនោះថា រដ្ឋសភាយើងមុខជាមានហេតុអ្វីយ៉ាងធំ ក្នុងអនាគតកាលមិនខានឡើយ ។ ឧបសគ្គដែលយើងមានរួចមកហើយនោះ មិនទាន់ចប់ទេ មុខជាមានហេតុក្រោយធំជាងនេះទៅទៀត ព្រោះប្រផ្នូលគ្មានឃើញថាល្អសោះ ។ មុខព្រហ្មបួននៅលើកំពូលរដ្ឋសភាគឺអ្នកកាន់អំណាចអង្គការរដ្ឋទាំងបួននោះហើយ ១- លោកអគ្គលេខាធិការនាយកគណៈបក្ស ។ ២- លោកប្រធានរដ្ឋសភា ។

៣- លោកនាយករដ្ឋមន្ត្រី ។ ៤- ព្រះមហាក្សត្រិយ៍ ។ រដ្ឋបុរសបួននាក់នោះពិតត្រូវរងគ្រោះលែងប្រើការកើត ។ មកដល់បច្ចុប្បន្នកាលនេះឃើញថា លោក អៀវ.កើស អគ្គលេខាគណៈបក្សនិងប្រធានរដ្ឋសភារងគ្រោះដល់ស្លាប់ ។ លើកទី ២ លោកស្វាយ.សួរប្រធានរដ្ឋសភា និងលោក ហុយ.កន្ធុលរងគ្រោះដោយរំលាយរដ្ឋសភា ។ លើកទី៣ ព្រះមហាក្សត្រិយត្រូវរត់ចោលប្រទេសព្រោះតែដើរតាមមាគ៌ានយោបាយបរទេសបារាំង មិនព្រមដើរតាមមាគ៌ានយោបាយរបស់ជាតិ ។

## វគ្គទី ១១

វំលងពីព្រឹត្តិការណ៍ខាងលើនោះមកទៀត មានការបើកកាស៊ីណូនៅផ្សារកណ្ដាល ដោយថវិកាជាតិមានវិបត្តិជាខ្លាំង ក្នុងរឿងបើកកាស៊ីណូ[១] លោក អៀវ.កើសប្រធានរដ្ឋសភាជាតិ មិនយល់ព្រមជាដាច់ខាត ។ លោកថ្លែងការណ៍ពន្យល់អ្នកដំណាងរាស្ត្រថា ល្បែងសុំសងជាមូលដ្ឋាន *នាំឱ្យសេដ្ឋកិច្ចជាតិ ជម្រុញប្រទេសជាតិ ទៅរកសេចក្ដីអន្តរាយទេ ។ ព្រោះអ្នកទៅលេងល្បែងនោះ គ្មានបានចម្រើនទេ ។ កូនត្រូវតែចាញ់ជាដរាប កូននោះគឺនរណា* មិនគឺជាពលរដ្ឋជាតិយើង

---

១- បើកកាស៊ីណូបីលើកហើយ ប្រទេសជាតិរងគ្រោះទាំងបីលើក ។ ទី១- បារាំងចាប់ស៊ឹង.ង៉ុកថាញ់ ។ ទី២-លោកអៀវ.កើសស្លាប់ ។ ទី៣-សម្ដេចសីហនុរត់ចោលប្រទេស ។ នេះជាការកត់សំគាល់របស់ខ្ញុំ ។

មេនោះគឺនរណា មិនគឺជនជាតិចិន ជាជនបរទេស រដ្ឋាភិបាលយកតុងបានពិតមែនហើយ ។ ប៉ុន្តែប្រាក់នោះ មិនអាចយកមកដោះស្រាយវិបត្តិថវិកាជាតិបានរហូតទៅទេ ។ អ្នកស្ម័គ្រចូលដេញយកកាស៊ីណូនោះ ពុំមែនគេជាមនុស្សល្ងង់ទេ គេធ្វើលេខឃើញចំណេញជាស្រេច បានជាគេហ៊ានចូលទៅដេញថ្លៃមានមធ្យោបាយផ្សេងទៀត មុខជារបួងលួងលោមរដ្ឋាភិបាលយើង ឱ្យលុះតាមមធ្យោបាយនោះ ខ្ញុំនិយាយពេលនេះមិនទាន់បានទេ ប៉ុន្តែបើរដ្ឋាភិបាល ជាប់ស្នេហ៍គេហើយ មុខជាវត្ថុបំណងរបស់គេបានសម្រេច ។ កាលណាវត្ថុបំណងរបស់គេបាចសម្រេច មានន័យថា គេបំបែរប្រាក់ដែលបំរុងចូល *ឃ្លាំងជាតិ ឱ្យចូលទៅឃ្លាំងគេវិញ* ។ *បើបកស្រាយ* សេចក្តីទៅឃើញថា រដ្ឋាភិបាលយើង មើលងាយរាស្ត្រលក់*រាស្ត្រឱ្យទៅមេកាស៊ីណូម្នាក់ថ្លៃតែ ៥សេនសោះក្នុងម្នាក់ៗ* ។ ខ្ញុំសូមបញ្ជាក់អស់លោកថែមទៀតថា ក្នុងរឿងនេះ មានស្រីជាតិខ្មែរម្នាក់មករកខ្ញុំដល់ផ្ទះ ហើយនិយាយថា សូមលោកប្រធានកុំជំទាស់ ខ្ញុំជូនទឹកតែ ៥០ម៉ឺនរៀល ។ ខ្ញុំនឹកអស់សំណើចក្នុងចិត្តថា អែយ៉ាគេឃើញខ្ញុំធ្វើប្រធានរដ្ឋសភា គេចង់មកទិញរាស្ត្រ ថ្លៃមួយរូបតែ ៥សេនទេតើ ខ្ញុំនិយាយប្រាប់ទៅស្រីនោះវិញថា មួយជាតិខ្ញុំនេះ ខ្ញុំស្អប់*ណាស់អំពើសំណូកដោយហេតុនេះហើយ បានជាខ្ញុំ*មិនធ្វើអ្នករដ្ឋការនឹងគេ ខ្ញុំចូលចិត្តរកទទួលទានប្រាក់ ខ្ញុំដែលរកបានដោយសុចរិត ។ ខ្ញុំនិយាយយ៉ាងនេះ ស្រីនោះក៏លាខ្ញុំចុះទៅផ្ទះវិញភ្លាម សូមលោកប្រយ័ត្ន មុខ*តែគេយកទិញស្មារតីអស់លោកទៀតហើយ* ។ *ចំពោះ*អស់លោកដំណាងរាស្ត្រ ខាងគណៈបក្សប្រជាធិបតេយ្យតែខ្ញុំពិនិត្យទៅឃើញ *មុខជាបណ្តាញចោលពីគណៈបក្សហើយ* ។ លោកប្រធានរដ្ឋសភាបន្តទៅ

ទៀតថា គេ*ធ្វើច្បាប់ដើម្បីគោរពតាម នេះមានច្បាប់ហាមឃាត់មិនឱ្យលេងល្បែងស៊ីសង ទៅរកមធ្យោបាយមកព្យួរច្បាប់មិនឱ្យ*ពលរដ្ឋគោរពទៅវិញ ព្រោះតែចង់បានប្រាក់ចូលថវិកាជាតិជនអរិយៈប្រទេសគេមើលមកឃើញថា ជនជាតិយើងអស់*មធ្យោបាយថ្លៃថ្នូរទៅហើយ ទាល់ច្រករបួតដប់ទៅនាំ* រាស្ត្រឱ្យលែងគោរពច្បាប់ទៅវិញ ចំណុចត្រង់នេះ ខ្ញុំអៀនខ្មាស់ណាស់ ។ មធ្យោបាយដែលយើងត្រូវរកប្រាក់ចូលថវិកាជាតិ មានច្រើនជាអនេក រាប់មិនអស់ ហេតុម្ដេចក៏យើងនាំគ្នាបើកកាស៊ីណូទៅវិញ ។

មធ្យោបាយនេះ ចំពោះខ្ញុំចាត់ទុកជាចោលម្សៀតបំផុត ព្រោះមធ្យោបាយនេះ *មិនខុសគ្នាពីអាប៉ោង១ដែល*មិនធ្វើលក់ ឱ្យកូនក្មេងលេងនោះទេ មិនបានប៉ុន្មានវា*បែកធ្លាយទៅវិញ* គ្រាន់តែល្អមើលតែមួយភ្លែតប៉ុណ្ណោះ មិនមានខ្លឹមសារអ្វី លើកស្ទួយជីវភាពពលរដ្ឋបានទេ ។

ថ្ងៃក្រោយមក រដ្ឋាភិបាលបើកកាស៊ីណូនៅផ្សារកណ្ដាល លោកអៀវ.កើសមិនសប្បាយចិត្តក្នុងរឿងនេះ ទាល់តែសោះបានហៅខ្ញុំម៉ែត.ហៀនទៅប្ដូរយោបល់គ្នាតែពីរនាក់ក្នុងការិយាល័យរបស់លោក លោកស្នើរខ្ញុំថាលោកមានយោបល់យ៉ាងដូចម្ដេចដែរ ក្នុងរឿងនេះ ខ្ញុំជម្រាបលោកថា សូមឱ្យរដ្ឋមន្ត្រីសមាជិកគណបក្សប្រជាធិបតេយ្យ សូមដកខ្លួនចេញពីរដ្ឋាភិបាលទៅ រដ្ឋាភិបាលនិងត្រូវរំលំហើយ ។ លោកអៀវ.កើស ប្រាប់ខ្ញុំវិញថាៈ តាមយោបល់ខ្ញុំ ត្រូវកោះហៅមកដេញដោល ព្រោះរដ្ឋាភិបាលធ្វើនយោបាយរំលោភលើច្បាប់ ។ ខ្ញុំជម្រាបលោកវិញថាបើដូច្នេះពិជាមានការបែកបាក់គ្នាហើយនាំឱ្យខូចឯកភាពជាតិ *យើង*

*កំពុងតែទាមទារឯករាជ្យផង នាំឱ្យបារាំងរឹតតែមើលងាយយើងថែមទៀត* ។ លោកអៀវ.កើស ថាការបែកបាក់នោះតែងតែមានជាធម្មតា ក្នុងរបៀបលទ្ធិប្រជាធិបតេយ្យដល់រដ្ឋាភិបាលកើតថ្មីមានឡើង ការបែកបាក់នោះ រលាយបាត់ទៅឯងទេ ។ សូមឱ្យខ្ញុំតាំងសំណួរដេញដោលទៅ ខ្ញុំប្រកែកមិនព្រមធ្វើសំណួរដេញដោលទើប *លោកហៅលោកឡាបលន់មកឱ្យធ្វើសំណួរដេញដោល* លុះលោកឡាប.លន់ធ្វើសំណួរដេញដោល ជូនរដ្ឋមន្ត្រីហើយ ដល់ថ្ងៃមកឆ្លើយនិងសំណួរដេញដោល ស្រាប់តែលោកនាយករដ្ឋមន្ត្រី យ៉ែម.សំបូរថ្លែងសេចក្ដីរំលាយរដ្ឋសភាតែម្ដងក្នុងនាមព្រះករុណាម្ចាស់ជីវិតលើត្បូង ខុសនិងច្បាប់រដ្ឋធម្មនុញ្ញពេញទី ដោយឥតសួរយោបល់ ពីប្រធានរដ្ឋសភាជាមុន ។ ក្នុងពេលនោះ ខ្ញុំជំរាបលោកប្រធានរដ្ឋសភាថា សូម*ឱ្យតាំងគណកម្មការតុលារដ្ឋធម្មនុញ្ញ បកស្រាយច្បាប់រដ្ឋធម្មនុញ្ញទៅបើឃើញថារំលាយរដ្ឋសភាខុសច្បាប់ ត្រូវនៅធ្វើការតទៅទៀត* បើឃើញថារំលាយនោះ ត្រឹមត្រូវហើយត្រូវទៅផ្ទះរៀងខ្លួន ។ លោកអៀវ.កើស ឆ្លើយមកខ្ញុំវិញថា តាមច្បាប់រដ្ឋធម្មនុញ្ញ បើមានការរំលាយរដ្ឋសភា *ត្រូវឱ្យរាស្ត្រវិនិច្ឆ័យសេចក្ដី* ។ បើអ្នកដំណាងរាស្ត្រក្នុងរដ្ឋសភាជាប់ឆ្នោតមកវិញភាគច្រើន ត្រូវចាត់*ទុកនយោបាយរដ្ឋសភាត្រូវ* បើអ្នកដំណាងរាស្ត្រក្នុងរដ្ឋសភាជាប់ឆ្នោតភាគតិច*ត្រូវចាត់ជានយោបាយរដ្ឋសភាខុស* ។

បើមានការរំលាយរដ្ឋសភា ត្រូវខ្ញុំធ្វើនាយករដ្ឋមន្ត្រី រដ្ឋាភិបាលខ្ញុំនេះ ត្រូវរៀប បោះឆ្នោតតាមច្បាប់រដ្ឋធម្មនុញ្ញជ្រើសរើសអ្នកដំណាងរាស្ត្រជាថ្មី ខ្ញុំង៉ែត.ហៀន សូមបំភ្លឺទៅលោកវិញថាតាមជំនឿរបស់ខ្ញុំប្រហែល គ្មានការបោះឆ្នោតទេ

ព្រោះបញ្ហារំលាយរដ្ឋសភានេះវាមានន័យទាក់ទង និងបញ្ហាឯករាជ្យបើបោះឆ្នោត ដដែល ចាំបាច់រំលាយរដ្ឋសភាធ្វើអ្វី ។ លោកអៀវ.កើស ឆ្លើយមកខ្ញុំវិញថា បើមិន បោះឆ្នោតទេ វាមាន*ការលើង្វែកលទ្ធិប្រជាធិបតេយ្យហើយ ហើយខុសនឹងច្បាប់ រដ្ឋធម្មនុញ្ញថែមទៀតផង ។*

ខ្ញុំ ង៉ែត.ហៀន តបទៅលោកវិញថា ចុះត្រង់មាត្រារដ្ឋធម្មនុញ្ញ*សម្តែងថា បើព្រះមហាក្សត្រមានការរំលាយរដ្ឋសភា ត្រូវមានសេចក្តីយល់ព្រម ពីប្រធាន រដ្ឋសភាជាមុន ចុះរឿងនេះ ហេតុដូចម្តេចក៏ព្រះក្សត្រ មិនឱ្យលោកប្រធានរដ្ឋ សភាជ្រាបផង* ។ ដែលខ្ញុំនិយាយនេះ មានវត្ថុបំណងចង់ឱ្យតុលាការតុលានិង រដ្ឋធម្មនុញ្ញបកស្រាយមាត្រានេះ *តើរំលាយរដ្ឋសភានោះ ដោយភ័ន្តច្រឡំទេ ឬ ត្រឹមត្រូវតាមច្បាប់* ។ ហើយខ្ញុំសូមបញ្ជាក់សេចក្តីជូនលោកប្រធានថែមទៀតថា *ច្បាប់បើគេមិនប្រតិបត្តិតាមមាត្រានេះហើយ ថ្ងៃមុខគេមិនអាចប្រតិបត្តិតាម មាត្រាណាក៏បានដែរ គួរតែរកខុសត្រូវក្នុងមាត្រានេះ ឱ្យឃើញសិន* ។ ប្រយ័ត្ន ក្លាយទៅជាប្រពៃណីអាក្រក់មកប្រឆាំងនឹងច្បាប់វិញ រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ ក្លាយទៅជារដ្ឋធម្មនុញ្ញរាជាធិបតេយ្យទៅវិញ អំណាចរបស់រាស្ត្ររស់ន័យទៅ ហើយ ហើយរដ្ឋធម្មនុញ្ញ ដែលរាំបរងលទ្ធិប្រជាធិបតេយ្យគ្មានច្រកចេញរួចទេ ពិត ជាថ្ងៃក្រោយមានអាណាធិបតេយ្យ នាំឱ្យរាស្ត្ររងទុក្ខ ។

លោកអៀវ.កើសថា បើដូច្នោះ សូមទៅអញ្ជើញអតីតអ្នកដំណាងរាស្ត្រ មក ដើម្បីឱ្យពិចារណា ហើយបញ្ចេញមតិ លុះដល់អតីតអ្នកដំណាងរាស្ត្រមក លោកអតីតប្រធានជំរាបអំពីយោបល់របស់ខ្ញុំ និងយោបល់របស់លោកខ្វែងគ្នា អតិ

ភាគច្រើន យល់តាមលោកអតីតប្រធានរដ្ឋសភា ខ្ញុំត្រូវតែគោរពតាម ទើបលាលោកទៅផ្ទះរៀងខ្លួនទៅ ។

កត់សំគាល់មតិរបស់បុគ្គលម្នាក់ៗ មិនត្រូវងាករេទៅតាមបុណ្យសក្តិឬសញ្ញាប័ត្ររបស់មនុស្សទេ ត្រូវគោរពនៅតាមហេតុផល គឺមិនយកលោកាធិបតេយ្យឬអអត្តាធិបតេយ្យមកជាសំអាងឡើយ ត្រូវយកធម្មាធិបតេយ្យមកសំអាងវិញ ។ ក្នុងពេលនោះបើអ្នកដំណាងរាស្ត្រ តាមមតិរបស់ខ្ញុំង៉ែត.ហៀនភាគច្រើនពិតជាអ្នកដំណាងរាស្ត្រ ត្រូវទុកជាមតិកទាំងអស់គ្នា ប៉ុន្តែមហាក្សត្រលែងរំលោភលើច្បាប់ទៀតហើយ ។ ដល់អ្នកដំណាងរាស្ត្រ តាមមតិរបស់លោកប្រធានរដ្ឋសភាវិញមានការរំលាយរដ្ឋសភារកទីបញ្ចប់គ្មាន ចំណុចត្រង់នេះបង្ហាញឱ្យឃើញថា ជាតិខ្មែរយើងមានកំពស់នយោបាយទៅទាបខ្លាំងណាស់ ព្រោះមានសេចក្តីខ្លាចឧបសគ្គ ។

ផលវិបាកនៃសេចក្តីខ្លាចរបស់អ្នកដំណាងរាស្ត្រភាគច្រើននោះ បានក្លាយទៅជាមតិករបស់ជាតិ រហូតមកដល់សព្វថ្ងៃនេះ នេះហើយខ្ញុំចាត់ទុកដូចលោកប្រធានអៀវ.កើសដែរ ព្រោះមតិភាគច្រើនពុំមែនសុទ្ធតែត្រូវឥតខ្ចោះទេ មានកាលៈទេសៈខ្លះខុសទៅវិញក៏មានដែរ ។ នេះជាការពិសោធន៍មួយទុកក្តើជូនទៅអនុជនរួមជាតិរិះរកមធ្យោបាយដោះស្រាយផងចុះ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថាបើកាលណាជាតិមិនគោរពច្បាប់រដ្ឋហើយ ពិតជាមានមន្ទិលសង្ស័យដល់មតិមហាជន ។ រឿងមិនគោរពច្បាប់នេះ ពុំមែនមកពីអ្នកតូចតាចទេ គឺពិតជាមកពីអ្នកធំផុតលេខតែម្តង ។

## វគ្គទី ១២

លោកអៀវ.កើសបានទៅកាន់ដំណែង នាយករដ្ឋមន្ត្រី តាមព្រះរាជក្រិត្យ ក្រុមប៊ុយរ៉ូរើសយកលោកសុនវើនសៃ ឱ្យធ្វើរដ្ឋមន្ត្រីមហាផ្ទៃ បេសកកម្មទៅបោះឆ្នោតឡើងទៅកាន់អំណាចគ្មានបានប៉ុន្មានថ្ងៃទេ ត្រូវព្រះមហាក្សត្រីយ៍រំលំចោលទៅវិញ ។ រួចហៅលោកអៀវ.កើសធ្វើជាទីប្រឹក្សាឯកជន អមព្រះអង្គមានឋានៈដូចរដ្ឋមន្ត្រីដែរ លោកអៀវ.កើសប្រកែក មិនព្រមទទួល ។ ខ្ញុំសួរលោកថា ហេតុម្តេចក៏ប្រកែក លោកប្រាប់ខ្ញុំវិញថា ដោយហេតុពីរយ៉ាង ហេតុទី១- *នយោបាយខ្ញុំនិងព្រះករុណាចូលគ្នាមិនចុះទេ ។ ហេតុទី២- ខ្ញុំធ្វើជាប្រធានរដ្ឋសភាធ្លាប់តែស្វែងរកប្រយោជន៍ឱ្យជនរួមជាតិ ដល់ពេលមានអាសន្នគិតតែប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ឱ្យអ្នកដំណាងរាស្ត្រទាំងអស់លំបាកវេទនាគ្រប់គ្នា ទៅឃើញថាខ្ញុំយកវេទិការគណៈបក្សប្រជាធិបតេយ្យ មករកប្រយោជន៍ផ្ទាល់ខ្លួនខ្ញុំទៅវិញ* ។ កាតព្វកិច្ចរបស់ខ្ញុំ ត្រូវនៅរួមជាមួយអស់លោក ធ្វើនយោបាយតទៅទៀត ហើយលោកបញ្ជាក់តទៅទៀតថា យើងត្រូវរួមគ្នាមួយក៏រិតខ្ពស់ថែមទៀត បើគ្នាយើងនរណាម្នាក់ ទទួលគ្រោះថ្នាក់ ដោយហេតុអ្វីមួយ ត្រូវសាមគ្គីគ្នាដោះស្រាយ ឱ្យខាងបានល្អប្រពៃឡើង ។

បន្ទាប់ពីនោះ.ព្រះករុណាម្ចាស់ជីវិត ត្រូវយាងទៅប្រទេសបារាំង ដើម្បីចចារពីរឿងឯករាជ្យ ប្រទេសកម្ពុជាតទៅទៀត ។ តម្រូវឱ្យលោកអៀវ.កើស

អតីតប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីយ៉ែម.សំបូរ តាមហែរព្រះអង្គទៅផង ។ គណៈប្រតិភូខ្មែរ ដែលមានព្រះករុណាជាប្រធាន ចចារពីរឿងឯករាជ្យលើកនេះ ឥតបានលទ្ធផលល្អឱ្យប្រទេសជាតិទេ ។ អតីតអ្នកដំណាងរាស្ត្រមានទីលំនៅខេត្តក្រៅទៅផ្ទះរៀងខ្លួនអស់ហើយ នៅតែអ្នកតំណាងរាស្ត្រដែលមានទីលំនៅ នៅភ្នំពេញ មានភាគតិចតួចទេ ។

គណកម្មការនាយកនៃគណបក្សប្រជាធិបតេយ្យ នៅធ្វើសកម្មភាពដូចពីដើម គឺមួយអាទិត្យត្រូវប្រជុំគ្នាម្តង រៀងរាល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង ៤ ដល់ម៉ោង ៦ ល្ងាច ទើបលើកពេលប្រជុំ ។ ក្នុងឱកាសនោះ ខ្ញុំទន្ទឹងមើលផ្លូវលោកអៀវ.កើស វិស័យដូចជា កូនមើលផ្លូវម្តាយទៅផ្សារ ព្រោះចង់ដឹងពីលទ្ធផលនៃកិច្ចចចារ រវាងរដ្ឋាភិបាលខ្មែរនិងរដ្ឋាភិបាលបារាំង ។

ឱកាសនោះមានមិត្តខ្ញុំម្នាក់ឈ្មោះ ទា.ឆាយ អតីតអ្នកដំណាងរាស្ត្រមណ្ឌលជ្រៃវៀន ទីរួមខេត្តកំពង់ចាម មនុស្សមានមិត្តភ័ក្ត្រច្រើនខាងបារាំង បានមកនិយាយប្រាប់ខ្ញុំថា តាមដំណឹងពីខាងបារាំង ការចចារនោះត្រូវបរាជ័យទៅហើយឥតបានលទ្ធផលល្អអ្វីទេ ។ គណបក្សយើងត្រូវតែរកផ្លូវផ្សេងតទៅទៀត ។ ខ្ញុំឮដំណឹងនេះរិតតែក្តៅក្រហាយខ្លាំងឡើង១ មិត្តខ្ញុំនោះឱ្យយោបល់ថា ផ្លូវដែលដើរទៅមុខមានសល់តែមួយគត់ ត្រូវនាំគ្នាកាន់អាវុធទាំងអស់គ្នាឡើងមានតែកម្លាំងអាវុធមួយទេ ដែលបារាំងសុខចិត្តប្រគល់ឯករាជ្យឱ្យជាតិយើង មិត្តនេះជាមនុស្សស្នោប់រស់ជាមួយនឹងខ្ញុំ ធ្វើការសម្ងាត់ឱ្យលោកអៀវ.កើស ។ ព្រោះប្រទេសវៀតណាម គេឈប់ប្រើមធ្យោបាយចចារគ្នាទៅហើយ ហើយជាតិយើងស្ថិតដល់

ណាទៀតមនុស្សនេះមានបក្សពួក នឹងចិនកុម្មុនិសផងថែមទាំងបារាំងកុម្មុយនិសទៀត ។ ខ្ញុំឆ្លើយតបទៅមិត្តខ្ញុំវិញថា ចាំលោកអៀវ.កើស មកសិនដើម្បីពិគ្រោះគ្នា រកច្រកចេញទៅទៀត ។ ក្នុងពេលនោះសារពត៌មានប្រជាធិបតេយ្យ បញ្ចេញសម្លេងកាន់តែខ្លាំងណាស់ដែរ ក្នុងការទាមទារឯករាជ្យពីប្រទេសបារាំង សារពត៌មានឯទៀត ស្រែកហៅអើ គ្រប់តែសារពត៌មាន មានពេលខ្លះ ប្រឆាំងជាងសារពត៌មានប្រជាធិបតេយ្យទៅទៀត មានន័យថា ខ្មែរគ្រប់គណបក្សមិនសុខចិត្តយកឯករាជ្យ ក្លែងក្លាយនោះទេ ។ អតីតអ្នកដំណាងរាស្ត្រនិមួយៗ អ្នករដ្ឋការគ្រប់ការិយាល័យ ក្នុងរដ្ឋាណាចក្រនាំគ្នាឃោសនាពន្យល់រាស្ត្រថា ឯករាជ្យអីមានរដ្ឋការពីរយ៉ាងនេះ ។ សកម្មភាពខាងខ្មែរឥស្សរៈ បានឡើងកំពស់ស្រីតៗជារៀងរាល់ថ្ងៃ ដល់មកជិតជាយក្រុងភ្នំពេញអស់ទៅហើយ ។ មានពេលខ្លះ គ្រាប់បែកដៃបានផ្ទុះនៅកណ្តាលក្រុងផង នាំឱ្យប្រជាពលរដ្ឋភ្ញាក់ផ្អើលកាន់តែខ្លាំងឡើង ។

ព្រះករុណា និងលោកនាយករដ្ឋមន្ត្រីយ៉ែម.សំបូរ បានវិលត្រឡប់មកកាន់ភ្នំពេញវិញហើយ បាត់លោកអតីតប្រធានរដ្ឋសភា អៀវ.កើស មិនឃើញមក រង់នៅចាំមកតាមកប៉ាល់ជើងទឹក ក្នុងចំណោមអតីតតំណាងរាស្ត្រខ្លះយល់ថាឥតបានមកទេ មុខជាបារាំងចាប់ខ្លួន នៅស្រុកបារាំងទៅហើយ ព្រោះលោកនេះហើយដែលនាំគេនាំឯងមិនទទួលយកឯករាជ្យក្លែងក្លាយនោះ ដំណឹងនេះធ្វើឱ្យអតីតអ្នកដំណាងរាស្ត្រជ្រួលច្របល់ម្តងទៀត ។ រំលងប្រហែលជាង ២០ថ្ងៃមកបានឃើញលោកអៀវ.កើសមកដល់ក្រុងភ្នំពេញវិញ អតីតអ្នកដំណាងរាស្ត្រនិងសមាជិកគណបក្សប្រជាធិបតេយ្យ ទៅសួរសុខទុក្ខលោកជាច្រើនគ្នា នរណាក៏ឃើញភ្ញាក់សម្ងាត់

បារាំងយាមផ្ទះលោកអៀវ.កើសដែរ ខ្ញុំនិងខ្មោចលោក ទា.ឆាយចុះឡើងញឹកញាប់ជាងគេ ។ លោកអៀវ.កើសបាននិយាយប្រាប់ខ្ញុំថា "លោកចង់ឱ្យមតិប្រជាពលរដ្ឋបារាំងគ្រប់មជ្ឈដ្ឋានយល់" លោកបានទៅស៊ើបសួរបារាំងទាំងនោះថា គួរឱ្យឯករាជ្យខ្មែរឬទេ បារាំងថាត្រូវតែឱ្យឯករាជ្យមកប្រទេសខ្មែរ ហើយត្រូវឱ្យទាំងប្រទេសកូសាំងស៊ីនផង ទើបត្រឹមត្រូវតាមសេចក្តីយុត្តិធម៌ ព្រោះកាលជប៉ុនចាប់បារាំង មានតែខ្មែរមួយទេ ដែលជួយលាក់បារាំង ។ លោកមានប្រសាសន៍តទៅទៀតថា មានតែមនុស្សភាគតិចទេ គឺរដ្ឋាភិបាលបារាំង មិនចង់ឱ្យឯករាជ្យមកប្រទេសយើង បើសារុបសេចក្តីទៅ យើងមានសេចក្តីសង្ឃឹមច្រើនណាស់ ។ ខ្ញុំបានជាមកតាមកប៉ាល់សមុទ្រ ព្រោះឆ្លៀតតែងសេចក្តី ធ្វើសន្និសិទ្ធមួយ បង្ហាញខេមរៈជន អំពីមតិរាស្ត្របារាំង និងរដ្ឋាភិបាលបារាំងខុសគ្នាវិស័យដូចមេឃនិងដី គឺឆ្ងាយពីគ្នាណាស់ ។

ខ្ញុំសូមពឹងផ្អែកលើលោកទាំងពីរនាក់នេះ សូមទៅរកកន្លែងឱ្យខ្ញុំធ្វើសន្និសិទ្ធ តើបានឬមិនបាន ពេលនោះខ្មោចលោក ទា.ឆាយ ទទួលថាបាន ថ្ងៃក្រោយមក លោកបានទៅទាក់ទងនិងលោកអភិបាលក្រុង សុំកន្លែងធ្វើសន្និសិទ្ធ លោកអភិបាលក្រុងថាៈ មិនបានទេ ព្រោះកន្លែងសម្រាប់អ្នករដ្ឋការ គួររកផ្សេងទៀតទៅប្រសើរជាង ។ ខ្មោចលោកទា.ឆាយ នឹងខ្ញុំទៅនិយាយរោងល្ខោនចិនរ៉ាន់បានខ្មោចលោកទា.ឆាយមកប្រាប់ខ្ញុំថាលោកមានដំណើរទៅការក្មួយឯកំពង់ធំ សូមឱ្យខ្ញុំទៅជំរាបលោកអៀវ.កើស ផង កន្លែងនោះរកបានហើយ ថ្ងៃ ១៤ ខែ មករា ឆ្នាំ ១៩៥០ ខ្ញុំធ្វើដំណើរទៅជំរាបលោកអៀវ.កើស ពីរឿងនោះ រឿងមួយទៀតលោក

ឱ្យខ្ញុំតាមស្ដាប់មើល តេបំរុងនិងកែប្រែរដ្ឋធម្មនុញ្ញដល់ណាហើយ ហើយមានបុព្វហេតុយ៉ាងណាទេ បានជាគេចង់កែប្រែរដ្ឋធម្មនុញ្ញ បើស៊ើបការបានយ៉ាងណាឱ្យខ្ញុំដឹងផង ។

## វគ្គទី ១៣

កាលពីថ្ងៃ ១៤ ខែមករា ឆ្នាំ១៩៥០ ពេលព្រឹកគណបក្សទាំងអស់រួមប្រជុំគ្នា ដើម្បីកែប្រែរដ្ឋធម្មនុញ្ញចុងក្រោយបំផុត លោក អៀវ.កើស ក្នុងឋានៈជំណាងគណបក្សប្រជាធិបតេយ្យ សម្ដែងឆន្ទៈមិនយល់ព្រមឱ្យកែប្រែទេ ព្រោះអាងហេតុ ៣ យ៉ាង :

១- ពេលនេះមិនទាន់មានរដ្ឋសភាផងទេ ។ ២-រដ្ឋធម្មនុញ្ញទើបអនុវត្តន៍មិនទាន់បានគ្រប់មាត្រាផង ម្ដេចក៏សុំកែប្រែទៅវិញ ។ ៣- បើការកែប្រែនោះ នាំឱ្យមានការបន្ថយសិទ្ធិពលរដ្ឋ សេរីភាពពលរដ្ឋខ្ញុំក្នុងឋានៈជំណាងគណបក្សប្រជាធិបតេយ្យ មិនព្រមជាដាច់ខាត ។ ថ្ងៃ ខែ ឆ្នាំដដែល គណកម្មការនាយកប្រជាធិបតេយ្យមកប្រជុំ ដើម្បីពិនិត្យបញ្ហាផ្សេងៗ ពេលថ្ងៃរសៀល លុះគណកម្មការនាយករួមប្រជុំចប់ហើយ សមាជិកគណបក្សទាំងឡាយទៅផ្ទះរៀងខ្លួនអស់ទៅ នៅសល់តែលោកប្រធានអៀវ.កើស និងលោកបាក់.មុងសេង តែពីរនាក់ កំពុងសន្ទនាគ្នាក្នុងការិយាល័យគណបក្សប្រជាធិបតេយ្យ ក្នុងដែលនោះ ខ្ញុំង៉ែត.ហៀន

នៅអង្គុយលេងនៅផ្ទះបងថ្លៃខ្ញុំ ប្រហែលជាម៉ោង៤កន្លះ ខ្ញុំក្រឡេតទៅមើលប្រក្រតីទិន គឺចំថ្ងៃដែលលោកអៀវ.កើស ណាត់ឱ្យខ្ញុំទៅជួប ដើម្បីស្តាប់សេចក្តីរាយការណ៍ពីខ្ញុំ ខ្ញុំលាម្ចាស់ផ្ទះ បើករថយន្តសំដៅទៅការិយាល័យ គណបក្សប្រជាធិបតេយ្យ ភ្នាក់ងារសម្ងាត់បារាំងជិះម៉ូតូបើកតាមខ្ញុំ ពីផ្សារសួនចាស់ ខ្ញុំបើករថយន្តតាមវិថីសទ្ធារស់ ឃើញលោកប៉ែន.អិន ដំណាងរាស្ត្រខែត្រក្រចេះ ខ្ញុំឈប់រថយន្ត ហៅលោកប៉ែន.អិន ទៅបានពីរនាក់លោកប៉ែន.អិន ឆ្លើយថាជាប់រវល់បន្តិច សូមអញ្ជើញទៅចុះ បើមានការចម្លែកសូមឱ្យដំណឹងផង ។ ភ្នាក់ងារសម្ងាត់បារាំង ចាំខ្ញុំនៅខាងក្រោយរថយន្តខ្ញុំចេញរថយន្តទៀត ភ្នាក់ងារសម្ងាត់បារាំង ក៏បើកម៉ូតូតាមខ្ញុំទៅទៀត ដល់ខ្ញុំបើករថយន្តដល់មុខការិយាល័យគណបក្សប្រជាធិបតេយ្យ ខ្ញុំឃើញទាហានបារាំងខាងជើងទឹក ប្រហែល១០នាក់ទៅ១២នាក់ កំពុងតែជជែកគ្នាលេងបែបខុសពីធម្មតា ខ្ញុំក្រឡេតទៅឃើញភ្នាក់ងារសម្ងាត់បារាំង ដែលធ្លាប់តែតាមយាមលោកអៀវ.កើស ឈរនៅមុខការិយាល័យគណបក្ស ។ ខ្ញុំរកចតរថយន្តឃើញឈ្មោះ នូ.យ៉ាអង្គុយចោងហោងពាក់បេរ៉េខ្មៅលុះខ្ញុំចតរថយន្តរួច ខ្ញុំចុះពីរថយន្ត ភ្នាក់ងារសម្ងាត់បារាំងដែលស្គាល់មុខ ខ្ញុំច្បាស់ព្រោះខ្ញុំតែងតែទះស្មា ឱ្យមកកត់លេខរថយន្តខ្ញុំចុះឈ្មោះលើកដៃសំពះខ្ញុំ ខ្ញុំសំពះតបវិញ ហើយដើរចូលទៅកាន់ការិយាល័យគណបក្ស ។ សារុបសេចក្តីទៅមានភ្នាក់ងារសម្ងាត់បារាំង ៤នាក់នៅយាមការិយាល័យគណបក្សគឺ ២នាក់យាមលោក អៀវ.កើស ពីរនាក់ទៀតយាមខ្ញុំង៉ែត.ហៀន ។

លោកអៀវ.កើស សួរខ្ញុំថា ម្តេចក៏យូរម្តេចម្លេះនេះ ខ្ញុំសូមទោសលោកថា

ភាន់ច្រឡំស្មានតែថ្ងៃស្អែក លោកសួរខ្ញុំទៀតថា មានការអ្វីចំឡែកទេ ខ្ញុំឆ្លើយថា មាន លោកហាក់.មុងសេង ថា ស្ដាយណាស់មិនបានទៅស្ដាប់ព្រោះដល់ពេលចាក់ថ្នាំ លោកអៀវ.កើស ហៅខ្ញុំ ដែលអង្គុយកៅអីមួយផ្សេង ឱ្យអង្គុយកៅអីលោកហាក់.មុងសេងវិញដើម្បីឱ្យចំមុខគ្នា ស្រួលដល់ការចចារគ្នា ខ្ញុំចូលទៅអង្គុយកៅអីនោះ ហើយជំរាបលោកថា កន្លែងសិទ្ធិសិទ្ធរកបានហើយ នៅរោងល្ខោនចីវ៉ាន់ផ្សារកាប់គោលោកសរសើរខ្ញុំថាចេះរកកន្លែងល្អណាស់ ព្រោះរោងល្ខោននោះ នៅចំកណ្ដាលភូមិខ្មែរតែម្ដង ។

រួចខ្ញុំបន្តសេចក្ដីរាយការណ៍តទៅទៀតថា តាមការស៊ើបអង្កេតរបស់ខ្ញុំមុខជាមានការកែប្រែរដ្ឋធម្មនុញ្ញហើយ គេយកមតិភាគច្រើនក្នុងគណបក្ស លោកសួរមកខ្ញុំវិញមានគោលបំណងយ៉ាងណា បានជាគេចង់កែប្រែរដ្ឋធម្មនុញ្ញនោះ ខ្ញុំង៉ែត.ហៀន មិនទាន់បានឆ្លើយផង ស្រាប់តែលោកស្រែកប្រាប់ថា ក្មេងណាចោលអី ខ្ញុំក្រោកស្ទុះឡើងក្រឡេកឃើញបែបដូចដបទឹកខ្មៅ កំពុងតែរមៀល ស្រាប់តែឮសូរផ្ទុះផាំងតែម្ដង ខ្ញុំដួលទៅខាងកើតតុ បែរក្បាលទៅទិសខាងជើង លោកនៅខាងលិចតុ ដួលបែរក្បាលទៅទិសខាងត្បូង លោកលាន់មាត់ថា: យី ! នយោបាយប្រទេសយើងដល់ម្លឹងលោកសួរខ្ញុំថា លោកត្រូវត្រង់ណាខ្ញុំឆ្លើយថាត្រូវបាក់ជើង ខ្ញុំសួរទៅលោកវិញថាលោកប្រធានត្រូវត្រង់ណាលោកឆ្លើយថាខ្ញុំធ្ងន់ណាស់ សូមប្រាប់គ្នាយើង *ឱ្យបន្តនយោបាយទៅទៀតជំរាបបានឯករាជ្យឱ្យជាតិ* ស្រាប់តែឮសូរខល់ខល់តែម្ដង ទោះបីខ្ញុំសួរយ៉ាងណាឥតមានឆ្លើយមកខ្ញុំសោះ ។

បែរជាឮសូរសង្រៀតធ្មេញក្រើត១ទៅវិញ ហើយ *ប្រាប់ខ្ញុំថា សូមប្រាប់គ្នា*

*យើង កុំឱ្យចងគំនុំតទៅទៀតទុកសន្តិភាពជូនមហាជនទៅចុះ* សំដីនេះជាមជ្ឈិម វាចាចុងក្រោយបំផុត ។ ខ្ញុំស្រែកហៅលេខហារីម្នាក់ឈ្មោះសែម មិនឃើញឈ្មោះ សែមមក ត្រឡប់ជាឃើញកុម្មសៀសម្ងាត់បារាំង ផ្ទេកខាងយកការណ៍សម្ងាត់ចូល ទៅកាន់ទីរងគ្រោះមុនគេទាំងអស់ ។ ខ្ញុំនឹកថាបារាំងនេះចូលមកបាញ់ខ្ញុំនិងលោក អៀវ.កើស បន្ថែមទៀតក៏មិនដឹងស្រាប់តែបារាំងនោះចេញបាត់ទៅ ។ ឃើញ លោកឡោ.ធូកចូលមកជាលើកទី ២ មកបីត្រកងខ្ញុំទៅពេទ្យព្រះកេតុមាលាមុនខ្ញុំ ចេញទៅ បានឃើញលោកស្នងការ សេង.ទីប មកជាលើកទី ៣ ជាមួយនិងលោក ស្រី អៀវ.កើស ។

ខ្ញុំទៅដល់មន្ទីរពេទ្យព្រះកេតុមាលា ខ្ញុំស្រែកទឹកណាស់ លោកង៉ោ.ហ៊ូ មិន ព្រះឱ្យផឹក *បែរឱ្យទឹកកក*មកបៀមទៅវិញ ខ្ញុំអស់កម្លាំងណាស់ លែងដឹងខ្លួនតាំង ពីនោះរហូត ។

សូមមិត្តអ្នកអានជួយពិចារណាខ្ញុំមើល បើខ្ញុំនិងលោកអៀវ.កើសអតីត ប្រធានរដ្ឋសភានេះត្រូវភ្នាក់ងារសម្ងាត់បារាំង*តាមឃ្លាំមជាប់ជានិច្ច គ្មានដែលអាក់ ខាន មោងណាសោះ តាំងពីថ្ងៃធ្វើលក្ខន្តិកឯករាជ្យនោះមកដោយស្មានប្រហែល ៤-៥ខែហើយម្តេចឡើយ ក៏ភ្នាក់ងារសម្ងាត់បារាំង ៤ នាក់ បណ្តោយឱ្យមនុស្សឯ ទៀតមកធ្វើឃាតលើរូបខ្ញុំនិងលោកអៀវ.កើសទៅកើត ។ បើប្រសិនជាមនុស្សឯ ទៀត ក្រៅពីភ្នាក់ងារសម្ងាត់បារាំងទៅវិញ ម្តេចឡើយភ្នាក់ងារសម្ងាត់បារាំងនោះ* មិនចាប់ខ្លួនអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋនោះម្តងទៅ ។

តាមជំនឿរបស់ខ្ញុំ *គ្មានទរណាក្រៅពីភ្នាក់ងារសម្ងាត់បារាំងនោះឡើយ*

ព្រោះខ្ញុំនឹងលោក អៀវ.កើស រងគ្រោះដោយគ្រាប់បែកដៃភ្លាម *ម្ដេចឡើយក៏ស៊ុង ការសម្ងាត់បារាំងដឹងរឿងនេះរហ័សម្ល៉េះ* គឺចូលទៅដល់កន្លែងកើតហេតុភ្លាមៗ ។ ហើយអ្នកដែលចាប់ខ្លួនឈ្មោះ ទូ.យ៉ាបាននោះ *គឺទាហានជើងទឹករបស់បារាំងនឹង ឯង ឈរនៅមុខការិយាល័យគណបក្ស ប្រហែល ១២ នាក់នោះ* តែម្ដង មានន័យថាវាយហើយស៊ំមុខរបូលវិញ ខ្ញុំសូមបញ្ជាក់ជូនមិត្តអ្នកអានថាៈ ខ្លួនខ្ញុំនេះហើយជាអ្នកផ្ដើមគំនិតសុំឯករាជ្យពីបារាំងឱ្យជនជាតិខ្មែរ លោកអៀវ.កើស មិនយល់ស្របតាមលក្ខក្ដិៈឯករាជ្យ ២៤៥ ជាលើកទី១ ខ្ញុំនេះស្ម័គ្រចិត្ត ដោយស្មោះត្រង់ចំពោះជាតិមិនព្រមទទួលយកឯករាជ្យ ២៤៥ ជាលើកទី២ ដូចជំរាបពីខាងដើមរួចមកហើយ ខ្ញុំនៅតែសប្បាយចិត្តជានិច្ច នឹងអំពើដែលខ្ញុំបានបំពេញជូនជាតិ ពិតមែនតែខ្ញុំនិងលោអៀវ.កើស ពុំបានទទួលឯករាជ្យពីប្រទេសបារាំង ដោយផ្ទាល់ខ្លួន ប៉ុន្តែឧត្តមគតិរបស់ខ្ញុំ និងលោក អៀវ.កើស *ស្របតាមឆន្ទៈប្រជាតិទាំងអស់* ចំណុចត្រង់នេះ មានន័យថាមិនបានទទួលឯករាជ្យផ្ទាល់ដៃនោះពិតមែន ប៉ុន្តែឧត្តមគតិដែលមានភាពរឹងប៉ឹងជាងដែកថែបទៅទៀត នាំឱ្យអ្នកស្នេហាជាតិឯទៀត យកទៅជាធ្វើមូលដ្ឋាន តវ៉ាលុះត្រាតែបានឯករាជ្យបរិបូរណ៍ ប៉ុន្តែខ្ញុំនៅស្ដាយ ក្រៃណាលែងស្ដាយ ចំពោះបាត់ដីកូសាំងស៊ីន ដែលហៅថាកម្ពុជាក្រោម បើជីវិតរបស់ខ្ញុំរស់នៅតទៅទៀត ខ្ញុំខិតខំរកគ្រប់មធ្យោបាយ ដែលខ្ញុំមាន លុះត្រាតែបានដីកម្ពុជាក្រោម មកជូនជាតិទើបស្របតាមវត្ថុបំណងរបស់ខ្ញុំ និងលោកអៀវ.កើស ។

ខ្ញុំសូមធ្វើបណ្ដាំទុក ចំពោះជនរួមជាតិថាៈ ករណីកិច្ចរបស់ជាតិ ទាមទារតវ៉ាយកឯករាជ្យនេះ បានបរិបូរណ៍មួយភាគហើយ ប៉ុន្តែពុំទាន់មានឯកភាពទេ សូម

អនុជន អ្នកស្នេហាជាតិខាងក្រោយកុំភ្លេចរឿងនោះឱ្យសោះ បើកាលណាយើងបណ្តោយឱ្យគេជាន់ បានមួយជំហានមុខតែគេឈ្នានពានមួយជំហានមកទៀត យូរៗទៅជាតិយើងនិងរលាយបាត់ពីផែនទីសកលលោកតែម្តង ។

ខ្ញុំសូមបញ្ជាក់ថា លោកអៀវ.កើស ដឹកនាំដល់ពេទ្យទទួលមរណៈភាព គ្រួសារនឹងសមាជិកគណបក្សប្រជាធិបតេយ្យ នាំយកសពលោកទៅដម្កល់នៅផ្ទះរបស់លោកដើម្បីធ្វើបុណ្យឧទ្ទិសកុសលជូនវិញ្ញាណក្ខ័ន្ធលោក ។

ចំណែកខ្ញុំង៉ែត.ហៀន ទទួលព្យាបាលមុខរបួលអស់ ៨ខែនៅមន្ទីរពេទ្យព្រះកេតុមាលាអស់ប្រាក់ ប្រាំបីពាន់រៀល(៨០០០៛០០)ពីរឆ្នាំទើបធ្វើសកម្មភាពបានវិញ ក្នុងពេលនោះគ្រួសាររបស់ខ្ញុំធ្លាក់ដល់បាតសមុទ្រទៅហើយ ។ ក្នុងពេលនោះខ្ញុំសូមអំពាវនាវគុណព្រះរតនត្រៃយ៍ នឹងគុណមាតាបិតាអាចារ្យទាំងអស់ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងសាកលលោក សូមឱ្យទុកជីវិតខ្ញុំ ដើម្បីខ្ញុំបានឃើញមនុស្សដែលផ្តើមគំនិតសម្លាប់លោកអៀវ.កើស នឹងខ្ញុំដែលធ្វើសកម្មភាពជូនជាតិដោយសុទ្ធចិត្ត ។ ស្រាប់តែម៉ោង ៤ភ្លឺខ្ញុំសុបិននិមិត្តឃើញ លោកអៀវ.កើសដដែលប៉ុន្តែស្លៀកសពាក់ស បែបដូចបេក្ខជនចូលទៅបួស យកសៀវភៅមួយហិបមកបើកបង្ហាញខ្ញុំ ហើយប្រគល់ហិបសៀវភៅនោះឱ្យមកខ្ញុំរក្សាទុករួចហើយត្រឡប់ទៅ វិញបាត់ទៅសុបិនមិត្តនេះគ្មាននរណាកាត់ឱ្យខ្ញុំបានទាល់តែសោះ ។

រឿងនេះមិនទាន់ចប់ទេ បច្ចាមិត្តវានៅពួនលាក់ពុត តាមរកមុខសម្លាប់អ្នកស្នេហាជាតិតទៅទៀត រំលងជាច្រើនថ្ងៃ *វាចោលគ្រាប់បែកទៅផ្ទះលោកឃុន.ណៃ ដើម្បីសម្លាប់ជីវិតលោកតទៅទៀត ។*





លោក **ឃុន.ណៃ** អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផង អ្នកដំណាងរាស្ត្រមណ្ឌលក្រុងបាត់ដំបងផង មានភ័ព្វសំណាង បានធ្វើជាប្រធានទីប្រឹក្សាជាតិបន្តបេសកកម្មពីលោកអៀវ.កើស ក្នុងការទាមទារឯករាជ្យនឹងជាអ្នកការពាររដ្ឋធម្មនុញ្ញ ក្នុងពេលលង្វែកលទ្ធិប្រជាធិបតេយ្យ ។

មិត្តអ្នកអានប្រហែលជាមានសេចក្តីងឿងឆ្ងល់ហើយ ហេតុដូចម្តេចបានជាបច្ចាមិត្តរបស់ជាតិតាមសម្លាប់តែមនុស្ស ៣រូបនេះ សមាជិកគណបក្សប្រជាធិបតេយ្យគពោកក៏មិនតាមសម្លាប់ផងទៅ ? ចំណុចត្រង់នេះខ្ញុំសូមអនុញ្ញាតបំភ្លឺថា *ភ្នាក់ងារសម្ងាប់របស់អាណានិគមនិយមបារាំង វាស្គាល់ជម្រៅនយោបាយ របស់សមាជិកគណបក្សប្រជាធិបតេយ្យ*ទាំងអស់ ពិសេសទៅទៀត វាសំគាល់ឃើញមនុស្ស ៣នាក់នេះ ឧស្សាហ៍ជូបគ្នាញឹកញាយណាស់ ជូនទៅការិយាល័យរដ្ឋសភា ជូនទៅការិយាល័យគណបក្សប្រជាធិបតេយ្យ ។ តាមខ្ញុំស្មានប្រហែលជាមានសម្លេងមនុស្ស ៣នាក់នេះ ចូលទៅក្នុងខ្សែអាត់របស់ពួកបច្ចាមិត្តទេដឹង ព្រោះ ៣នាក់ ជួបគ្នាម្តង១ ឥតប្រុងប្រយ័ត្នអំពីខ្សែអាត់ទេ ព្រោះប្រទេសយើងមិនទាន់និយមប្រើខ្សែអាត់ ដែលសម្រាប់ថតសម្លេងបញ្ចាលដល់ប្រជាជន ។ រឿងមានខ្សែអាត់ថតសម្លេងនាំឱ្យខ្ញុំភ្ញាក់ខ្លួនព្រឹតនៅពេលខ្ញុំពិភាក្សាពីរឿងឯករាជ្យ ជាមួយលោករអៀវ.កើស នឹងលោក ឃួន ណៃ ខ្ញុំវិលត្រឡប់មកថ្លឹងសំដីរបស់ខ្ញុំ និងកល្យាណមិត្តរបស់ខ្ញុំវិញ ខ្ញុំ*ឃើញថាសំដីពិភាក្សាទាំងនោះវាធ្ងន់ខ្លាំងណាស់ ត្រូវតែភាគីអកុសលសម្លាប់ហើយ ។ ដោយបញ្ចេញសេចក្តីស្មោះត្រង់ចំពោះជាតិ គ្មានលាក់លៀមអ្វីទាល់តែសោះ ។*

ក្នុងពេលដែលខ្ញុំវិបត្តិជីវភាពគ្រួសារ គណបក្សប្រជាធិបតេយ្យ បានឱ្យលោក ស្វាយ.សូ នឹងលោកមិញនាត្រីយកប្រាក់ ១០០០៛ មកជួយគាំទ្រដែរ ប៉ុន្តែយកប្រាក់នោះទៅធៀបនឹងណោយលោកឃួន.ណៃ វិញ ឃើញថាខុសឆ្ងាយពីគ្នាណាស់ វិស័យដូចជាទឹកត្រពាំងនឹងទឹកទន្លេមានន័យថាលោក *ស្រឡាញ់អ្នកស្នេហា*

*ជាតិ ស្មើរតែជាងកូនបង្កើតទៅទៀត ។*

តាមខ្ញុំសំគាល់ឃើញឧត្តមគតិវរៈជនទាំងអស់ ដែលកាន់អំណាច *គ្មានវរៈជនណាពិសេសដូចលោក ឃួន.ណៃ* ទេ ដែលឥតពីលោកអៀវ.កើសទៅ កាលលោកឡើងធ្វើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ *លោកប្រកាសប្រាប់ដល់មហាជនមិនឱ្យយកប្រាក់ទៅសូកចៅក្រមទេ បើចៅក្រមណាទទួលសំណូកលោកធ្វើទោសគ្មានឃោគយល់ឡើយ ហើយលោកសុំភ្នាក់ងារសម្ងាត់យកមកស៊ើបការរកមុខ អ្នករដ្ឋការស៊ីសំណូកទៀតផង* ។ ចំណុចត្រង់នេះបង្ហាញឱ្យឃើញថា *មកពីខ្លួនលោកស្អាតស្អំណាស់ បានជាហ៊ានប្រកាសប្រឆាំង និងអំពើពុករលួយយ៉ាងនេះ* បើរិះគិតដល់អត្ថន័យប្រកាសនោះ ឃើញថា គ្មាននរណាហ៊ានចូលទៅសូក *លោកនិងអ្នករដ្ឋការឯទៀតឡើយ ចំណុចត្រង់នេះ បង្ហាញថា* លោកគ្មានស៊ីសំណូកទេ សម្តែងចិត្តស្មោះត្រង់ចំពោះជាតិ ។ *ឧត្តមគតិលោក ឃួន.ណៃ នេះ គួរយកជាគំរូយ៉ាងគ្រប់គ្នា ។*

ព្រោះមានផលប្រយោជន៍ដល់ជាតិសំខាន់ណាស់ ។ ហេតុម្តេចបានជាខ្ញុំចាត់ទុកថាមាន ប្រយោជន៍សំខាន់ណាស់ *ព្រោះខ្ញុំយល់ថាតាមលទ្ធិប្រជាធិបតេយ្យការសំខាន់ត្រូវពលរដ្ឋគោរពច្បាប់* មានរដ្ឋធម្មនុញ្ញជាដើមហាមឃាត់មិនឱ្យសូក *មិនឱ្យស៊ីសំណូក* អ្នកសូកនោះគឺនរណា មិនគឺសាធារណជន អ្នកស៊ីសំណូកនោះគឺនរណា មិនគឺអ្នករដ្ឋការគ្រប់ប្រភេទ ដែលពុករលួយភាគខ្លះ ។

នាកាលបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បណ្តោយឱ្យពលរដ្ឋសូកអ្នករដ្ឋការបានតាមចិត្ត និងបណ្តោយឱ្យអ្នករដ្ឋការស៊ីសំណូកបានតាមចិត្ត ។ *កម្លាំងប្រាក់ធំជាងកម្លាំងច្បាប់ទៅហើយ* មិនបាច់មានច្បាប់តទៅទៀតទេ *ត្រូវតែពលរដ្ឋទាំងអស់*

*ពឹងផ្អែកទៅលើកម្លាំងប្រាក់វិញ* ។ បើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បណ្តោយឱ្យកម្លាំងប្រាក់ឈ្នះកម្លាំងច្បាប់ពិតជាថ្ងៃក្រោយទៅ *ពលរដ្ឋខ្លះយកកម្លាំងអាវុធ មកសង្កត់លើកម្លាំងប្រាក់វិញនាំឱ្យមានការច្របូកច្របល់រកទីបំផុតគ្មាន* ។

បើប្រទេសកម្ពុជា ធ្វើដំណើរដល់ថ្នាក់នេះហើយ អ្នកប្រាជ្ញដែលគេនិយមប្រើគតិបណ្ឌិត គេចាត់ទុកប្រទេសកម្ពុជាយើងថា *មានវិបត្តិរដ្ឋធម្មនុញ្ញ ដែលធានារ៉ាប់រងនូវលទ្ធិប្រជាធិបតេយ្យ*គឺព្រឹត្តិការណ៍នៃប្រទេសនោះវា *ចូលទៅក្នុងអំណាចអាណាធិបតេយ្យពេញទី* គឺគ្មានរបៀបរៀបរយ នឹងការពារផលប្រយោជន៍សាធារណជនទាល់តែសោះឱ្យសាធារណជនសង្ឃឹមលើអ្វី ដោយហេតុដូចជំរាបមក*ពីខាងលើនេះហើយបានជា លោក ឃួន.ណៃ កាលធ្វើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌*ពុះពាប្រកាសប្រឆាំងនឹងអំពើពុករលួយគ្រប់បែបយ៉ាង ព្រោះលោកស្គាល់ករណីយកិច្ចរបស់ជាតិ*ច្បាស់ណាស់ ។ ចំពោះរឿងនេះខ្ញុំមិនអ្នកអាងទេ ប៉ុន្តែខ្ញុំសូម* អ្នកអានវិលត្រឡប់ទៅពិនិត្យស្ថាន ការណ៍កាលជំនាន់ លោកឃួន.ណៃកាន់អំណាចរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឡើងវិញ។ ហើយយកព្រឹត្តិការណ៍នោះមកថ្លឹងនិងព្រឹត្តិការណ៍ កាលជំនាន់សង្គមរាស្ត្រនិយម កាន់អំណាចមុនថ្ងៃ ១៨.មីនា.១៩៧០ *ឡើងវិញមើលតើខាងណាល្អជាងខាងណា* ។ ខ្ញុំសូមលើកឧទាហរណ៍មួយ កាលជំនាន់លោក ឃួន.ណៃ កាន់អំណាចរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌មកបង្ហាញមិត្រអ្នកអានដើម្បីជ្រាបជាពតិមានដូចតទៅនេះ :

មានពលរដ្ឋម្នាក់ឈ្មោះអ៊ា.ងួន បានទិញក្របីឱ្យចៅកែពីរនាក់ឈ្មោះសុះនឹងឈ្មោះឡាយ.អី ដើម្បីយកក្របីនោះទៅលក់ក្រៅប្រទេស មានថ្ងៃមួយនោះ

ឈ្មោះអ៊ា.ងួនទៅសុំបើកប្រាក់៥ម៉ឺនរៀលពីចៅកែទាំងពីរនាក់ ដូចមានឈ្មោះខាងលើ ចៅកែបានឱ្យប្រាក់៥ម៉ឺនរៀលមកឈ្មោះអ៊ា.ងួន ដើម្បីឱ្យថ្លៃក្របីដែលអ៊ា.ងួនបានទិញឱ្យខ្លួន ហើយមានឱ្យមនុស្សម្នាក់តាមមករក្សាប្រាក់ជាមួយផង ។ ក្នុងយប់ដែលត្រឡប់មកដល់ទីលំនៅវិញ ឈ្មោះអ៊ា.ងួន ទទួលទានដំណេក ជាមួយអ្នកបំរើនោះលក់ទៅ ស្រាប់តែមានចោរមិនស្គាល់ឈ្មោះ មកខួងជញ្ជាំងជិតមាត់ទ្វារហើយលួចយកប្រាក់ ៥ម៉ឺនរៀល នឹងទ្រព្យរបស់ឈ្មោះអ៊ា.ងួន ។ បានចូលទៅប្តឹងស្នងការនគរបាលយុត្តិធម៌ពេទ្យចិន ដើម្បីឱ្យអ្នករដ្ឋការទាំងនោះជួយរកចោរឱ្យឃើញ ។ លោកស្នងការនគរបាលយុត្តិធម៌ បានអញ្ជើញទៅផ្ទះឈ្មោះអ៊ា.ងួនធ្វើសេចក្តីហេតុតាមដំណើរ ប៉ុន្តែនៅខាងចុងសេចក្តីកត់ហេតុបញ្ជាក់សេចក្តីថា តាមស្នាមខួងជញ្ជាំងពី*ខាងក្រៅ អាចោរមិនអាចចូលទៅក្នុងផ្ទះបានទេ* ព្រោះពិសោធន៍មើលគ្រប់វិធីហើយ មិនអាចបើកទ្វារចូលទៅខាង*ក្នុងផ្ទះបានទេ* មានតែមនុស្សចូលពួននៅក្នុងផ្ទះជាមុន ចាំបើកទ្វារពីក្បាលព្រលប់ ទើបលួចទ្រព្យសម្បត្តិក្នុងផ្ទះនោះបាន ។ លោករដ្ឋការអាជ្ញាសាធារណរដ្ឋសាលាដំបូងភ្នំពេញ ចោទប្រកាន់លើឈ្មោះអ៊ា.ងួនថា លួចដោយប្រើឧបាយកលទុច្ចរិត បញ្ជូនឈ្មោះអ៊ា.ងួននឹងសំណុំរឿងទៅឱ្យលោកសុភាចារបុរសស៊ើបអង្កេតរកសេចក្តីយុត្តិធម៌ ។ លោកសុភាចារបុរសឈ្មោះ(ក) សួរបញ្ជាក់ឈ្មោះអ៊ា.ងួនឱ្យឆ្លើយដោះសារការពារខ្លួន ឈ្មោះអ៊ា.ងួន ឆ្លើយប្រកែកពីខ *ចោទលោកសុភាចារបុរស ឱ្យពន្យល់ពីរបៀបបើកទ្វារពីខាង* ក្រៅឈ្មោះអ៊ា.ងួនគ្មានមធ្យោបាយនឹងពន្យល់ លោកសុភា*ចារបុរសឈ្មោះ(ក)ឃុំឃាំង ឈ្មោះអ៊ា.ងួន នៅពន្ធនាគារជាតិ* ទើបប្រពន្ធឈ្មោះអ៊ា.ងួនរត់

ទៅពឹងមេធាវីម្នាក់ សុំឱ្យជួយការពារសង្គ្រោះ លោកមេធាវីឈ្មោះ(ខ)គ្មានមធ្យោបាយ ដោះ *ឈ្មោះអ៊ា.ងួន រួចពីពន្ធនាគារឡើយ* ។ ទើបប្រពន្ធឈ្មោះអ៊ា.ងួន រត់ទៅពឹងមេធាវីមួយទៀត ឈ្មោះ(គ)ជួយការពារសង្គ្រោះ អ៊ា.ងួន បន្ថែមទៀត មេធាវីទី ២ នេះបានចំឡងសំណុំរឿង *យកមកពិនិត្យសព្វគ្រប់ហើយ ហើយសុំ* អនុញ្ញាតលោកសុភាចារបុរសទៅជួបឈ្មោះអ៊ា.ងួនឯទីពន្ធនាគារ *ដើម្បីសួរបញ្ជាក់ ទៅចំណុចខ្លះ ហើយទៅពិនិត្យមើលផ្ទះកើតហេតុដល់ទីកន្លែង ដើម្បីពិសោធន៍ក្នុង ការបើកទ្វារពីខាងក្រៅមើល តើបើកបានឬមិនបាន លុះដល់ពិសោធន៍មើលទៅ ឃើញថាបើកពីខាងក្រៅបានលោកមេធាវី* ទី២ នេះប្រាប់ប្រពន្ធឈ្មោះអ៊ា.ងួនថា ប្រហែលមួយអាទិត្យទៀតឈ្មោះអ៊ា.ងួន បានរួចខ្លួនហើយ ។ ក្នុងថ្ងៃដដែលនោះ លោកមេធាវីទី២ បានធ្វើពាក្យប្តឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បញ្ជាក់សេចក្តីថា *លោកសុភាចារបុរសឈ្មោះ(ក) ឃុំឃាំងឈ្មោះអ៊ា.ងួន ដោយភាន់ច្រឡំទេ ព្រោះ អាងហេតុថា* គ្មានជនណាចូលទៅពីខាង*ក្រៅបាន ដោយជឿតែសេចក្តីកត់ហេតុ របស់មន្ត្រីក្រុមនគរបាលយុត្តិធម៌ ឥតមានទៅពិនិត្យខ្លួនឯងទីកន្លែងឃើញថាខុស នឹងទំនងច្បាប់ពេញទី បើលោករដ្ឋមន្ត្រីមិនជឿខ្ញុំជាមេធាវីទេ សូមចាត់ចៅក្រម ផ្សេង ឱ្យធ្វើអង្កេតថែមទៀតចុះ ពិតជានឹងឃើញការពិតពុំខានឡើយ លោក យ៉ូន.ណៃ* ពិនិត្យសេចក្តីតវ៉ារបស់លោកមេធាវីរួចហើយលោក *ចាត់ចៅក្រមផ្សេង ឱ្យចេញទៅពិនិត្យផ្ទះកើតហេតុនោះភ្លាម មួយរំពេចដោយចៅក្រមឈ្មោះ(ឃ) បានធ្វើអង្កេតជាមួយនឹងមេធាវីទី២* តាមសេចក្តីពន្យល់របស់មេធាវីទី ២ ឃើញ ថា*បើកទ្វារផ្ទះរួចពីខាងក្រៅពិតមែន ទើបធ្វើសេចក្តីកត់ហេតុប្តឹង* ទៅក្រសួង

យុត្តិធម៌ លោកឃួន.ណៃ បញ្ជាឱ្យលោកសុភាចារ *បុរសឈ្មោះ(ក) ដោះលែងឈ្មោះអ៊ា.ងួន ភ្លាមមួយរំពេចនោះបង្ហាញថាសេចក្តីសុចរិតផុះឡើងហើយ ។*

ឈ្មោះសុះនឹងឈ្មោះឡាយអ៊ីជាម្ចាស់ប្រាក់ ដើមបណ្តឹងរដ្ឋប្បវេណី មានការឈឺចាប់ណាស់ រត់ទៅពឹងមេធាវីមួយនឹងគេដែរ *ដើម្បីយកឈ្មោះអ៊ាងួនមកបញ្ចូលគុកវិញដល់ពេលកាត់សេចក្តី* ។ ហេតុតែចង់អោយគេជាប់គុកក្រៅក្របខណ្ឌច្បាប់ *បានទៅក្លែងលិខិតជាឯកជនដាក់* សេចក្តីថា ឈ្មោះអ៊ាងួន បានមកខ្ចីប្រាក់ ៥ ម៉ឺនរៀលដើម្បីយកទៅទិញក្របីមកអោយខ្លួន លិខិតនោះធ្វើនៅក្នុងពេលដែល ឈ្មោះអ៊ាងួនជាប់គុកបានពីរថ្ងៃ លោកមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីយកលិខិតនោះទៅដាក់ក្នុងសំនុំរឿង ដើម្បីទារសំណងប្រាក់ ៥ ម៉ឺនរៀលវិញដល់ថ្ងៃជំនុំជំរះកាត់សេចក្តី ពីរឿងនេះ លោកមេធាវីខាងដើមចោទ អាងទៅលើលិខិត *ឈ្មោះអ៊ា ងួនខ្ចីប្រាក់ ៥ ម៉ឺនជាបង្អែក លោកមេធាវីទី ២ របស់អ៊ាងួន សុំអោយលោកក្រាឡាបញ្ជី ធ្វើសេចក្តីកត់ហេតុថា លិខិតនោះជាលិខិតក្លែងទេ ព្រោះកាលបរិច្ឆេទលិខិតសញ្ញានោះឱ្យឃើញថា ឈ្មោះអ៊ាងួនចូលគុកបានពីថ្ងៃរួចមកហើយ ទើបធ្វើលិខិតសញ្ញាថា* ក្រោយភស្តុតាង គឺនៅលើដីការឃុំឃាំងឈ្មោះអ៊ាងួន អាច *បដិសេធលិខិតសញ្ញានោះ ដោយស្វ័យប្រវត្តិមិនអាចដើមបណ្តឹងរដ្ឋប្បវេណី ប្រកែកដោះសាដូចម្តេចបានឡើយ ។*

លោកចាងហ្វាង ក្រោយដែលបានស្តាប់មេធាវីខាងចោទនឹងមេធាវីខាងចំលើយ ឆ្លើយឆ្លងគ្នាចប់តុលាការវិនិច្ឆ័យសេចក្តីអោយឈ្មោះអ៊ាងួនបានរួចខ្លួនពីខចោទ ។ រឿងនេះបែរទៅជាឈ្មោះអ៊ា.ងួនដើមចោទវិញម្តង *ឈ្មោះសុះនឹងឈ្មោះ*

*ឡាយដឹងខ្លួនថាពិតជាគ្មានច្រករួចទេ បែរជាសុំទោសលោកអ៊ា.ងួនទៅវិញ លះបង់ប្រាក់៥ម៉ឺនរៀលចោល បើបណ្ដោយ* ឱ្យអ៊ា.ងួនប្ដឹងពិតជាជាប់គុកមិនខានឡើយ ។

ខ្ញុំដែលលើករឿងនេះមកនិទានគ្រាន់តែបញ្ជាក់បង្ហាញឱ្យឃើញថា លោកឃួន.ណៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើការ*រហ័សណាស់ គឺផ្លាស់ប្ដូរសុភាចារបុរសភ្លាម១ មួយរំពេចមានន័យថា លោកស្វែងរកសេចក្ដីយុត្តិធម៌ឱ្យជាតិភ្លាម១មិនឱ្យសំណុំរឿង*ដេកក្នុងការិយាល័យរបស់លោក៣ម៉ោងទេ លោកយកចិត្តទុកដាក់នឹងរដ្ឋការ ដូចជាការផ្ទាល់ខ្លួនរបស់លោក ។ ហើយចំពោះអ្នកធ្វើការវិញ គ្មានរតេតរតូតទេ ដល់ម៉ោងធ្វើការយ៉ាងជិតស្និត ហើយគ្មានដើរចេញទៅណាបានទេព្រោះ*មានភ្នាក់ងាររបស់លោកតាមតយតន់ជានិច្ច ម្ល៉ោះហើយការងាររដ្ឋការគ្មានខាតទាល់តែសោះគឺក្នុង១ថ្ងៃ៨ម៉ោងប្រាកដជា* ៨ម៉ោងពិតមែនចំណែកខ្លួនលោកវិញដូច្នោះដែរប្រតិបត្តិការ*ទៀងទាត់ណាស់* ។ ន័យមួយវិញទៀត លោកបានចាត់ការរៀបចំពេទ្យព្រះសង្ឃ បានទទួលលទ្ធផលយ៉ាងសមរម្យល្អណាស់បើអ្នកអានមានការសង្ស័យសូមទៅពិនិត្យផ្ទាល់ភ្នែកទៅចុះ *មុខជានឹងឃើញការពិត ដែលជាស្នាដៃរបស់* លោកពុំខានឡើយ គឺលោកពង្រីកកិច្ចការឱ្យចម្រើនជាលំដាប់ ។ នៅពេលដែលព្រះករុណា រំលាយរដ្ឋសភាលើកទី២ បង្កើតឱ្យមានក្រុមប្រឹក្សាជាតិ ខ្ញុំសូមបញ្ជាក់ថា មានព្រឹត្តិការណ៍ជាតិពីរធ្ងន់ធ្ងរណាស់ គឺប្រឹត្តិការណ៍ទី១ លោកឡើទូលាមកបញ្ជាក់សេចក្ដីសម្រេចជាដាច់ខាត តើរដ្ឋាភិបាលជាតិខ្មែរសុខចិត្តយកឯករាជ្យ ២៤៩០ឬទេ ? ក្នុងពេលលោកឃួន.ណៃ ធ្វើជាប្រធានទីព្រឹក្សាជាតិបាន

បានហៅខ្ញុំង៉ែត.ហៀន ទៅពិគ្រោះសម្ងាត់តែពីរនាក់សួរយោបល់ខ្ញុំថាម្ដេចទៅរឿងឯករាជ្យ ២៤៥នោះ ខ្ញុំឆ្លើយថា ចំពោះរូបខ្ញុំមិនព្រមយកឯករាជ្យ ២៤៥ជាដាច់ខាត ។ លោកឃួន.ណៃឆ្លើយមកខ្ញុំវិញថាយោបល់លោកពិតជាត្រូវណាស់នេះជាកលមធ្យោបាយរបស់អាណានិគមនិយមបារាំង ជាចុងក្រោយបំផុតបើយើងមិនព្រមយកឯករាជ្យ ២៤៥ នោះពិតជាជាតិយើងបានឯករាជ្យដូចប្រទេសឯទៀតដែរ ហើយលោកបញ្ជាក់ប្រាប់ខ្ញុំថា ឯករាជ្យនោះមិនបាច់មានកិច្ចសញ្ញាអ្វីទេ គ្រាន់តែប្រទេសបារាំងប្រកាសទទួលស្គាល់ថា ប្រទេសខ្មែរជារដ្ឋឯករាជ្យ វាស្រេចទៅហើយ ។

ហើយលោកសួរខ្ញុំថា ខ្លាចទីប្រឹក្សាជាតិឯទៀតយល់ខុសពីយើងពីរនាក់ បើដូច្នេះសូមលោកទៅស្ទង់មើល បើបានការយ៉ាងណាមកឱ្យដំណឹងខ្ញុំផង ។ ខ្ញុំក៏ទៅស្ដាប់ស្ទង់ទីប្រឹក្សាជាតិទាំងអស់ឃើញថា មានយោបល់ដូចលោកឃួន.ណៃនឹងខ្ញុំដែរ ខ្ញុំទៅជំរាបលោកវិញតាមដំណើរលោកមានសេចក្ដីត្រេកអរខ្លាំងណាស់ ហើយលោកលាន់មាត់ប្រាប់ខ្ញុំថា យើងជាមនុស្សនយោបាយ *ត្រូវមានចិត្តតស៊ូឱ្យបានដល់ទិសដៅរបស់ជាតិយើង ព្រោះពេលល្អគ្មានពីរដងទេ មានតែម្ដងគត់* ។

យើងជាមនុស្សនយោបាយ មិនត្រូវរឹងកំព្រិសដូចជាឈើនោះទេ ត្រូវទន់ដូចជាដើមត្រែង កាលណាខ្យល់បក់មកខ្លាំងត្រូវក្រាបដល់ដី កាលណាខ្យល់ហួសទៅត្រូវងើបមកវិញ សូមកុំភ្លេចគោលដៅរបស់ជាតិយើងដែលលោកអៀវ.កើសបានត្រួសត្រាយរួចមកឱ្យហើយសោះ ។

គោលដៅរបស់ជាតិនោះ *គឺឯករាជ្យបរិបូណ៌* នេះឯង តាមខ្ញុំស្មានព្រះ

ករុណាមុខជាផ្អែកលើទីប្រឹក្សាជាតិហើយ ហើយមុខជាមានសំបុត្រសួរមកខ្ញុំឱ្យឆ្លើយក្នុងរឿងនេះមិនខានឡើយ ។ ទីប្រឹក្សាត្រូវតែធ្វើសំណូមពរឬញត្តិបង្ហាញទឹកចិត្តយើងទៅឱ្យលោកឡឺទួណូដឹងវិញក្នុងឱកាស ដែលគេមកសួរបញ្ជាក់ផ្តាច់ព្រឹត្តនេះ ។

បន្ទាប់មកទីប្រឹក្សា បានទទួលសារពីព្រះករុណាពិតមែនគ្មានខុសពីសំដីលោកឃួន.ណៃសោះឡើយ ទើបទីប្រឹក្សាជាតិនាំគ្នាធ្វើញត្តិបង្ហាញទឹកចិត្តទីប្រឹក្សាជាតិថា មិនព្រមទទួលយកឯករាជ្យ ២៤ខនោះទេ សូមទទួលយកតែឯករាជ្យបរិបូរណ៍ដូចប្រទេសឥណ្ឌា ព្រះករុណាបានប្រគល់ញត្តិនោះឱ្យទៅលោកឡឺតូណូលោកនេះយកញត្តិនោះទៅឱ្យរដ្ឋាភិបាលបារាំង ។

ព្រឹត្តិការណ៍ទី ២ ក្នុងឱកាសលោកឡឺតូណូមកទស្សនាប្រទេសកម្ពុជានោះលោកញ៉ឹក.ជូឡុង ឱ្យទាហានទៅទទួលលោកឡឺតូណូ តិចពេក ព្រះករុណាចាប់ទោសលោកញ៉ឹក.ជូឡុងថាធ្វើឱ្យដាច់មិត្តភាពបារាំងខ្មែរ ដាក់រឿងនោះឱ្យរដ្ឋាភិបាលវិនិច្ឆ័យទោសគណៈរដ្ឋមន្ត្រីបានសម្រេចសេចក្តីត្រូវនិរទោសលោកញ៉ឹក.ជូឡុងចេញពីប្រទេសរួចទៅហើយ ។ ទើបយករឿងនោះ មកសុំសេចក្តីយល់ព្រមពីទីប្រឹក្សាជាតិបានចាត់លោកប៉ែន.នុតមកជាព្រះរាជដំណាង ។ គួរឱ្យអស្ចារ្យណាស់លោកឃួន.ណៃ បានសុំឱ្យអនុប្រធានដឹកនាំទីប្រជុំជំនួសបានចុះពីលើវេទិការប្រធានទីប្រឹក្សាជាតិ មកថ្លែងសេចក្តីសួរបញ្ជាក់ព្រះរាជ្យដំណាងថា សូមអនុញ្ញាតសូមឱ្យពិភាក្សាទៅចុះ ។ ទើបលោកឃួន.ណៃធ្វើអត្ថាធិប្បាយថាសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី គួរចាត់ទុកដូចជាសាលក្រមសាលាដំបូង តែតួក្តីម្ខាងគឺ

លោកញ៉ឹក.ជូឡុងប្ដឹងមកទីប្រឹក្សាជាតិ ទើបត្រឹមត្រូវតាមទំនងច្បាប់ រឿងនេះទៅជាព្រះករុណាដែលឈ្នះសេចក្ដីក្នុងជាន់សាលាដំបូង គឺសេចក្ដីសម្រេចគណរដ្ឋមន្ត្រីប្ដឹងមកសាលាឧទ្ធរណ៍ គឺទីប្រឹក្សាជាតិវិញ ដូចជាឃើញថាជាការមួយចំឡែកណាស់ ហើយថែមទាំងគ្មានក្នុងប្រពៃណីតុលាការផង ស្រាប់តែលោកសំសារីដែលមកជាមួយនឹងលោកប៉ែននុត ឡើងឆ្លើយជំនួសលោកប៉ែន នុតថា រឿងនេះពុំមែនតុលាការទេ គឺសេចក្ដីសម្រេចរបស់គណរដ្ឋមន្ត្រីទេតើ មកពីព្រះករុណាចង់ឱ្យមានសេចក្ដីយុត្តិធមិ តែម្យ៉ាងប៉ុណ្ណោះ បានជាស្នើសុំមកនេះ ។ លោកឃួន.ណៃឆ្លើយតបទៅវិញថាបើដូច្នោះបង្ហាញឱ្យឃើញថា ព្រះករុណាមានគោលដៅតែមួយ គឺចង់បានសេចក្ដីយុត្តិធមិតែម្យ៉ាងប៉ុណ្ណោះតើពិតមែនឬទេ លោកប៉ែន.នុតឆ្លើយថាពិតមែនហើយ បានជានាំរឿងនេះមកទីប្រឹក្សាសម្រេចម្ដងទៀត ។ លោកឃួន.ណៃឆ្លើយតបវិញថា បើដូច្នោះពិតមែន ក្នុងសំណុំរឿងតាមស្ដាប់សេចក្ដីរាយការណ៍របស់រដ្ឋាភិបាល គ្មានឃើញសេចក្ដីដោះសាររបស់លោកញ៉ឹកជូឡុងសោះ បើដូច្នេះធ្វើម្ដេចរកយុត្តិធមិឃើញ គួរតែទុកពេលវេលាឱ្យលោកញ៉ឹកជូឡុងដោះសារបានផង ទើបមានសេចក្ដីយុត្តិធមិ ។ ក្នុងពេលបន្ទាប់មកទៀត បើខ្ញុំង៉ែត.ហៀន ចាំមិនច្រឡំទេ ខ្ញុំសូមបំភ្លឺថា តាមច្បាប់រដ្ឋធម្មនុញ្ញនីរទេសបានតែក្នុងប្រទេស បើ នីរទេសទៅក្រៅប្រទេសនាំឱ្យមានការឆ្គងនឹងច្បាប់ ។ នៅទីបំផុតលោកឃួន.ណៃ ឡើងទៅលើវេទិកាវិញ ដឹកនាំទីប្រជុំតទៅទៀត លោកសួរថា គួរបង្អង់រឿងនេះ ទុកមួយអន្លើ ដើម្បីឱ្យលោកញ៉ឹកជូឡុងជូនសេចក្ដីដោះសារជាសំអាងឬទេ ? ទីប្រឹក្សាជាតិភាគច្រើន អនុមតិថាត្រូវតែទុកពេលជូន

លោកញ៉ឹកជូឡុងជូនសេចក្តី ដោះសារជាសំអាងសិន ។

ព្រឹត្តិការណ៍ដូចខាងលើនេះ គ្រាន់តែបញ្ជាក់បង្ហាញឱ្យឃើញថា លោកឃួន.ណៃ ជាអ្នករកសេចក្តីយុត្តិធម៌ឱ្យជាតិមួយរូបយ៉ាងសំខាន់ណាស់ ពិបាករកឥស្សរៈជនបែបនេះបានឡើយ ។ ទោះបីទីប្រឹក្សាជាតិខិតខំយ៉ាងណា ក៏ដោយឯករាជ្យបរិបូរណ៍នៅតែមិនបានសម្រេចឱ្យប្រទេសជាតិ ។ ព្រះករុណានរោត្តមស៊ីហនុ ស្តេចយាងទៅចរចារប្រទេសបារាំងម្តងទៀត ឥតបានលទ្ធផលមកឱ្យជាតិទេ ។ ម្តងនេះព្រះករុណាស្តេចយាងទៅសហរដ្ឋអាមេរិក ថ្លែងការឱ្យពួកនិស្សិតអាមេរិកាំងស្តាប់ ស្រាប់តែមានព្រឹត្តិការណ៍ភ្ញាក់ផ្អើលពេញសាកលលោកតែម្តងដល់ព្រះករុណាយាងទៅប្រទេសជប៉ុនថ្លែងការម្តងទៀត នាំឱ្យអាណានិគមនិយមបារាំង រញ្ជួយរង្គើគ្រប់សរសៃសរសូងតែម្តង ។ ម្តងនេះពន្លឺឯករាជ្យបរូបរិណ៍ចាប់ឃើញរូបរាងខ្លះហើយ ប៉ុន្តែនៅមិនបានសម្រេចទៀត ព្រោះបារាំងមិនព្រមប្រគល់ឯករាជ្យបរិបូរណ៍មកឱ្យប្រទេសជាតិខ្មែរទាល់តែសោះ ។ បារាំងចង់ឱ្យតែឯករាជ្យក្លែងក្លាយ ២៤មាត្រា ដូចមានលក្ខន្តិកឯករាជ្យនោះស្រាប់ហើយ សូមលោកអ្នកអានពិនិត្យឯករាជ្យ ២៤មាត្រា នោះមើលទៅចុះ ។ តើមានឱជារសបែបណាខ្លះរឿងនេះ ខ្ញុំម៉ែត.ហៀន ប្រឆាំងតាំងពីជំនុំគណកម្មការចម្រុះនោះម្ល៉េះ លោកអៀវ.កើសប្រឆាំងពីកាលនោះដែរ ហេតុនេះបានតែភ្នាក់ងារសម្ងាត់បារាំងតាមតែមនុស្ស ២នាក់ ។





លោក **សឺង-ង៉ុក ថាញ់** ជាចៅក្រមម្នាក់ផង នាយករដ្ឋមន្ត្រីផង ទាមទារឯករាជ្យលើកទី១ និងលើកទី២ ដរាបបានឯករាជ្យបរិបូរណ៍ឱ្យជាតិខ្មែរ ។

## វគ្គទី ១៤

ដល់ថ្ងៃលោក ស៊ឹង.ង៉ុកថាន់មនុស្សទោសនយោបាយ ត្រូវត្រឡប់មកប្រទេសកម្ពុជាវិញ ជាចៃដន្យស្របនឹងថ្ងៃលោកអ្នកុម្មសៀដឺរីរ៉េមុង ទទួលមរណៈភាព ដោយឃៀកមិញដែលជាបោយបម្រើរបស់លោកសម្លាប់ ។ លោកទា.ឆាយដឹងរឿងនោះមុនគេ រត់មកប្រាប់ខ្ញុំថា លោកអ្នកុម្មសេដឺរីរ៉េមុងស្លាប់ទៅហើយ មកបបួលខ្ញុំទៅមើលខ្មោចលោកដឺរីរ៉េមុង ។ ខ្ញុំង៉ែត.ហៀន ឆ្លើយតបទៅវិញថា មិនត្រូវទៅមើលទេ យើងមនុស្សអ្នកនយោបាយ នាំឱ្យគេមានការសង្ស័យមកលើយើងតាមអង្កេតពីយើងទៀត នាំឱ្យមានរវល់ឥតបានប្រយោជន៍អ្វីសោះ ។ករណីកិច្ចរបស់យើង ត្រូវទៅមើលផ្លូវ ដើម្បីរក្សាសន្តិសុខឱ្យលោកស៊ឹង.ង៉ុកថាន់ ទៅវិញ ។ លោកទា.ឆាយ និយាយមកកាន់ខ្ញុំទៀតថា លោកស៊ឹង.ង៉ុកថាន់ ពេញជាមនុស្សមានបុណ្យអស្ចារ្យណាស់ ព្រោះមានប្រផ្នូលល្អណាស់ដោយពួកឃៀកមិញវាចេះរើសថ្ងៃសម្លាប់លោកដឺរីរ៉េមុង ចំថ្ងៃដែលមនុស្សមានទោសមានសេរីភាពមកធ្វើនយោបាយវិញ ។ ម្តងនេះខ្ញុំជឿជាក់ថា ប្រទេសយើង ពិតជាបានឯករាជ្យបរិបូណ៌ហើយ ។ ខ្ញុំឆ្លើយតបទៅវិញថា នេះគ្រាន់តែជំនឿតាមផ្លូវចិត្តរបស់លោកប៉ុណ្ណោះទេ ការពិតមិនទាន់បង្ហាញយើងនៅឡើយទេ ។ លោកទា.ឆាយ បន្តវាចាទៅទៀតថាយីពូសន្ទនាលោកអៀវ. កើស និងលោកស្លាប់ពីរនាក់ទៅហើយ គឺលោក

អៀវ.កើស ស្លាប់មុនលោកអ្នកុម្មសៀដីរ៉ែមុងស្លាប់ក្រោយគិតទៅនៅតែលោក នឹងអ្នកដំណាងរាស្ត្រ៧នាក់ទៀត ។ ប្រហែលទេវតាទុកជីវិតលោកឱ្យឃើញឯករាជ្យបរិបូណ៌សិនទេដឹង ។ និយាយត្អាបណ្ដើរក្នុងរថយន្តចុះមើលសន្តិសុខបណ្ដើរ តាំងពីភ្នំពេញរហូតដល់វាលកប៉ាល់ហោះពោធិចិនតុង ដល់វាលកប៉ាល់ហោះហើយ គ្មានទាន់ឃើញនរណាទៅម្នាក់សោះមានតែខ្ញុំង៉ែត.ហៀននឹងលោកទា.ឆាយតែពីរនាក់គត់ មួយសន្ទុះមកទៀតលេចឃើញលោកម៉ែន.នុត ទៅដល់ជាលើកទី២ បន្ទាប់ពីខ្ញុំង៉ែត.ហៀននឹងលោកទា.ឆាយ ។

លោកប៉ែន.នុតអង្គុយតុផ្សេង បានបក់ដៃហៅខ្ញុំង៉ែត.ហៀននឹងលោកទា.ឆាយឱ្យទៅអង្គុយជិត ដើម្បីស្រួលដល់ការចចារគ្នា ពីរឿងលោកអ្នកុម្មសៀដីរ៉ែមុង ស្លាប់តែហោង ដោយឥតសមហេតុសមផលក្នុងពេលនោះខ្ញុំបំភ្លឺលោកប៉ែន.នុត តាមឱវាទព្រះពុទ្ធអង្គសម្ដែងថាមនុស្សនីមួយ១ ធ្វើអំពើយ៉ាងណាត្រូវតែបានផលវិបាកយ៉ាងនោះមកវិញ ។ បើដាំដើមក្រូចពិតជាបានផ្លែក្រូចទទួលទាន បើដាំដើមស្វាយពិតជាបានផ្លែស្វាយទទួលទានហើយ ។ ខ្ញុំបំភ្លឺដូចខាងលើនេះ លោកប៉ែន.នុតឆ្លើយមកខ្ញុំវិញថា តាមធម៌ត្រង់ចំណុចនេះគ្មានអ្នកណាកែបានទេ ។ មនុស្សមកទទួលលោកស៊ឺង.ង៉ុកថាន់កាន់តែច្រើនឡើង ដល់ម៉ោងត្រូវមកដល់ហើយ មិនឃើញកប៉ាល់ហោះមកសោះលោកទា.ឆាយភ្ញាក់ផ្អើលថា ម្ដេចក៏យ៉ាងនេះទៅវិញដូចជាចំឡែកណាស់ ប្រហែលបារាំងចាប់ទៅទៀតទៅហើយក៏មិនដឹង លោកប៉ែន.នុត ឆ្លើយថា ចាប់ម្ដេចកើតឡើងកប៉ាល់ហោះផុតមកហើយ យឺតដំណើរមកពីឈប់ហួសកំណត់ម៉ោងតាមផ្លូវទេ កន្លះម៉ោងមកទៀតបានឃើញ



## ឆា_ឆាយ

លោក **ឆា_ឆាយ** អ្នកដំណាងរាស្ត្រមណ្ឌលព្រៃវៀនទីរូមខេត្តកំពង់ចាម អ្នកយកពត៌មានពិសេសពីអាណានិគមនិយមបារាំងជាមួយម៉ែត.ហៀន ជូនលោក អៀវ.កើសប្រធានរដ្ឋសភា ក្នុងរឿងទាមទារឯករាជ្យ ។

កប៉ាល់ហោះមកដល់ពោធិចិនតុង ឃើញលោកស៊ុង.ង៉ុកថាន់ ចេញមកមុនគេ លើកដៃសំពះគោរពជាតិពីលើកប៉ាល់ហោះមក ខ្ញុំក្រឡេកទៅក្រោយ ឃើញដូច សមុទ្រមនុស្សតែម្តង នាំឱ្យខ្ញុំង៉ែត.ហៀន និងលោកទា.ឆាយរំភើបចិត្តឥត ឧបមា ។ ខ្ញុំង៉ែត.ហៀននិងលោកទា.ឆាយជិះរថយន្តមួយពីរនាក់មិនបានជូន ដំណើរលោកស៊ុង.ង៉ុកថាន់ ដល់ផ្ទះទេ បររថយន្តបង្ហួសទៅផ្ទះតែម្តង ។

ថ្ងៃស្អែកឡើងលោក ទា.ឆាយ មកហៅខ្ញុំទៅសួរសុខទុក្ខលោក ស៊ុង.ង៉ុក ថាន់ដល់ផ្ទះ ខ្ញុំឆ្លើយតបទៅវិញថា ទុកពេលឱ្យបងប្អូនរួមជាតិគេទៅសួរសុខទុក្ខ សិនចុះ ចាំមួយអាទិត្យទៀតចាំយើងទៅ ។ ដល់ថ្ងៃសន្យាខ្ញុំង៉ែត.ហៀននិងលោក ទា.ឆាយទៅតែពីរនាក់ បានឃើញលោកហុលវង្ស.អានុភាព ទើបនឹងចេញមកពី បន្ទប់លោកស៊ុង.ង៉ុកថាន់ ។ លោកស៊ុង.ង៉ុកថាន់ឱ្យមនុស្សបម្រើមកហៅខ្ញុំ ង៉ែត.ហៀននិងលោកទា.ឆាយចូលទៅ ខ្ញុំជំរាបលោកថានេះលោកទា.ឆាយជាមិត្ត របស់ខ្ញុំធ្វើតំណាងរាស្ត្រ ចំពោះរូបខ្ញុំវិញមិនបាច់ជំរាបលោកទេ លោកស្គាល់ស្រាប់ ទៅហើយ ។

លុះសួរសុខទុក្ខគ្នារួចហើយលោកទា.ឆាយជំរាបលោកថា ខ្ញុំនេះហើយ ដែលរងគ្រោះជាមួយលោកអៀវ.កើស លោកហាក់ដូចជាភ្ញាក់ខ្លួន ហើយសួរខ្ញុំពី បុព្វហេតុ ខ្ញុំរាយការណ៍ជំរាបតាមដំណើរដូចជំរាបអ្នកអានរួចមកហើយពីខាង លើ ។ រួចខ្ញុំសួរទៅលោកម្តង លោកបញ្ជាក់ប្រាប់ខ្ញុំកាលនៅឯប្រទេសបារាំង ឆ្លៀតរៀនច្បាប់បានសញ្ញាប័ត្រមួយថែមទៀត បារាំងគេឱ្យជ្រើសរើសកន្លែងនៅ បើចង់នៅប្រទេសបារាំង គេជួយគាំទ្រតាមរបៀបនៅប្រទេសបារាំង បើចង់

ត្រឡប់មកប្រទេសខ្មែរវិញ គេអនុញ្ញាតឱ្យមក ប៉ុន្តែសូមកុំឱ្យធ្វើនយោបាយតទៅទៀត ។ លោកប្រាប់បារាំងថា លោកត្រូវទៅប្រទេសខ្មែរវិញ គេព្រមអនុញ្ញាតឱ្យមក រួចលោករាយការណ៍ប្រាប់ខ្ញុំតាំងពីនៅប្រទេសសៀមរហូតដល់ប្រទេសជប៉ុនមួយចប់ ។ ហើយសួរខ្ញុំពីបុព្វហេតុកើតឥស្សរៈ ក្នុងប្រទេសយើង ខ្ញុំង៉ែត.ហៀនរាយការណ៍ជំរាបលោកតាមដំណើរថា រឿងនេះមុនដំបូងឡើង អ្នករដ្ឋការបារាំងចាប់ឯកឧត្តមបានចំនួន ៣ថ្ងៃ ខ្ញុំង៉ែត.ហៀន ១ លោក រស់.សារ៉េត ១ លោក ធា.ឡេង ១ នៅឯស្រុកត្បូងឃ្មុំ មានការឈឺចាប់ផ្លូវចិត្តខ្លាំងពេក ព្រោះឃើញគេប្រមាទនាយរដ្ឋមន្ត្រី ជាដំណាងជាតិខ្មែរទាំងមូលត្រូវតែប្រើកម្លាំងតទល់វិញ យើងខ្ញុំទាំង ៣នាក់តាំងគណកម្មាធិការនៅវត្តវិហារទទឹមប្រមូលស្បៀងនិងអាវុធដើម្បីប្រើកម្លាំងតទល់នឹងអាណានិគមនិយមបារាំង ទើបគណកម្មាធិការនោះចាត់ខ្ញុំង៉ែត.ហៀន និងលោករស់.សារ៉េត ឱ្យទៅទាក់ទងនិងលោកអភិបាលខេត្តកំពង់ចាម ចៅសែនកុសលមុនដំបូងយើងខ្ញុំទាំង ២ នាក់ ទៅជួបលោកបាឡាត់ខេត្តព្រុំសួលដើម្បីឱ្យស្នើនិងលោកអភិបាលខេត្ត តើលោកយល់ព្រមតទល់នឹងអាណានិគមនិយមបារាំងទេ ? លោកចៅសែនកុសលជាមនុស្សស្នេហាជាតិមួយរូបពិបាកនិងរកបាន ទទួលយល់ព្រមមួយរំពេច បានចាត់លោករស់.សារ៉េតឱ្យទៅភ្នំពេញដើម្បីនឹងសួរឥស្សរៈជនធំៗ មានលោកលន់.នល់ ជាដើម ។ ឥស្សរៈជនធំៗ នៅភ្នំពេញ មិនយល់ព្រមតាមទេ ព្រោះយល់ថាបើធ្វើតាមរបៀបនោះវាស្លាប់ពលរដ្ឋច្រើនណាស់ ហើយថែមទាំងមិនឈ្នះគេផង ព្រោះយើងគ្មានអាវុធផង មិនចេះច្បាំងផង នាំឱ្យហិនហោចភោគសម្បត្តិក្នុងប្រទេសជាការឥតប្រយោជន៍នាំឱ្យ

ប្រជា រាស្ត្ររិតតែរងទុក្ខខ្លាំងទៅទៀត ។

ចំពោះលោកស៊ឹង.ង៉ុកថាន់នាយករដ្ឋមន្ត្រីយើង គង់តែថ្ងៃណាមួយរួចមកវិញទេ ហើយឯករាជ្យប្រទេសយើង កំពុងទាមទារតាមសន្ធិវិធីពីបារាំងដែលមកថ្មីនេះ គេឱ្យជាតិយើងមានស្វ័យភាពចាត់ការក្នុងប្រទេស ស្រេចតែជាតិយើងចុះ គឺយើងត្រួតត្រាគ្នាឯង ហាក់ដូចឱ្យស្លាបម្ខាងមកយើងហើយ ស្លាបម្ខាងទៀតកិច្ចការបរទេស នៅលើគេបណ្ដោះអាសន្ន ។ កាលណាយើងចេះដឹងគ្រប់គ្រាន់គេឱ្យយើងថែមទៀត ។ លោកចៅសែនកុសលពួសំដីលោករស់-សារេត រាយការណ៍ជំរាបដូចខាងលើនេះ ខឹងតូងតែម្ដង ។ ចាប់ទូរស័ព្ទនិយាយទៅ លោកញឹក-ជូឡុង ភ្លាម និយាយជាភាសាបារាំងខ្ញុំស្ដាប់មិនបានទេ ប៉ុន្តែលោកយល់ថាពួកឥស្សរជននៅភ្នំពេញចាញ់បោកបារាំងទៀតហើយ ។ លោកនិយាយថាពេលល្អមានតែមួយនេះទេ ពួកយួនគេវាយបារាំងចេញមុខ បើជាតិយើងវាយទៀតវាបានកន្លែងឯណានឹងជ្រក ខ្លាវាស្លាប់ទៅហើយមិនត្រូវខ្លាចស្បែកខ្លាទេ ពួកយើងត្រូវប្រើកម្លាំងទៅទៀត ។

ខ្ញុំបាទនេះមេធ្វើមគំនិតជាមួយលោករស់-សារេត និងលោក ផាងឡេងបានយកពាក្យលោក លន់-នល់ នឹងលោកចៅសែនកុសល មកពិចារណាថ្លឹងមើលខ្ញុំបាទយល់ថាពាក្យលោក លន់-នល់ ឱ្យអត្ថប្រយោជន៍ទៅលើជាតិច្រើនជាង ។

ពាក្យលោកចៅសែនកុសល ប្រកបទៅដោយព្រោះផ្ដាច់ដល់ជាតិណាស់ហើយខ្ញុំបានស្គាល់ឧត្តមគតិ លោក លន់-នល់ ច្រើនជាង ព្រោះមនុស្សនេះគិតអ្វីមិនសូវខុសទេ លោក ចៅសែនកុសល មានឧត្តមគតិខ្ពស់ជាងពិតមែនហើយ

ប៉ុន្តែធ្វើការដើម្បីប្រយោជន៍ជាតិ ទៅជានាំជាតិឱ្យវិនាសអន្តរាយទៅវិញ ដូចជាមិនសមហេតុមិនសមផល ហើយអាកប្បកិរិយារបស់លោកប្រកបដោយសេចក្តីខឹងច្រើនណាស់ផង ខ្វះការអំណត់អត់ធ្មត់បើពួកខ្ញុំបានទៅធ្វើជាមួយ ពិបាកនឹងស្តាប់គ្នាណាស់ ខ្ញុំថាបើដូច្នេះលោកអភិបាលខេត្ត ត្រូវចាត់វិធានការដូចម្តេចទៅវិញ លោកថាត្រូវតែទៅស្រុកយួនលើកទ័ពពីខាងនោះមកវិញ ចំណុចនេះខ្ញុំបាទគ្មានចាប់អារម្មណ៍ទាល់តែសោះ ខ្ញុំនឹកក្នុងចិត្តថា អណ្តើកនៅនឹងជើង បែរទៅក្តក់ហៅផ្តៃវិញ តាមយោបល់ខ្ញុំបាទនឹងលោករស់សារេត បើលោកយល់ព្រមវាយបារាំងក្នុងស្រុកខ្មែរ ខ្ញុំទាំងពីរនាក់សុខចិត្ត ព្រោះបារាំងមកក្នុងពេលនោះគ្មានច្រើនទេ មានមិត្តជប៉ុនជួយគាំទ្រជាកម្លាំងថែមទៀត ព្រោះពេលនោះជប៉ុនទៅមិនទាន់អស់ទេ លុះខ្វែងមតិគ្នាដូច្នេះ ខ្ញុំបាទនឹងលោករស់.សារ៉េតត្រឡប់ទៅស្រុកត្បូងឃ្មុំវិញ រំលោយគណកម្មាធិការចោលទៅរំលងពីរថ្ងៃលោកចៅសែនកុសលអភិបាលខែត្រកំពង់ចាម នាំអ្នករដ្ឋការធ្វើឥស្សរៈឯប្រទេសវៀតណាមស្រាប់តែថ្ងៃក្រោយទៅអ្នកនៅភ្នំពេញ រត់ទៅធ្វើឥស្សរៈនៅខាងបាត់ដំបងតទៅទៀតមានអាយុជីវិតមកដល់សព្វថ្ងៃនេះ ។ លោកស៊ុង.ង៉ុកថាន់ស្តាប់សេចក្តីរាយការណ៍របស់ខ្ញុំ ង៉ែត.ហៀន ចប់ហើយឆ្លើយមកវិញថា ស្តាយណាស់ជាតិមិនមូលគ្នាដោយឥតមានវិធានការគិតទុកជាមុន បើធ្វើពេលនេះពិតជាមតិស្មោកលលោកភ្ញាក់ផ្អើលខ្លាំងណាស់ ។ ខ្ញុំង៉ែត.ហៀនជំរាបទៅលោកថា ប្រទេសយើងសព្វថ្ងៃនេះក្រណាស់ សូមលោកនាយកមេត្តារកមធ្យោបាយជួយរដ្ឋាភិបាលលោកប៉ុយកន្ទួលផង ព្រោះរដ្ឋាភិបាលនេះ កំពុងបន្តសកម្មភាពទាមទារឯករាជ្យបរិបូណ៌តាមទីដៅគណ

បក្សប្រជាធិបតេយ្យដែលមានលោកអៀវ.កើសជាអ្នកដឹកនាំ ។ លោកស៊ឹង.ង៉ុក ថាន់ឆ្លើយមកខ្ញុំវិញថា យើងពិបាករៀបស្រុកទេសបន្តិចហើយ ព្រោះប្រទេសយើង មិនទាន់បានឯករាជ្យបរិបូរណ៍ ។ បើជាតិបានឯករាជ្យបរិបូណ៌ តែយើងធ្វើ នយោបាយត្រូវល្អ ពិតជាជាតិយើងគ្មានក្រកើតទេ ខ្ញុំគ្រាន់តែលើកយកគោលការ មួយមកបង្ហាញលោកថា មុនដំបូងយើងត្រូវទាក់ទងនឹងបរទេសមានសហរដ្ឋ អាមេរិកជាដើម ឱ្យសមាគមគេមកធ្វើធនាគារចងការប្រាក់ នៅប្រទេសយើងឱ្យ បានគ្រប់ខែត្រជនជាតិយើងដែលទាល់ក្រ អាចទៅរកខ្ចីប្រាក់នោះពីធនាគារគេ បាន បើមានវត្ថុធានាត្រឹមត្រូវតាមច្បាប់ប្រាក់នោះការថោកណាស់ ក្នុង១ឆ្នាំការ ត្រឹមតែ ៥ភាគរយទេ ខុសការប្រាក់ក្នុងប្រទេសយើង ដែលពួកនាយទុនចងការ ក្នុង១ខែ ៥ភាគរយទៅវិញ មានអ្នកខ្លះយកចងការ១២ភាគរយក្នុង១ខែទៀតផង ឃើញថាការប្រាក់នោះវាធ្ងន់ណាស់ បើយកតែ៥ភាគរយក្នុង១ឆ្នាំវិញ ឃើញថា មានចំណេញច្រើនណាស់ព្រោះក្នុងមួយឆ្នាំយើងចំណេញ ៥៥រទៅហើយ បើការ ប្រាក់ ១២រ ទៅវិញក្នុងមួយឆ្នាំយើងចំណេញ ១៣៩រទៅហើយ ។ បើធ្វើរបៀប នេះជនបរទេសគេមានចំណេញខ្លះ ជនជាតិយើងមានចំណេញខ្លះ គិតទៅគិតមក ប្រហែលធ្វើកើត ។

បន្ទាប់មកទៀតបើជនជាតិយើងគ្មានវត្ថុធានាប្រាក់ទេ ប៉ុន្តែចង់បានប្រាក់ នោះទៅពង្រីកមុខរបររបស់ខ្លួនពិតប្រាកដត្រូវតែអ្នករដ្ឋការយើង ធានារ៉ាប់រងឱ្យ ខាងតែបានប្រាក់ យកទៅរកទទួលទាន ។ តពីនោះទៅទៀត ត្រូវអ្នករដ្ឋការយើង ជួយឧបត្ថម្ភឱ្យពេញកម្លាំង ចំពោះអ្នកដែលយកទៅរកទទួលទាននោះឧបមាយក

ធ្វើរោងចក្រត្រូវរោងចក្រនោះដើរឱ្យបានស្រួល កុំឱ្យខាតបានបើយកទៅធ្វើកសិកម្មត្រូវជួយអ្នកកសិករឱ្យបានផលច្រើនដោយវិធីប្រើជី ដោយប្រើតាមរបៀបថ្មីបើធ្វើពាណិជ្ជកម្ម ត្រូវជួយផ្តល់មធ្យោបាយគ្រប់យ៉ាង ។ តាមខ្ញុំបាទស្មានមើលទៅថ្ងៃក្រោយអស់នាយទុនចងការប្រាក់៥ភាគរយក្នុង១ខែតទៅទៀតហើយនាយទុនធំៗ មិនអាចទុកប្រាក់ឱ្យនៅទំនេរឥតមានការប្រាក់នោះទេ មុខជាយកប្រាក់ទៅដាក់ធានាគារជាតិគ្រប់គ្នា ដើម្បីយកចុងការប្រាក់ឱ្យបានទៀងទាត់ប្រទេសជាតិត្រូវតែចំណេញមួយកម្រិតទៀតយ៉ាងខ្ពស់ ។ ខ្ញុំសង្ឃឹមថា បើធ្វើរបៀបនេះពិតជាលើកជីវភាព ប្រជាពលរដ្ឋគ្រាន់បើជាងមុនឆ្ងាយណាស់ ។ មានមធ្យោបាយធ្វើឱ្យរាស្ត្រយើងមានទ្រព្យសម្បត្តិជាច្រើនទៀត នេះមានច្រើនណាស់ . . . ។ លោកស៊ឹង.ង៉ុកថាន់បន្តវាចារតទៅទៀតថា មធ្យោបាយនេះបើប្រទេសយើងមិនទាន់ឯករាជ្យទេ យើងគ្មានសិទ្ធិធ្វើបានទេ បារាំងមិនព្រមឱ្យបរទេសណា ចូលមកក្នុងប្រទេសយើងបានឡើយ ។ មានន័យថាខេមរៈជាតិយើងខ្ញុំតែក្រៅផ្ទះត្រូវតែជាតិយើងប្រឹងតស៊ូមួយកម្រិតទៀត ។ ខ្ញុំង៉ែត.ហៀននិងលោកទា.ឆាយត្រឡប់ទៅផ្ទះវិញ លោកទា.ឆាយចេះតែសរសើរលោកស៊ឹង.ង៉ុកថាន់មិនដាច់ពីមាត់សោះថា"ខ្ញុំតាំងពីកើតមកគ្មានពូនរណាបញ្ចេញគំនិតបែបនេះសោះ ។ ទើបតែលោកអៀវ.កើសនិងលោកស៊ឹង.ង៉ុកថាន់មានគំនិតប្លែក ធ្វើម្តេចឱ្យបានគំនិតនេះទៅជាគំនិតរបស់រដ្ឋាភិបាលជាប្រទេសយើងរុងរឿងមិនខានឡើយ ។

រំលងប្រហែល ៣ខែមកខ្ញុំង៉ែត.ហៀន នឹងលោកទា.ឆាយទៅជួបម្តងទៀត ស្រាប់តែលោកស៊ឹង.ង៉ុកថាន់មានប្រសាសន៍ថា គិតនាំគ្នាធ្វើបាតុកម្មទាម

ទារឯករាជ្យបរិបូរណ៍ពីបារាំង ត្រូវប្រើសន្តិវិធីតាមសណ្តាប់ធ្នាប់ ខ្ញុំង៉ែត.ហៀន និងលោកទា.ឆាយ យល់ព្រមតាមទាំងអស់ ។ ខ្ញុំង៉ែត.ហៀន និងលោកទា.ឆាយ ត្រឡប់មកផ្ទះវិញ ពិភាក្សាគ្នាលោកទា.ឆាយថា មុខជាមានគ្រោះថ្នាក់មិនខាន ឡើយ បើធ្វើបាតុកម្មពិតមែន ។ ចំណែកខ្ញុំង៉ែត.ហៀនយល់ផ្ទុយស្រឡះពីលោក ទា.ឆាយ ខ្ញុំយល់ថាឥតមានធ្វើបាតុកម្មទេ គ្រាន់តែនិយាយចោលជើងឱ្យបារាំង ចាប់អារម្មណ៍តែប៉ុណ្ណោះ ការពិតទៅវិញ លោកស៊ឺង.ង៉ុកថាន់ រត់ទៅប្រើកម្លាំង យុទ្ធវិធីទៀតហើយ ។ លោកទា.ឆាយមិនជឿខ្ញុំទាល់តែសោះ ខ្ញុំរំលឹកឡើងវិញថា រឿងមុនៗខ្ញុំធ្វើគ្រូទាយមិនខុសទេ ដូចយ៉ាងរំលាយរដ្ឋសភាលើកទី១ ខ្ញុំទាយថាបើ សមាជិករដ្ឋសភាសួរដេញដោលរដ្ឋមន្ត្រីពិតជាមានការរំលាយរដ្ឋសភាហើយលោក ភ្លេចហើយឬនៅ នេះហើយគេហៅថាកលមធ្យោបាយរបស់អ្នកនយោបាយ ។ លោក ទា.ឆាយជឿខ្ញុំខ្លះមិនជឿខ្លះស្រាប់តែថ្ងៃលោកស៊ឺង.ង៉ុកថាន់រត់ចូលទៅ ខែត្រសៀមរាបថា ខ្ញុំទាយត្រូវណាស់មកបបួលខ្ញុំរត់ទៅជាមួយគ្នា ។ ខ្ញុំថាបើខ្ញុំ បាក់ជើងយ៉ាងនេះ បើខ្ញុំទៅមុខជាស្លាប់មិនខាន ត្រូវនៅធ្វើនយោបាយក្នុងប្រទេស តទៅទៀត ។

លោកស៊ឺង.ង៉ុកថាន់រត់ចូលព្រៃ មានប្រតិកម្មក្នុងប្រទេសសម្បើមណាស់ នាំឱ្យអាណានិគមនិយមបារាំងភ្ញាក់ផ្អើលយ៉ាងក្រៃលែង មិនគ្រាន់តែប៉ុណ្ណោះទេ រដ្ឋការខ្មែរក៏ដូច្នោះដែរ ។ ខ្ញុំប្រាប់លោក ទា.ឆាយ ទៀតថា រដ្ឋមន្ត្រីលោក ហ៊ុយ.កន្ធុល ត្រូវតែរលំ រដ្ឋសភាត្រូវតែរលាយហើយម្តងនេះ ។ លោកទា.ឆាយ ឆ្លើយមកខ្ញុំវិញថា ព្រះករុណាបានស្បថនៅវត្តឧណ្ណាឡោមរួចហើយថា មិនរំលាយ

រដ្ឋសភាជាដាច់ខាត បើរំលំរដ្ឋមន្ត្រីប្រហែលមានមែន ឯរដ្ឋសភាពិតជាគ្មានរំលាយទេ ។ ខ្ញុំឆ្លើយតបទៅវិញថា ព្រះករុណាពុំមែនទៅក្រោមសម្តេចសង្ឃនាយកទេ នៅក្រោមអ្នកកុម្មុយនិស្តបារាំង ព្រោះព្រះអង្គធានារ៉ាប់រងនិងលោកវ៉ាងសង់អ្នូរីយ៉ូលធ្ងន់ណាស់ ចំពោះលោកស៊ឹង.ង៉ុកថាន់ ។

បើព្រះករុណា មិនរំលំគណរដ្ឋមន្ត្រីមិនរំលាយរដ្ឋសភាទេ មុខជាអាណានិគមនិយមបារាំង វាចោទប្រកាន់ព្រះអង្គថា ទៅបញ្ឆោតរដ្ឋាភិបាលបារាំង យកលោកស៊ឹង.ង៉ុកថាន់ មកប្រឆាំងនឹងបារាំងទៅវិញ ខ្ញុំនិយាយយ៉ាងនេះ លោកទា.ឆាយ ដូចជាស្តាប់ ។

បន្ទាប់ពីនោះមកទៀត ព្រះករុណានរោត្តមសីហនុយាងទៅធ្វើសកម្មភាពនៅប្រទេសសៀម បានចាត់មនុស្សឱ្យទៅអញ្ជើញលោក ស៊ឹង.ង៉ុកថាន់ មកជួបដើម្បីប្តូរយោបល់គ្នាពីរឿងឯករាជ្យនេះ ។ ប៉ុន្តែមិនបានសម្រេចដូចបំណងទេ ត្រឡប់មកវិញរំលំរដ្ឋាភិបាលនិងរំលាយរដ្ឋសភា ហើយចាប់អ្នកតំណាងរាស្ត្រដាក់គុក ខ្ញុំង៉ែត.ហៀនធ្វើជាមេធាវីការពារគ្រប់រឿងទាំងអស់ អ្នកតំណាងរាស្ត្រនឹងរដ្ឋការឯទៀតមានលោកឃីន.ឆៃជាដើមប្រហែល ៤០នាក់ លោកទា.ឆាយចេញពីទីឃុំឃាំងមកមានជំងឺឈឺស្លាប់តែម្តង ពេលដែលស្លាប់ដេកលើភ្លៅខ្ញុំនៅពេទ្យខេមរា ។ ព្រះមហាក្សត្រិយតាំងទីប្រឹក្សាជាតិមួយជំនួសរដ្ឋសភា រួចព្រះអង្គយាងទៅធ្វើសកម្មភាពនៅខេត្តបាត់ដំបងជាមួយលោកលន់.នល់ អភិបាលខេត្តបាត់ដំបង ពួកទាហានរត់ចោលរដ្ឋាភិបាលលោកប៉ែន.នុត នាំឱ្យបារាំងអាណានិគមនិយមភ័យស្លន់ស្លោយ៉ាងក្រៃលែង ។ សុំឱ្យរដ្ឋាភិបាលស្តេចយាងព្រះករុណាវិល

ត្រឡប់មកកាន់រាជធានីវិញ ក្នុងពេលនោះព្រះករុណានឹងបារាំងចរចាគ្នាជាសម្ងាត់ ស្រាប់តែចេញមកវិញព្រះករុណាថ្លែងការណ៍ ឱ្យមហាជនដឹងថា ព្រះអង្គនឹងទាមទារយកឯករាជ្យបរិបូរណ៍ឱ្យបានកំណត់រយៈវេលាពាឆ្នាំ គិតពីថ្ងៃនេះតទៅមុខ បើមិនបានទេ សុំឱ្យប្រជាពលរដ្ឋវិនិច្ឆ័យសេចក្តីធ្វើទោសព្រះអង្គចុះ ។

ចំណុចត្រង់នេះ ខ្ញុំសុំបើកវង់ក្រចកមួយ( គំនិតដែលទាមទារឯករាជ្យបរិបូរណ៍នោះ មានតាំងពីឆ្នាំ១៩៤៩នោះម្ល៉េះ គឺច្រើនដំណាក់ណាស់ហើយ អង្គការរដ្ឋគឺរដ្ឋសភាខាងគណបក្សប្រជាធិបតេយ្យ មិនយល់ព្រមយកឯករាជ្យ ២៤ខ ។ ដល់រំលាយរដ្ឋសភា ធ្វើជាទីប្រឹក្សាជាតិទៀត មានលោកឃួន.ណៃជាអ្នកដឹកនាំ នៅតែមិនព្រមយកឯករាជ្យ ២៤ខនេះទៀត ។ ដល់លោកស៊ឹង.ង៉ុកថាន់ត្រឡប់មកវិញ ធ្វើសកម្មភាពប្រឆាំងយ៉ាងអស្ចារ្យ មិនព្រមទទួលជួបចរចានឹងព្រះករុណាដែលជាអ្នកនាំពាក្យអាណានិគមនិយមបារាំង មិនព្រមយកឯករាជ្យ ២៤ខនេះទៀត ព្រោះលោកយល់ថាព្រះករុណាសីហនុជាកូនជឹងបារាំង មានឧត្តមគតិតែមួយទេ ។ ព្រះអង្គយល់ឃើញថាប្រជាពលរដ្ឋទាំងអស់ ចង់បានឯករាជ្យបរិបូរណ៍ពិតមែន ទើបព្រះអង្គលះបង់ព្រះរាជវាំងទៅទាមទារតវ៉ាជាទីកចុងក្រោយបំផុត ។ ទើបបារាំងព្រមសុខចិត្តឱ្យឯករាជ្យបរិបូរណ៍ដល់ប្រទេសកម្ពុជា បាននៅឆ្នាំ ១៩៥៣ ខ្ញុំសុំបញ្ជាក់ថែមទៀតថា: ឯករាជ្យនោះប្រទេសខាងលោកកុម្មុយនិស្តគ្មានប្រទេសណាមួយ ទទួលស្គាល់ឯករាជ្យប្រទេសកម្ពុជាទេ ។ មានតែបក្សខាងលោកសេរី បើរិះគន់តាមទំនងនេះទៅ ឃើញថាបក្សខាងលោកសេរីជួយគាំទ្រប្រទេសកម្ពុជាមុនបក្សលោកកុម្មុយនិស្ត ។ លុះដល់ឆ្នាំ ១៩៥៤ ទើបបារាំងឱ្យ

ឯករាជ្យប្រទេសកម្ពុជា ម្តងទៀតក្រោយសន្និសីទហ្សឺណែវ បក្សកុម្មុយនិស្តព្រម ទទួលស្គាល់ បានចូលទៅក្នុងអង្គការសហប្រជាជាតិប្រទេសកម្ពុជាយើងបាន ប្រកាសកាន់មាគ៌ានយោបាយអព្យាក្រិតភាព មានន័យថា យកបក្សទាំង២ គឺ លោកសេរីនិងលោកកុម្មុយនិស្តមកជាមិត្ត បក្សកុម្មុយនិស្តអរណាស់ ព្រោះបាន ជ្រៀតចូលមកផ្សាយលទ្ធិរបស់កុម្មុយនិស្តរបស់ខ្លួនក្នុងប្រទេសកម្ពុជាបាន ។ ប៉ុន្តែ ពេលនោះរដ្ឋមន្ត្រីការបរទេសអាមេរិកកាំង ឈ្មោះប៉ុលស្ទែរឌុលលិស បានធ្វើបក្ស ការពារទ្វីបអាស៊ីមួយ ហៅថាបក្សសេអាតូ សម្រាប់ការពារកុំឱ្យកុម្មុយនិស្ត រាល ឆ្លងផ្សាយឥទ្ធិពលពីប្រទេសចិន ចូលមកក្នុងជ្រោយសុវណ្ណភូមិបាន ។

នៅក្នុងឆ្នាំ ១៩៥៤ ខែ កក្កដា ប្រទេសកម្ពុជាយើងបោះឆ្នោតជ្រើសយក របបគ្រប់គ្រងរដ្ឋ តាមសន្និសីទហ្សឺណែវ ក្នុងពេលនោះគណបក្សប្រជាធិបតេយ្យ ធ្វើសមាជដើម្បីជ្រើស គណកម្មាធិការនាយកថ្មី ចូលទៅប្រកួតប្រជែងក្នុងការ បោះឆ្នោតជ្រើសយករបបគ្រប់គ្រងរដ្ឋ ។ ក្រុមប្រជាជនខ្មែរក្រហម និងក្រុមខ្មែរ សេរី ខ្មែរខៀវ បានចូលមករួបរួមក្នុងគណបក្សប្រជាធិបតេយ្យ ព្រោះមានឧត្តម គតិដូចគ្នា មកពីមិនព្រមយកឯករាជ្យក្លែងក្លាយ ២៤៩ ដូចគណបក្ស ប្រជាធិបតេយ្យដែរ គណបក្សប្រជាធិបតេយ្យចាត់ទុកខ្មែរឥស្សរៈ ដែលអ្នកត ដោយកម្លាំងអាវុធជាជើង ម្ខាងរបស់ប្រទេសកម្ពុជា ធ្វើដំណើរទៅមុខនិង ជើងម្ខាងទៀតអ្នកតស៊ូដោយ សន្តិវិធី គឺកម្លាំងនយោបាយក្នុងផ្លូវច្បាប់ ។

អគ្គលេខាធិការខែត្រ និងអគ្គលេខាធិការស្រុកបានមករួមប្រជុំគ្នា ដើម្បី ជ្រើសតាំងគណកម្មាធិការនាយកគណបក្សប្រជាធិបតេយ្យ ដើម្បីបោះឆ្នោត ។

សមាជភាគច្រើនបញ្ចេញសេចក្ដីទុកចិត្តទៅលើវរជនក្មេងៗ នាំឱ្យវរជនចាស់ៗ មិនសប្បាយចិត្តជាខ្លាំង កើតជាការបែកបាក់គ្នាមួយភាគតូច ។ ចំណែកខ្ញុំ



លោក ស៊ឹម_វ៉ា

ង៉ែត.ហៀនចូលក្នុងចំណោមវរជនចាស់ៗ ព្រោះធ្វើនយោបាយពីរទឹកមកហើយ ធ្លាប់ជួបប្រទះនឹងឧបសគ្គរបស់ជាតិធំៗ ជាច្រើនលើកកាលជំនាន់នគរវត្តម្តង កាលជំនាន់គណបក្សប្រជាធិបតេយ្យម្តង ។ ពេលនោះលោកសឹម.វ៉ាលាចេញពីគណបក្សប្រជាធិបតេយ្យដោយអន់ចិត្តនឹងវរជនក្មេងៗ ធ្វើគណកម្មាធិការនាយក ព្រោះលោកយល់ថាពួកក្មេងៗ ដឹកនាំគណបក្សប្រជាធិបតេយ្យមិនកើត ព្រោះខ្វះការពិសោធន៍ច្រើនណាស់ ។

អស់លោកវរជនក្មេងៗ បានមកដឹកនាំគណបក្សប្រជាធិបតេយ្យ តាមខ្ញុំសង្កេតមើលឃើញថាមានទម្ងន់ស្រាលណាស់ ព្រោះខ្វះមិនស្គាល់ទឹកចិត្តរាស្ត្រ ហើយថែមទាំងមិនព្រមស្តាប់ឥស្សរៈជនចាស់ៗ ទៀតផង ។

ក្នុងការជ្រើសបេក្ខជន ខ្ញុំឥតភ័ព្វសំណាងបានធ្វើបេក្ខជននឹងគេទេ ប៉ុន្តែខែត្រសៀមរាប គ្មាននរណាម្នាក់ទៅឈរឈ្មោះសោះ ព្រោះគេខ្លាចអំណាចដាបឈូន ដោយដាបឈូនខាងសង្គមរាស្ត្រនិយមបានសម្លាប់កៅ.តតផង ។ លោកមិញណាត្រីបានដល់ផ្ទះខ្ញុំនិយាយសូមអង្វរឱ្យខ្ញុំង៉ែត.ហៀនទៅឈរឈ្មោះនៅស្រុកកំពង់ក្តី ដើម្បីបង្គ្រប់ចំនួនកុំឱ្យឃើញថា គណបក្សធំរកមនុស្សទៅឈរឈ្មោះមិនបាន នាំឱ្យអាប់ឱនដល់គណបក្ស ។

ខ្ញុំយល់ព្រមទៅ ប៉ុន្តែគ្មានសេចក្តីសង្ឃឹមអ្វីទាល់តែសោះ ។ ដល់ពេលទៅឃោសនា ខ្ញុំបែរទៅឃោសនា ឱ្យលោកឃួន.ណៃ នៅខែត្រកំពង់ចាមទៅវិញ ព្រោះខ្ញុំស្រឡាញ់ឧត្តមគតិរបស់លោក ។ ក្នុងពេលឃោសនា ខ្ញុំសង្កេតមើលចិត្តរាស្ត្រសព្វគ្រប់ ឃើញថាមានសង្ឃឹមតិចណាស់ក្នុង ១០០មាន តែ៣០ទេ ដោយ

ហេតុ ២យ៉ាង១រាស្ត្រមិនបានក្បត់នឹងព្រះករុណាជាម៉ែឪទេ ។ ២ លោកស៊ឹម.វ៉ា អ្នកផ្តើមគំនិតបង្កើតគណបក្សនេះឡើង លោកចេញពីគណបក្សប្រជាធិបតេយ្យទៅហើយ ហើយលោកនេះហើយអ្នកទាមទារឯករាជ្យមុនគេឯង តាំងពីជំនាន់កាសែតនគរវត្តលោកយល់ថាគណបក្សនេះ មិនល្អបានជាលោកលាចេញពីគណបក្សនេះ ។

ខ្ញុំត្រឡប់មកពីកំពង់ចាមវិញ ត្រូវទៅជួយឃោសនាលោកម៉ម.លនក្នុងខែត្រកណ្តាលទៀត ខ្ញុំពិនិត្យឃើញទឹកចិត្តរាស្ត្រនៅតែដដែល ដូចខ្ញុំជំរាបគោលការណ៍ខាងលើពីរខនេះស្រាប់ហើយ តាមខ្ញុំប៉ាន់ស្មានមើល ក្នុងមណ្ឌលលោកម៉ម.លននេះ មានរាស្ត្របោះឆ្នោតឱ្យប្រហែល ១០ភាគរយប៉ុណ្ណោះទេ ។ ខ្ញុំធ្វើសេចក្តីរាយការណ៍ជូនគណកម្មាធិការនាយកគណបក្សប្រជាធិបតេយ្យ ថាបោះឆ្នោតលើកនេះ មានសេចក្តីសង្ឃឹមស្ទួចស្តើងណាស់ ។ លុះដល់ថ្ងៃក្រោយមកទៀតត្រូវចេញទៅឃោសនានៅខែត្រសៀមរាប មានរថយន្តជូនដំណើរទៅទាំងតូចទាំងធំ តាមខ្ញុំចាំបាន មិនតិចជាង១០រថយន្តទេ ទៅដល់ខែត្រសៀមរាប លោកអភិបាលខែត្រហ៊ុយ.ម៉ោង ទទួលគណកម្មការឃោសនា បក្សប្រជាធិបតេយ្យដោយរាក់ទាក់ជាទីបំផុត ។ ប៉ុន្តែលោកឃាត់មិនឱ្យឃោសនាទេ ព្រោះបើឃោសនាទៅ ពិតជាមានការបង្ហូរឈាមភ្លាមមួយរំពេច ។ លោកហ៊ុយ.ម៉ោង បាននាំទៅមើលប្រាសាទអង្គរវត្តទៅវិញ លុះដល់ត្រឡប់មកពីមើលប្រាសាទអង្គរវត្តវិញ ។ គណកម្មាធិការដោយមានលោកសោម.ចាំងជាអ្នកដឹកនាំ បានចូលទៅជួបនិងគណកម្មការអន្តរជាតិដែលមានប្រទេសឥណ្ឌា ជាប្រធានជំរាបថាយើងយើង

មកនេះដើម្បីឃោសនា ពន្យល់រាស្ត្រអំពីវិធីរបស់គណបក្សប្រជាធិបតេយ្យ ក្នុងការជ្រើសអ្នកដំណាងរាស្ត្រ ឥឡូវនេះព្រឹត្តិការណ៍ហាមឃាត់មិនឱ្យយើងខ្ញុំឃោសនាបាន មានន័យថាគណបក្សប្រជាធិបតេយ្យគ្មានសេរីភាពក្នុងការឃោសនាបោះឆ្នោតនោះផងទេ ផ្ទុយទៅវិញមានតែគណបក្សសង្គមរាស្ត្រនិយមតែម្នាក់ឯង ។ សុំឱ្យគណកម្មការអន្តរជាតិ ធ្វើសេចក្តីកត់ហេតុប្តឹងទៅប្រធានសន្និសីទហ្សឺណែវ ដើម្បីសម្រួលកិច្ចការនេះឱ្យបានស្រួល ។ គណកម្មការឃោសនា បានទទួលទានដំណេកនៅសណ្ឋាគារមួយរង់ចាំព្រឹកឡើងនឹងត្រឡប់មកភ្នំពេញវិញ តាមខែត្រកំពង់ធំ ។

ក្នុងយប់នោះ មានឪពុកទាហានដាបឈ្មួនម្នាក់ដែលជាមិត្តស្និទ្ធស្នាលនឹងលោកសុត.ចំរើន មកនិយាយប្រាប់លោកសុតចំរើនថា ស្អែកនេះគេនឹងសម្លាប់អ្នកឃោសនានាខាងគណបក្សប្រជាធិបតេយ្យទាំងអស់ នៅស្រុកកំពង់ក្តីនោះហើយ ។ ពេលដោយស្មានប្រហែលជាម៉ោង ៣ ខ្ញុំង៉ែត.ហៀនឡើងបត់ជើងតូចស្រាប់តែឃើញលោកសុត.ចំរើន កំពុងតែចរចាគ្នានឹងតាម្នាក់ ដែលខ្ញុំពុំស្គាល់ឈ្មោះលោកសុត.ចំរើនបានហៅខ្ញុំ ទៅប្រាប់រឿងអាថ៌កំបាំងនេះ ។ ខ្ញុំជំរាបលោកសុតចំរើនវិញថា សូមកុំឱ្យបែកការរឿងនេះឱ្យសោះ បើកាលណាបែកការហើ ពិតជារកច្រកចេញមិនរួចទេ ។ ទុកភារកិច្ចនេះឱ្យខ្ញុំដោះស្រាយតែម្នាក់ឯងបានហើយ លោកសុតចំរើនសួរអំពីមធ្យោបាយដោះស្រាយរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ទៅវិញថា ត្រូវយើងទៅភ្នំពេញវិញ តាមខែត្របាត់ដំបងទើបបានរួចគ្រោះថ្នាក់ផុត លោកសុត.ចំរើន យល់ស្របតាម ។ ម៉ោង ៥ភ្លឺបានដាស់គ្នីគ្នាឡើង លោកសុត.ចំរើន ស្មើ

ខ្ញុំង៉ែត.ហៀនធ្វើជាមគ្គុទ្ទេសក៍អ្នកនាំផ្លូវ ព្រោះទៅកាន់មណ្ឌលកំពង់ក្តីជាមណ្ឌលរបស់ខ្ញុំ ។ មនុស្សទាំងអស់បានយល់ព្រមតាមសេចក្តីស្នើសុំរបស់លោកសុត.ចំរើន ខ្ញុំង៉ែត.ហៀនប្រកាសថាបើដូច្នោះឃើញរថយន្តខ្ញុំបើកទៅខាងណា ត្រូវតែបើកតាមខានមិនបានជាដាច់ខាត រថយន្តណាមួយមិនបើកតាមខ្ញុំទេត្រូវមានទោសធ្ងន់គឺខុសនឹងមតិភាគច្រើន ។ លុះព្រឹកឡើងយើងទាំងអស់គ្នា ទៅទទួលទានអាហារពេលព្រឹកពេលម៉ោង ៧ លោកហ៊ុយ ម៉ោងអភិបាលខេត្ត បានមករួមពិសារជាមួយផង លោកចេញថ្លៃអាហារឱ្យចិនទាំងអស់ ។ យើងចាប់ចេញដំណើរបររថយន្តព័ទ្ធផ្សារសៀមរាបចុះឡើង ដើម្បីបង្ហាញឱ្យឃើញថា យើងទាំងអស់គ្នានេះ រៀបចេញដំណើរទៅកំពង់ក្តីហើយ ស្រាប់តែឃើញរថយន្តដឹកទាហានយ៉ាងធំៗ ៤ បរឆ្ពោះទៅសំដៅស្រុកកំពង់ក្តី ដើម្បីទៅរង់ចាំធ្វើបាបពួកយើងនៅទីនោះ ដែលកំបាំងពីភ្នែកគណកម្មការអន្តរជាតិ ។

នេះជាសញ្ញាឱ្យខ្ញុំកត់សំគាល់បាន ថាដំណើរដែលលោកសុតចំរើនឱ្យមកនោះ វាពិតដប់គ្រប់ដប់ទៅហើយ ។ ខ្ញុំង៉ែត-ហៀន បររថយន្តខាងមុខគេទាំងអស់បាន មួយជុំផ្សារសៀមរាបទៀត ដើម្បីឱ្យរថយន្តទាហានទាំង៤ នោះទៅឆ្ងាយបន្តិច ស្រាប់តែខ្ញុំបើករថយន្តដាក់លេខ ១០០ សំដៅទៅខេត្តបាត់ដំបងតែម្តង ។ រថយន្តទាំងអស់ដែលបើកក្រោយរថយន្តខ្ញុំក៏បើកតាមយ៉ាងលឿនដូចគ្នាដល់មកផ្សារកំពង់កំពង់ថ្កូវ ត្រូវចូលទៅយកបេក្ខជនម្នាក់មកពីភ្នំពេញវិញផង ។ ស្រាប់តែរថយន្តសេអ៊ឹមហ្សេផ្ទុកដោយទាហានពេញទាំងអស់ពីរទៀតបើកដេញតាមពីក្រោយចូលទៅស្រុកក្រឡាញ់ ។ ដោយស្មានថាពួកឃោសនីក បើករថយន្ត

ទៅស្រុកក្រឡាញ់ យើងទាំងអស់គ្នាបានបើករថយន្តចេញពីផ្សារកំពង់ថ្កូវមកវិញ បានដឹងច្បាស់ថា មានទាហានចេញតាមព្យាបាទពីខាងក្រោយហើយ បានបើករថយន្តឆ្ពោះទៅខេត្តបាត់ដំបង គណកម្មការឃោសនីក បានក្លាយខ្លួនទៅជាអ្នកស៊ើបយកការ នៅទីរួមខេត្តបាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង ដល់ម៉ោង ៥ ល្ងាច បានមករួមប្រជុំនឹងគណកម្មការនាយក នៅសណ្ឋាគារ សុង-គុន ខ្ញុំង៉ែត-ហៀន បានថ្លែងការជំរាបគណកម្មការនាយកតាមដំណើរដូចជំរាបដូចខាងលើនោះរួចមកហើយ ។ គណកម្មាធិការនាយក ក៏ជួយត្រេកអរអំពីមធ្យោបាយ ដែលដោះកុនរួចពីសេចក្តីស្លាប់ ។ ខ្ញុំមិនទាន់អស់ចិត្តទេបើកថយន្តផ្ទាល់ខ្លួន ជាមួយនិងក្រុមគ្រួសារស៊ើបយកការ នៅក្នុងខេត្តកណ្តាល-តាកែវកំពត កំពង់សោម-កំពង់ស្ពឺ អស់ថេរៈវេលាប្រហែល ១អាទិត្យទៀត ។ ថ្ងៃក្រោយខ្ញុំបើករថយន្តទៅស៊ើបយកការនៅខេត្តស្វាយរៀង និងខេត្តព្រៃវែងថែមទៀត ។ ខ្ញុំប្រមូលលទ្ធផលនៃការស៊ើបអង្កេតទាំងនោះយកមកពិចារណាតែម្នាក់ឯង ខ្ញុំឃើញតាមផ្លូវចិត្តថាគ្មានឈ្មោះ ឆ្នោតសង្គមរាស្ត្រនិយមកើតទាល់តែសោះ ខ្ញុំប្រាប់មិត្តខ្ញុំ ៣នាក់ ១-លោកស្វាយ- សូ ២-លោកចាប.ស៊ុំ ៣-លោកឃិន.ឆែ មិត្តទាំង៣នាក់នេះយល់ស្របតាមខ្ញុំភាគច្រើន ប៉ុន្តែមិត្តទាំង៣នាក់នេះឆ្លើយមកវិញថា ប្រសិនបើយើងមិនបោះឆ្នោតជាមួយនឹងគេជាការឥតប្រយោជន៍ទេ ព្រោះគណបក្សសេរីភាព នឹងគណបក្សដម្កើង ប្រជាជាតិគេនៅតែបោះឆ្នោតដដែល ។

ថ្ងៃបន្ទាប់មក ខ្ញុំទៅជួបនឹងលោកវេជ្ជបណ្ឌិតនាលផ្លែង ដែលជាមិត្តភក្តិរបស់ខ្ញុំយ៉ាងជិតស្និត ដើម្បីសួរបញ្ជាក់ថា បើគណបក្សប្រជាធិបតេយ្យឈប់បោះ

ឆ្នោតគណបក្សសេរីភាពយ៉ាងម្ដេចដែរ លោកនាលផ្ទើងឆ្លើយមកខ្ញុំវិញថា បើគណបក្សប្រជាធិបតេយ្យឈប់បោះឆ្នោត គណបក្សសេរីភាពក៏ឈប់បោះឆ្នោតដែរ ហើយថែមទាំងធានាអះអាងទៀតថា គណបក្សដម្កើងប្រជាជាតិមិនព្រមបោះឆ្នោត ដូចគណបក្សសេរីភាពដែរ ។ ខ្ញុំប្រមូលលទ្ធផលនៃការមិនយល់ព្រមបោះឆ្នោតតទៅទៀត បានសព្វគ្រប់ហើយ ។ ទើបខ្ញុំធ្វើសេចក្ដីរាយការណ៍មួយជំរាបគណកម្មាធិការនាយកគណបក្សប្រជាធិបតេយ្យ ។

គណកម្មាធិការនាយក គណបក្សប្រជាធិបតេយ្យឆ្លើយមកខ្ញុំវិញថា រឿងនេះស្រេចតែលោកកេង.វ៉ាន់សាក់ទេ ទើបខ្ញុំនិងលោកឃិន ឆែនាំគ្នាទៅដល់ផ្ទះលោកកេង.វ៉ាន់សាក់តែម្ដង ដើម្បីបំភ្លឺរឿងនេះសព្វគ្រប់ លោកកេង.វ៉ាន់សាក់ឆ្លើយមកវិញថាៈ ខ្ញុំនិងលោកឃិនឆៃយល់ដោយភាន់ច្រឡំទេ តាមការពិតទៅវិញគណបក្សយើងត្រូវឈ្នះឆ្នោតសង្គមរាស្ត្រនិយម ៧០ភាគរយទៅហើយ ។ ខ្ញុំង៉ែត.ហៀនហួសចិត្តនឹងការយល់ឃើញរបស់លោកកេង.វ៉ាន់សាក់ លោកមានសញ្ញាប័ត្រជាន់ខ្ពស់ពិតប្រាកដមែនហើយ ប៉ុន្តែផ្លូវចិត្តវិញ លោកគ្មានស្គាល់ចិត្តរបស់រាស្ត្រទាល់តែសោះ ។ ខ្ញុំង៉ែត.ហៀននិងលោកឃិន.ឆៃ បានពន្យល់លោកកេង.វ៉ាន់សាក់ពីផ្លូវច្បាប់ និងផ្លូវនយោបាយថា បើប្រសិនជាគណបក្សទាំងអស់មិនព្រមបោះឆ្នោត មានន័យថា គណកម្មការអន្តរជាតិ អនុវត្តន៍សន្និសីទហ្សឺណែវមិនត្រឹមត្រូវតាមច្បាប់ទេ ។ ដោយគណបក្សទាំងអស់ គ្មានសិទ្ធិសេរីភាពនឹងឃោសនាពន្យល់រាស្ត្រ ព្រោះសង្គមរាស្ត្រនិយមកាន់អំណាច បិទសិទ្ធិសេរីភាពមិនឱ្យគណបក្សឯទៀតឃោសនាបានផង ប្រសិនបើធ្វើយ៉ាងនោះទៅពិតជាមានការ

ប្រែប្រួល គណកម្មការអន្តរជាតិបើកឱ្យគណៈបក្សទាំងអស់មានសិទ្ធិសេរីភាពដូចគ្នា ។ លោកកេង.វ៉ាន់សាក់មិនយល់ព្រមតាមសេចក្ដីស្នើសុំរបស់ខ្ញុំង៉ែត.ហៀន និងលោកឃិន.ឆៃទេ ។ ខ្ញុំសូមបញ្ជាក់ថា មុនថ្ងៃបោះឆ្នោតនៅមុនការិយាល័យគណបក្ស ស្រាប់តែគណបក្សសង្គមរាស្ត្រនិយមប្រើអំណាចផ្ដាច់ការ មកលើគណបក្សប្រជាធិបតេយ្យ ក្នុងពេលឃោសនាមានបាញ់លោកកេង.វ៉ាន់សាក់ផង ប៉ុន្តែចៃដន្យគ្រាប់កាំភ្លើងនោះ ហួសទៅត្រូវអ្នកបើករថយន្តលោកចាងហ្វាងសាំ.សុងហ្វេណង់ដែស ទៅវិញ ។

ដល់ពេលបោះឆ្នោត គណបក្សប្រជាធិបតេយ្យ និងគណបក្សឯទៀតសៅ្ងតែម្ដង សង្គមបានកៅអីនៅក្នុងរដ្ឋសភាទាំងអស់ ហើយថែមទាំងបេក្ខជនគណបក្សប្រជាធិតេយ្យត្រូវរងគ្រោះស្ទើរគ្រប់គ្នា ។

ខ្ញុំង៉ែត.ហៀនដែលនិយាយនេះ គ្រាន់តែបញ្ជាក់បង្ហាញឱ្យឃើញថា តាមសំដីអ្នកអង្គម្ចាស់យុត្តិវង្ស លោកមានព្រះបន្ទូលប្រាប់ខ្ញុំថាក្នុងគណបក្សប្រជាធិបតេយ្យ យើងមានតែលោកអៀវ.កើសម្នាក់ទេ ដែលស្គាល់ចិត្តរាស្ត្រច្បាស់លាស់ជាងគេជាងឯង ។

ខ្ញុំសុំបញ្ជាក់ថែមទៀតថា គណបក្សប្រជាធិបតេយ្យឈ្នះឆ្នោតលើកទីពាតមកទៀតថា គណកម្មការនាយកជាន់ចាស់តាមគម្រោងការរបស់លោកអៀវ.កើសស្ទើរតែទាំងអស់ ។

ហេតុដែលគណបក្សប្រជាធិបតេយ្យត្រូវបរាជ័យនេះ មកពីវរជនក្មេងៗមិនព្រមស្ដាប់វរជនចាស់ៗ ទាល់តែសោះ បើប្រសិនជាវរជនក្មេងៗ ស្ដាប់វរជន

ចាស់ៗ ផង បើនឹងចាញ់ឆ្នោតសង្គមរាស្ត្រនិយម ក៏ល្អមើលណាស់ដែរ ។

សង្គមរាស្ត្រនិយមបានឡើងកាន់អំណាចរដ្ឋធ្វើការមុនដំបូង មានជោគជ័យគួរឱ្យសរសើរ ប៉ុន្តែដល់យូរទៅចេះតែអន់ថយចុះជាលំដាប់ ក្នុងពេលនោះខ្ញុំង៉ែត.ហៀនឈប់ធ្វើនយោបាយហើយ ក្លាយខ្លួនទៅជាអ្នកសង្កេតការណ៍ទៅវិញ ។ ខ្ញុំសូមសារភាពត្រឡប់ជំរាបមិត្តអាន ពីរឿងលោកស៊ឹង.ង៉ុកថាន់ មិនបានចូលមករួបបោះឆ្នោតក្នុងសង្គមជាតិវិញនោះមានហេតុដូចតទៅនេះ ។

ដើមដំបូងឡើងលោកអ៊ាស៊ុចូវបានជួបនឹងខ្ញុំង៉ែត.ហៀន នៅភោជនីយដ្ឋានដុងគីញនៅខាងមុខរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្រាប់ខ្ញុំថា ខ្ញុំតាមរកលោកបងឯង បីបួនថ្ងៃហើយ រកមិនឃើញសោះ ។ បានឱ្យក្មេងទៅរកដល់ផ្ទះទៀតក៏មិនបានជួប ខ្ញុំសួរទៅវិញថារកខ្ញុំមានការអី លោកអ៊ាស៊ុចូវប្រាប់មកខ្ញុំវិញថា បងឯងជាមនុស្សចាស់ទុំ មានសំបុត្រមួយ ពីលោកស៊ឹង.ង៉ុកថាន់ ។ សុំឱ្យសម្តេចសីហនុជួយធានារ៉ាប់រងអំពីសន្តិសុខរបស់លោកផង ដើម្បីចរចាគ្នាឱ្យជ្រះស្រឡះពីរឿងខ្វែងយោបល់គ្នាក្នុងការទាមទារឯករាជ្យនោះផង សំបុត្រនោះ លោកប៉ាច.ឈឿនបានយកទៅឱ្យលោកប៉ូ.ហ៊ែងថ្វាយសម្តេចសីហនុហើយ ។ ខ្ញុំសុំបងឯងជួយធ្វើអន្តរាគមន៍ក្នុងរឿងនេះឱ្យបានស្រួលផង ព្រោះខ្ញុំដឹងច្បាស់ថាបងឯងនេះ ជាកូនចៅសម្តេចសុទ្ធារស ប្រហែលជាទៅធ្វើអន្តរាគមន៍ក្នុងរឿងនេះបានផលល្អ ។ ខ្ញុំឆ្លើយតបវិញថាខ្ញុំជាកូនចៅសម្តេចសុទ្ធារសពិតមែន ប៉ុន្តែសម្តេចសីហនុ គាត់ឥតស្គាល់ខ្ញុំទេ មនុស្សដែលព្រះអង្គលោកស្គាល់នោះ មានតែលោកញ៉ឹក.ទូ និង លោកអ៊ុក.ម៉ូតទេ ប៉ែកខាងព្រះសង្ឃមានតែលោកគ្រូមហាព្រហ្មមុនីទេព.អ៊ូ និងលោក

វ៉ាន់.សាខុម ទេ ដែលសម្តេចសីហនុ ស្គាល់ហើយរាប់អានផង ។ លោកអ៊ា.ស៊ីចូវ ថាបើ ដូច្នេះខ្ញុំសុំពឹងបងឯងទៅនិយាយ ការណ៍នេះ និងលោកមហាព្រហ្មមុនីទេព អ៊ូ ឱ្យជួយធ្វើអន្តរាគមន៍ ដើម្បីឱ្យជាតិ មានសាមគ្គីភាពជាឯកភាពទៅវិញ ។

ខ្ញុំទទួលបេសកកម្មនោះពីពេលព្រឹក ដល់ពេលល្ងាចឡើងប្រហែលជាម៉ោង៧ ខ្ញុំបានទៅវត្តស្វាយពពែ ជួបនឹងលោកគ្រូមហាព្រហ្មមុនីទេព អ៊ូ សុំឱ្យជួយធ្វើអន្តរាគមន៍ សម្របសម្រួល រឿងនេះឱ្យបានស្រួល ។ លោកគ្រូមហាព្រហ្មមុនីទេព អ៊ូឃើញខ្ញុំ សួរថាមកមានការអ្វី ? ខ្ញុំក្រាបបង្គំទូលតាមដំណើរ ស្រាប់តែលោកមានពុទ្ធដីការថា សម្តេចព្រះអយ្យកោមានលិខិតបណ្តាំ សុំឱ្យអាត្មាជួយរក្សាសុខទុករាជ្យបុត្រនិងចៅរបស់ព្រះអង្គផង ។ រឿងនេះអាត្មាទៅនិយាយឱ្យបាន ប៉ុន្តែបានលទ្ធផលយ៉ាងណានោះមិនដឹងទេ ព្រោះស្តេចមានទីប្រឹក្សាច្រើនណាស់មិនអាចសម្រេចអ្វីតាមបំណងបានទេ វាស្រេចលើរដ្ឋាភិបាល ។ ខ្ញុំក៏ថ្វាយបង្គំលាលោកត្រឡប់មកផ្ទះវិញ ថ្ងៃក្រោយជួបនិងលោកអ៊ា.ស៊ីចូវ ម្តងទៀតខ្ញុំរាយការណ៍ ប្រាប់តាមដំណើរ ។ ជំរាបពីលទ្ធផលដែលលោកគ្រូមហាព្រហ្មមុនីទេព.អ៊ូ ទៅធ្វើអន្តរាគមន៍នោះបានលទ្ធផលផ្ទុយទៅវិញ លោកគ្រូមហាព្រហ្មមុនីទេព អ៊ូ ប្រាប់ខ្ញុំថា មិនកើតទេរឿងឱ្យអាត្មាស្នើនោះ ហើយបញ្ជាក់ថានរណាប្រទូស្តរាយនឹង លោកស៊ឹង.ង៉ុកថាន់ដូចបាចអង្កាមច្រាសខ្យល់ ខ្ញុំយកដំណឹងនេះទៅប្រាប់អ៊ា.ស៊ីចូវ វិញ ។ ថ្ងៃក្រោយលោកអ៊ា.ស៊ីចូវប្រាប់ខ្ញុំថា ពិតជាមិនបានស្រួលទេប្រទេសយើង ក្នុងអនាគតកាល ព្រោះជាតិយើងគ្មានឯកភាព តាមសន្និសីទបរ្បីណែវ សូមបងឯង កត់ទុកនៅក្នុងសៀវភៅមួយចំណាំមើលទៅចុះ ។

ខ្ញុំចាំពាក្យនោះគ្មានភ្លេចសោះ ស្រាប់តែថ្ងៃក្រោយឃើញហេតុដាបឈ្លួនក្បត់នាំឱ្យខ្ញុំយល់ថាពាក្យអ៊ា.ស៊ីចូវថា នោះ បានត្រូវខ្លះហើយ ហើយខ្ញុំចេះតែនឹកថាពិតជាចប់ត្រឹមនេះទេដឹង ។ ដល់សម្ដេចប្រមុខរដ្ឋអនុញ្ញាតឱ្យទូតអាមេរិកមានរដ្ឋទូតឡើងវិញនាំឱ្យខ្ញុំចាប់អារម្មណ៍ ដល់ពាក្យលោកអ៊ា.ស៊ីចូវ ព្រោះខ្ញុំឃើញថាពួកយៀកកុងមក រកលាក់ខ្លួនតាមទល់ដែន ពេញប្រទេសទៅហើយមុខជាអាមេរិកកាំងដឹងរឿងនេះមិនលែង ។ កាលណាបើអាមេរិកកាំងដឹងច្បាស់មុខជាមិនស្រួល ហើយប្រទេសមុខ ជាមានហេតុមិនខាន ។ មានថ្ងៃមួយខ្ញុំង៉ែត.ហៀនបានជួបលោកស៊ឹម.វ៉ា នៅសាលាជំបូងភ្នំពេញ លោកប្រាប់ខ្ញុំថាតែកាលណាប្រទេសយើង រេពីអព្យាក្រិតភាព ពិតជាប្រទេសមានគ្រោះថ្នាក់ផ្លូវរស់មានតែមួយគត់ គឺអព្យាក្រិតភាព ឥឡូវនេះប្រមុខរដ្ឋចាក់ខែលទៅរកកុម្មុយនិស្ត ហើយគ្មាននរណានិយាយស្ដាប់ទេ ស្ដាប់តែលោកចៅ.សេង ម្នាក់ឯងយកអ្នកជំណាងរាស្ត្រមក ធ្វើជាសត្រូវ ហើយខ្ញុំនេះដេកចាំតែស្លាប់ ខ្ញុំចំណាស់នេះហើយ ខ្ញុំមិនខ្លាចស្លាប់ទេ ឧត្តមគតិខ្ញុំយ៉ាងណាត្រូវតែខ្ញុំនៅយ៉ាងនោះ ។ ខ្ញុំឮសំដីលោកស៊ឹម.វ៉ា ខ្ញុំហួសចិត្តព្រោះលោកនេះជាមនុស្សដែលសម្ដេចឪ រាប់អានជាងគេ ជាងឯង ជាយូរអង្វែងឆ្នាំមកហើយ ។

ល្ងាចឡើងលោកជូ.ហ៊ឹងជាមិត្តរបស់ខ្ញុំ មកលេងផ្ទះខ្ញុំ ដើម្បីសន្ទនាគ្នាអំពីនយោបាយប្រទេសជាតិ ។ មនុស្សនេះជាអ្នកជំនួញចូលចិត្តតែខាងអាមេរិកកាំងស្អប់បក្សកុម្មុយនិស្តយ៉ាងលើសលប់ ខ្ញុំសួរចង់ដឹងថា ក្នុងចំណោមអ្នកជំនួញ ដែលមានចិត្តស្រឡាញ់អាមេរិកមានច្រើនឬតិច ឈ្មោះនេះបានឆ្លើយប្រាប់ខ្ញុំមកវិញថា

៩០ភាគរយ ។ ខ្ញុំឆ្លើយទៅវិញថា តាមដំណឹងពីព្រឹកមិញនេះ លោកស៊ឹម.វ៉ា ថា សម្តេចឪ បែបដឹកនាំប្រទេសចូលខាងកុម្មុយនិស្តហើយ ។ រំលងមកតាមស្មាន ប្រហែលជា ៣ខែប៉ុណ្ណោះ ស្រាប់តែ គឺព្រឹត្តិការណ៍ថ្ងៃ ១៨ មីនា ឆ្នាំ ១៩៧០ ដូចអ្នកផងជ្រាប ស្រាប់ហើយ ។

## វគ្គទី ១៥

ប្រទេសយៀកណាមខាងជើងនិងយៀកកុង ចូលមកវាយប្រហារប្រទេសកម្ពុជាយើង ដោយយកលេសថាមករំដោះប្រទេសកម្ពុជា ពីចក្រពត្រនិយមអាមេរិកកាំងឱ្យម្ចាស់ដើមវិញ ។ មធ្យោបាយនេះមិនខុសគ្នាពីមធ្យោបាយអាមេរិកកាំងដែលអាងលេសថា មកជួយវៀតណាមខាងត្បូងដើម្បីរំដោះប្រទេសវៀតណាមខាងត្បូងឱ្យម្ចាស់ដើមវិញទេ ។ វៀតណាមខាងជើងទាមទារឱ្យអាមេរិកាំង ត្រឡប់ទៅប្រទេសខ្លួនវិញ ទុកបញ្ហាយៀកណាមនិងយៀកណាមដោះស្រាយដោយខ្លួនឯង បើដូច្នេះខេមរជាតិ ត្រូវតែមានសិទ្ធិ សូមដើរផ្លូវដែលវៀតណាមខាងជើងគូសបញ្ជាក់ ឱ្យអាមេរិកកាំងដើរតាមផងដែរ តែសុំឱ្យវៀតណាមខាងជើងនិងយៀកកុងដកថយទ័ពចេញពីប្រទេសកម្ពុជា ដោយទុកបញ្ហានេះឱ្យខ្មែរដោះស្រាយរវាងខ្មែរនិងខ្មែរគ្នាឯងទៅវិញ ។ បើយៀកណាមខាងជើងមិនគោរពតាមសេចក្តីសុំនោះទេ អាមេរិកកាំងមានសិទ្ធិ ពេញបរិបូរណ៍ មិនគោរពតាមសេចក្តីសុំរបស់វៀតណាមខាងជើងដែរ ។

បើដូច្នេះ វៀតណាមខាងជើង កាលណាទៅនឹងចប់សង្គ្រាមបាន ព្រោះបើវៀតណាមខាងជើងចោទថា អាមេរិកកាន់ឈ្លានពាន ខេមរជាតិខ្មែរក៏មានសិទ្ធិចោទប្រកាន់វៀតណាមខាងជើង និងវៀតកុងឈ្លានពានដូចតែគ្នាដែរ ។

ដើម្បីបញ្ចាក់នូវជម្លោះជាអន្តរជាតិ លើទឹកដីវៀតណាមចិននេះបានត្រូវតែគូភាគីអន្តជាតិ អាមេរិកកាំងដកកងទ័ពចេញពីប្រទេសវៀតណាមខាងត្បូង ត្រូវវៀតណាមខាងជើងនិងវៀតកុង ដកកងទ័ពរបស់ខ្លួនចេញពីប្រទេសខ្មែរ និងប្រទេសលាវ ទើបមានតុល្យភាព ។

ន័យមួយវិញទៀត គួរតែរដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលលាវ ព្រមទាំងរដ្ឋាភិបាលវៀតខាងត្បូងផង ស្នើសុំដល់អង្គការសហប្រជាជាតិ ជាចុងក្រោយបំផុត សុំឱ្យអង្គការនេះ បង្គាប់ទៅសហប្រធានសន្និសីទហ្សឺណែវ ឱ្យកោះប្រជុំសន្និសីទហ្សឺណែវឡើងវិញ បើប្រសិនជាសហប្រធានពុំព្រមកោះប្រជុំសន្និសីទហ្សឺណែវ ដូចពីមុនៗទៀតទេ ។ ប្រទេសទាំងបីដែលរងគ្រោះត្រូវប្តឹងដល់ អ.ស.ប ដោយចេញមុខទៅតំទុកបញ្ហានេះតទៅទៀត នាំឱ្យស្លាប់ពលរដ្ឋវៀតណាមចិនច្រើនណាស់ ។ កំហុសអស់នេះពុំមែននៅលើរដ្ឋាភិបាលខ្មែរ, រដ្ឋាភិបាលលាវនិងរដ្ឋាភិបាលវៀតណាមខាងត្បូងទេ, ពិតជានៅលើប្រទេសណាមិនព្រមប្រជុំសន្និសីទហ្សឺណែវតែម្តង ។

*ក្នុងសៀវភៅនេះ* មានត្រ័យរត្តនវត្ថុ ៣ យ៉ាង : ១ ទង់ជាតិ ជានិមិត្តរូបនៃប្រាជ្ញាជនជាតិខ្មែរ ។ *២រដ្ឋធម្មនុញ្ញ ជានិមិត្តរូបនៃខួរក្បាលជនជាតិខ្មែរ ។ ៣ វិមានឯករាជ្យ ជានិមិត្តរូបនៃបេះដូងជនជាតិខ្មែរ* ។ ជនជាតិខ្មែរ ធ្លាប់ទីពឹង

ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ការទីពឹងនោះត្រឹមត្រូវហើយ សម្រាប់ផ្លូវព្រះពុទ្ធសាសនាផង សម្រាប់បរលោកផង ប៉ុន្តែផ្លូវសម្រាប់ជាតិវិញ ត្រូវពឹងផ្អែកលើទង់ជាតិ រដ្ឋធម្មនុញ្ញ, វិមានឯករាជ្យ, ទើបស្របតាមនយោបាយរបស់ជាតិខ្មែរ ។

## ការពឹងផ្អែកលើទង់ជាតិ

ពុំមែនមានន័យថាពឹងកំណាត់សំពត់នោះទេ កំណាត់សំពត់គ្រាន់តែជានិមិត្តរូបបញ្ញានៃជនជាតិខ្មែរទាំង ៨ លាននាក់ បើដូច្នេះករណីកិច្ចរបស់រដ្ឋាភិបាលត្រូវតែអប់រំជាតិខ្មែរឱ្យមានប្រាជ្ញាច្រើនសម្រាប់តទល់នឹងសត្រូវ ដែលមកឈ្លានពានទឹកដីយើងដើម្បីកុំឱ្យជាតិយើងធ្លាក់ចុះទៅជាទាសភាពបាន ។

## ការពឹងផ្អែកលើរដ្ឋធម្មនុញ្ញ

ពុំមែនពឹងផ្អែកលើសៀវភៅរដ្ឋធម្មនុញ្ញទាំងស្រុងនោះទេ រដ្ឋធម្មនុញ្ញគ្រាន់តែជានិមិត្តរូបនៃខួរក្បាលជនជាតិខ្មែរទាំង ៨ លាននាក់គឺត្រូវពឹងផ្អែកទៅខួរក្បាលចេះដឹងនៃជនជាតិខ្មែរ ទាំងជាតិទៅវិញបើដូច្នេះជនជាតិខ្មែរម្នាក់ត្រូវសួរខ្លួនឯងមើល តើចេះរដ្ឋធម្មនុញ្ញ គ្រប់គ្រាន់ហើយឬនៅ? បើអ្នកកាន់អំណាចអង្គការរដ្ឋប្រព្រឹត្តរំលោភលើច្បាប់ ជនអ្នករងគ្រោះដឹងឬទេ? បើឥតមានដឹងអ្វីទេពិតជាការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ តាមច្បាប់រដ្ឋធម្មនុញ្ញពិតវាគ្មានប្រសិទ្ធិភាពដល់ប្រជាពលរដ្ឋទេ លទ្ធិផ្តាច់ការនៅតែក្លែងខ្លួនមកបន្ថំបាន ។

## ការទីពឹងវិមានឯករាជ្យ

ពុំមែនទីពឹងដុំថ្មគ្រួសខ្សាច់ស៊ីម៉ង់នឹងរូបចម្លាក់នោះទេ វិមានឯករាជ្យនេះ

គ្រាន់តែជានិមិត្តរូបបេះដូងជនជាតិខ្មែរ ៨ លាននាក់តែប៉ុណ្ណោះ តាមការពិតទៅវិញ ត្រូវតែទីពឹងបេះដូងជនជាតិខ្មែរទាំងជាតិ ព្រោះបេះដូងជាវត្ថុធាតុសម្រាប់រស់នៅមនុស្សម្នាក់ៗ ។ តែកាលណាយើងសុខចិត្តលះបង់បេះដូងបូជាជូនទៅជាតិហើយមានន័យថាមនុស្សឥតខ្លាចស្លាប់ទេ ។ បើយើងហើយហ៊ានយកសេចក្ដីស្លាប់មកដាក់ពីក្រោយខ្នង ពិតជាមានសេចក្ដីក្លាហានហ៊ានពុះពារឧបសគ្គចង្រៃដែលមករារាំងសេចក្ដីចំរើនរបស់ជាតិ ពិតជាយើងដឹកនាំជាតិឱ្យបានទៅជួបសុភមង្គល ដែលជាទីដៅរបស់រដ្ឋាភិបាលពុំខានឡើយ ។

តាមទស្សនៈរបស់ខ្ញុំ នាឡិកាពិភពលោកបានវិលចុះវិឡើង ឥឡូវនេះទ្រនិចនាឡិកានោះបានចង្អុលមកចំប្រទេសកម្ពុជា ដល់លេខចំម៉ោង ១០ ហើយត្រូវជាតិគ្រប់ភ្លាពួតដៃនឹងរដ្ឋាភិបាល ឱ្យបានជោគជ័យក្នុងសង្គ្រាមបច្ចុប្បន្ននេះពិតជាប្រទេសយើង នឹងក្លាយខ្លួនទៅជាមហាអំណាចឡើងវិញ ។ កាលបើខ្ញុំនិយាយបែបនេះមានអ្នកអានខ្លះគេសើចនឹងមតិរបស់ខ្ញុំ ថាខ្ញុំនេះជាមនុស្សឆ្កួតឬជា ចំណុចត្រង់នេះបំភ្លឺថា កាលលោកប៉ាច.ឈឿន លោកស៊ឺង.ង៉ុកថាន់ លោកស៊ុម.វ៉ា លោកង៉ោ.ហុងទាមទារឯករាជ្យពីអាណានិគមនិយមបារាំងនោះ អ្នកផងគេចោទពូកនេះថាវក្តូឆ្កួតទាំងអស់ ។ ប៉ុន្តែដោយអំណាចទឹកចិត្តមនុស្សបួននាក់រឹងដូចថ្ម មនុស្សចេះតែមកសុំចុះចូលកាន់តែច្រើន ធ្វើឱ្យសេចក្តីសង្ឃឹមរបស់ជាតិកាន់តែកម្លាំងខ្លាំងហ៊ានយកខ្លួនទៅស្លាប់ដើម្បីឯករាជ្យជាតិ ។

ខ្ញុំសូមបំភ្លឺថែមទៀតថា បើរំពិតតាមកាលបរិច្ឆេទពីឆ្នាំ ១៩៣៦ មកដល់ឆ្នាំ ១៩៥៤ នេះមានកំណត់ពេលតែ ២៨ឆ្នាំប៉ុណ្ណោះទេ ប្រទេសកម្ពុជាបានឯករាជ្យ

បរិបូរណ៍ ។

ការវិវត្តន៍របស់ជាតិខ្មែរ មានពាត់ណាក់គឺ ១-ជាតិយើងបានលទ្ធិប្រជាធិបតេយ្យ មានរដ្ឋធម្មនុញ្ញធានារ៉ាប់រង សម្រាប់គ្រប់គ្រងរដ្ឋដូចសព្វថ្ងៃនេះ ។ ២-ជាតិយើងបានឯករាជ្យពេញបរិបូណ បានចូលទៅអង្គុយក្នុងអង្គការ សហប្រជាជាតិស្មើមុខនឹងអារ្យប្រទេសដែរ យើងមានសិទ្ធនឹងរៀបចំសាកលលោកទៅថ្ងៃក្រោយ ដូចអារ្យប្រទេស ។ ៣-ជាតិយើងវិវត្តន៍ព្រឹត្តិការជាតិ មកដល់សាធារណរដ្ឋហើយ ត្រូវពង្រឹងសាធារណរដ្ឋឱ្យខ្លាំងឡើងថែមទៀត ។

ដោយអំណាចអតីតវិរបុរសរបស់ជាតិនឹងបច្ចុប្បន្នវីរបុរសរបស់ជាតិ មានសេចក្តីក្លាហានពុះពារនូវឧបសគ្គចង្រៃរបស់ជាតិចោល ។ បើយើងគ្រប់គ្នាងាកទៅមើលសមត្ថភាពវីរបុរសទាំងអស់នោះវិញ អ្នកចេញពីសកលវិទ្យាល័យមានតិចណាស់ បើយកមកប្រៀបធៀបយុវជនយើងសម័យនេះ ឃើញថាមានឥទ្ធិពលខុសគ្នាមួយជាដប់ទៅហើយ កម្លាំងវិទ្យាសាស្ត្រឃើញថាជាតិយើងមានល្បឿនជឿនលឿនគ្រាន់បើ ជាងសម័យមុន ។ តាមយោបល់ស្តួចស្តើងរបស់ខ្ញុំ គួរតែជាតិរិះរកមធ្យោបាយយ៉ាង ឱ្យយុវជនដែលមានបរិញ្ញាប័ត្រជាន់ខ្ពស់បានទៅកាន់មុខក្រសួង នឹងមុខការសំខាន់ ៗ របស់រដ្ឋប្រយោជន៍ដឹកនាំជាតិទៅរកមហាអំណាចដូចជំនាន់ដើមវិញ ដែលយើងបាត់បង់ជាច្រើនសតវត្សមកហើយ ។

មុននឹងបញ្ចប់ខ្ញុំសូមឱនសេរីសាគោរពដល់វិញ្ញាក្ខន្ធអតីតយុទ្ធជន ដែលមានគំនិតថ្លៃថ្នូរទាមទារ *លទ្ធិប្រជាធិបតេយ្យ និងឯករាជ្យ ព្រមទាំងសាធារណរដ្ឋមកជូនជាតិយើង* ហើយខ្ញុំសូមផ្ញើសេចក្តីសង្ឃឹមថា មុខជាអនុជនតាមដានរក

មហាអំណាចដែលយើងបាតបង់រាប់សតវត្សទៅហើយ មកជូនជាតិវិញពុំខានឡើយ ។

បើរិះគិត ដល់សន្និសញ្ញាសន្និសិទ្ធហ្សឺណែវពុំទាន់ជាស្ថាពរនៅឡើយទេ អនាគតកាលយ៉ាងខ្លីខាងមុខ មុខជាសន្និសិទ្ធហ្សឺណែវលើកយកបញ្ហាសង្គ្រាមប្រទេសកម្ពុជានេះទៅដោះស្រាយឱ្យជាតិយើងពុំខានឡើយ ។

# ចប់

មេធាវី **ម៉ែត ហៀន**